ក្រសួងបរិស្ថាន
Ministry of Environment

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
National Council for Sustainable Development

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
National Council of Khmer Language

# សទ្ទានុក្រម
# ការប្រែប្រួលអាកាសធាតុ




# LEXICON OF CLIMATE CHANGE

២០១៩

# សន្ទានុក្រមបច្ចេកសព្ទស្ដីពីការប្រែប្រួលអាកាសធាតុ

**បោះពុម្ពដោយ**
នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
និងក្រសួងបរិស្ថាន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**© ក្របមុខនិងរូបថតដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា**

**សម្គាល់**

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិភាសាខ្មែរ បានខិតខំប្រឹងប្រែងចងក្រងសទ្ទានុក្រមនេះឡើង ដើម្បីសម្រួលដល់ការប្រើប្រាស់បច្ចេកសព្ទប្រែប្រួលអាកាសធាតុឱ្យបានត្រឹមត្រូវនិងឯកភាពគ្នា។ ទោះបីជាសទ្ទានុក្រមនេះអាចនៅមានភាពខ្វះចន្លោះក្នុងបរិបទណាមួយក៏ដោយ ក៏យើងសង្ឃឹមថានេះគឺជាឯកសារមូលដ្ឋានចាំបាច់សម្រាប់អ្នកអានប្រើប្រាស់ទៅតាមតម្រូវការរៀងៗខ្លួន។

© រក្សាសិទ្ធិដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
និងក្រសួងបរិស្ថាន
បោះពុម្ពលើកទី២ ឆ្នាំ២០១៩

# សទ្ទានុក្រម
# ការប្រែប្រួលអាកាសធាតុ

## Lexicon of Climate Change


ក្រសួងបរិស្ថាន

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

ក្រុមប្រឹក្សាជាតិភាសាខ្មែរ



២០១៩

# មាតិកា


បុព្វកថា ---------------------------------------------- vii
អារម្ភកថា ----------------------------------------------ix
សេចក្ដីថ្លែងអំណរគុណ ----------------------------------------xi
របៀបប្រើប្រាស់សទ្ទានុក្រម -----------------------------------xiii
**ផ្នែកទី១** : **បច្ចេកសព្ទនិងនិយមន័យ ខ្មែរ-អង់គ្លេស** ------------------------ ១
**ក** ---------------------------------------------- ៣
**ខ** ---------------------------------------------- ៣៤
**គ** ---------------------------------------------- ៣៦
**ច** ---------------------------------------------- ៣៨
**ជ** ----------------------------------------------៤២
**ដ** ----------------------------------------------៤៦
**ឌ** ----------------------------------------------៤៨
**ត** ----------------------------------------------៤៩
**ថ** ---------------------------------------------- ៥១
**ទ** ---------------------------------------------- ៥៣
**ធ** ---------------------------------------------- ៥៧
**ន** ----------------------------------------------៥៨
**ប** ----------------------------------------------៥៩
**ផ** ----------------------------------------------៦៩
**ព** ---------------------------------------------- ៧៥
**ភ** ----------------------------------------------៧៩
**ម** ----------------------------------------------៨៤
**យ** ----------------------------------------------៨៩
**រ** ----------------------------------------------៩១
**ល** ----------------------------------------------៩៥
**វ** ----------------------------------------------៩៦
**ស** ----------------------------------------------៩៩

ហ ------------------------------------------------ ១១០
ឡ ------------------------------------------------ ១១១
អ ------------------------------------------------ ១១២
ផ្នែកទី២ : បច្ចេកសព្ទ អង់គ្លេស-ខ្មែរ ------------------------------------- ១២៥
A ------------------------------------------------ ១២៧
B ------------------------------------------------ ១៣០
C ------------------------------------------------ ១៣២
D ------------------------------------------------ ១៣៨
E ------------------------------------------------ ១៤០
F ------------------------------------------------ ១៤៣
G ------------------------------------------------ ១៤៥
H ------------------------------------------------ ១៤៧
I ------------------------------------------------ ១៤៩
J ------------------------------------------------ ១៥១
K ------------------------------------------------ ១៥១
L ------------------------------------------------ ១៥២
M ------------------------------------------------ ១៥៤
N ------------------------------------------------ ១៥៦
O ------------------------------------------------ ១៥៨
P ------------------------------------------------ ១៥៩
R ------------------------------------------------ ១៦១
S ------------------------------------------------ ១៦៣
T ------------------------------------------------ ១៦៦
U ------------------------------------------------ ១៦៧
V ------------------------------------------------ ១៦៨
W ------------------------------------------------ ១៦៩
Z ------------------------------------------------ ១៦៩
ផ្នែកទី៣ : អក្សរកាត់ ------------------------------------------------ ១៧១
ឯកសារពិគ្រោះ ------------------------------------------------ ១៨៥

# បុព្វកថា

ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាចម្បងមួយដែលមនុស្សជាតិកំពុងប្រឈម ដោយសារផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើងៗ ហើយមានវិសាលភាពកាន់តែធំជាងមុន ទៅលើគ្រប់ទិដ្ឋភាពសេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌។ ក្នុងន័យនេះ ចំណេះដឹងស្ដីពីការប្រែប្រួលអាកាសធាតុគឺជាកត្តាគន្លឹះមួយ ក្នុងការចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមទាំងនេះតាមបែបវិទ្យាសាស្ត្រ។

ជាទូទៅ ពាក្យបច្ចេកទេសពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុត្រូវបានប្រើប្រាស់ផ្សេងៗគ្នា ទៅតាមបរិបទខុសៗគ្នារបស់ក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងគ្រឹះស្ថានសិក្សា ដោយមិនទាន់មានការឯកភាពគ្នាជាលក្ខណៈប្រព័ន្ធឬជារួមក្នុងភាសាជាតិ ដែលប្រការនេះអាចនាំឱ្យមានការយល់ខុសៗគ្នាពីសំណាក់អ្នកប្រើប្រាស់ពីគ្រប់មជ្ឈដ្ឋាន។

ដោយមើលឃើញពីកង្វះខាតនេះ នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលជានាយកដ្ឋានបច្ចេកទេស បានខិតខំរៀបចំចងក្រង ត្រួតពិនិត្យ និងបោះពុម្ពផ្សាយ "**សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ**" ជាភាសាជាតិ ក្នុងគោលបំណងជួយសម្រួលដល់ការប្រើប្រាស់ពាក្យបច្ចេកទេសប្រែប្រួលអាកាសធាតុឱ្យបានត្រឹមត្រូវនិងឯកភាពគ្នា។

សៀវភៅនេះ ត្រូវបានចងក្រងឡើងដោយផ្អែកលើសទ្ទានុក្រមរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្ដីពីការប្រែប្រួលអាកាសធាតុ(IPCC) អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ(UNFCCC) និងស្ថាប័នអន្តរជាតិជំនាញផ្នែកប្រែប្រួលអាកាសធាតុមួយចំនួនទៀត។ ក្រៅពីនេះ ក្រុមការងារក៏បានប្រើប្រាស់ឯកសារជាតិដែលមានស្រាប់ ដូចជាវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមបច្ចេកសព្ទបរិស្ថានឆ្នាំ១៩៩៩ សទ្ទានុក្រមពាក្យបច្ចេកទេសប្រែប្រួលអាកាសធាតុឆ្នាំ២០១០ និងឯកសារពាក់ព័ន្ធមួយចំនួនទៀត។

ឯកសារនេះ មានការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ទៅតាមក្បួនភាសាខ្មែរ ដោយក្រុមប្រឹក្សាជាតិភាសាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធានាបាននូវសង្គតិភាព ឯកភាព និងភាពត្រឹមត្រូវក្នុងការប្រើប្រាស់។

សទ្ទានុក្រមនេះ គឺជាស្នាដៃថ្មីមួយទៀតសម្រាប់ជាវិភាគទានដ៏សំខាន់ដល់ការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំយល់ថា សៀវភៅនេះពុំទាន់អាចឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់បានទាំងស្រុងនៅឡើយទេ។ អាស្រ័យហេតុនេះ រាល់មតិកែលម្អនិងអនុសាសន៍របស់អ្នកអាននឹងធ្វើឱ្យឯកសារនេះ កាន់តែមានលក្ខណៈទូលំទូលាយនិងមានអត្ថន័យគ្រប់ជ្រុងជ្រោយក្នុងបរិបទប្រែប្រួលអាកាសធាតុនាពេលអនាគត។

ក្នុងនាមក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះថ្នាក់ដឹកនាំក្រសួងបរិស្ថាន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នាយកដ្ឋានប្រែប្រួលអាកាសធាតុ និងក្រុមការងារទាំងអស់ដែលបានខិតខំរៀបចំសៀវភៅដ៏មានសារៈសំខាន់នេះ។ ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាជាតិភាសាខ្មែរដែលបានសហការក្នុងការត្រួតពិនិត្យ កែតម្រូវ និងអនុម័តបច្ចេកសព្ទស្តីពីការប្រែប្រួលអាកាសធាតុនេះ៕

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

# អារម្ភកថា

*បច្ចេកសព្ទក្នុងវិស័យប្រែប្រួលអាកាសធាតុ* ជាពាក្យដែលស្តែងពីសញ្ញាណ បញ្ញត្តិ របាយការណ៍បច្ចេកទេស ក្នុងជំនាញប្រែប្រួលអាកាសធាតុ ហើយដែលមាននិយមន័យកំណត់ច្បាស់លាស់។

ការចងក្រងសទ្ទានុក្រមបច្ចេកសព្ទក្នុងវិស័យនេះមិនមែនទាមទារឱ្យមានត្រឹមតែការយល់ពីន័យរបស់បច្ចេកសព្ទប៉ុណ្ណោះទេ តែថែមទាំងទាមទារឱ្យមាននូវជំនាញផ្នែកភាសាវិទ្យានិងអក្សរសាស្ត្រទៀតផង ដើម្បីអាចតាក់តែងសេចក្តីពន្យល់ពីនិយមន័យនៃពាក្យនីមួយៗឱ្យបានច្បាស់លាស់និងឆ្លើយតបទៅនឹងបរិបទនៃការប្រើប្រាស់ពាក្យទាំងនោះផងដែរ។

ដោយឡែក សទ្ទានុក្រមបច្ចេកសព្ទដែលលោកអ្នកកំពុងកាន់អាននៅក្នុងដៃនាពេលនេះ ត្រូវបានចងក្រងឡើងដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋាន *ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព* ហើយបានដាក់ជូនក្រុមប្រឹក្សាជាតិភាសាខ្មែរពិនិត្យកែតម្រូវ អនុម័តទាំងមេពាក្យ ទាំងសេចក្តីពន្យល់ពីខ្លឹមសាររបស់វា ប្រកបដោយស្មារតីឯកភាពនិងទទួលខុសត្រូវខ្ពស់។

ទោះជាយ៉ាងនេះក្តី ក៏ការភាន់ច្រឡំអាចនឹងកើតមានឡើងជាយថាហេតុ។ ហេតុនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែររង់ចាំទទួលនូវមតិកែលម្អពីប្រិយមិត្តអ្នកអានដោយក្តីរីករាយបំផុត។

ក្រុមប្រឹក្សាជាតិភាសាខ្មែរ សូមថ្លែងអំណរគុណទុកជាមុននូវការចូលរួមកែតម្រូវពីសំណាក់មិត្តអ្នកអាន ហើយសង្ឃឹមថា សទ្ទានុក្រមនេះអាចជាឯកសារជំនួយស្មារតីដល់មហាជនទូទៅ ជាពិសេស ដល់អ្នកសិក្សាស្រាវជ្រាវក្នុងវិស័យប្រែប្រួលអាកាសធាតុនិងវិស័យពាក់ព័ន្ធ៕

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិនា ឆ្នាំ២០១៧

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**បណ្ឌិត ច័ន្ទ សំណាញ**

# សេចក្តីថ្លែងអំណរគុណ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងក្រសួងបរិស្ថាន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងពាក់ព័ន្ធនានា ស្ថាប័នជាតិ ដៃគូអភិវឌ្ឍអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំសេចក្តីព្រាងចុងក្រោយនៃសទ្ទានុក្រមនេះ។ សូមអរគុណជាពិសេសចំពោះឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាននិងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលបានផ្តល់ការណែនាំនិងការគាំទ្រយ៉ាងពេញទំហឹងនៅក្នុងកិច្ចការដ៏សំខាន់នេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ព្រមទាំងឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ បណ្ឌិត ជាសមាជិកសមាជិកានៃក្រុមប្រឹក្សាជាតិភាសាខ្មែរដែលបានខិតខំប្រឹងប្រែងត្រួតពិនិត្យនិងកែតម្រូវការប្រើប្រាស់ពាក្យពេចន៍និងអក្ខរាវិរុទ្ធឱ្យបានត្រឹមត្រូវតាមក្បួនភាសាខ្មែរនិងធ្វើឱ្យសទ្ទានុក្រមការប្រែប្រួលអាកាសធាតុនេះកាន់តែមានគុណភាពខ្ពស់។

សទ្ទានុក្រមនេះ ត្រូវបានរៀបរៀងឡើងក្រោមកិច្ចសម្របសម្រួលពីនាយកដ្ឋានប្រែប្រួលអាកាសធាតុ ដោយមានការចូលរួមយ៉ាងសកម្មពីមន្ត្រីបច្ចេកទេសនិងថ្នាក់ដឹកនាំនាយកដ្ឋាន មន្ត្រីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ព្រមទាំងមតិណែនាំដ៏មានតម្លៃពីថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងក្រសួងបរិស្ថាន។ ការចូលរួមយ៉ាងទូលំទូលាយរបស់អ្នកពាក់ព័ន្ធទាំងអស់បានធ្វើឱ្យសទ្ទានុក្រមនេះមានសង្គតិភាពនិងភាពច្បាស់លាស់ ដែលអាចជាប្រយោជន៍ដល់អ្នកអាន ជាពិសេសអ្នកសិក្សាស្រាវជ្រាវ ព្រមទាំងរួមចំណែកគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣។

ការចងក្រងនិងការបោះពុម្ពផ្សាយសទ្ទានុក្រមនេះអាចដំណើរការទៅបានដោយមានការគាំទ្រហិរញ្ញវត្ថុពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា(CCCA)ដែលទទួលមូលនិធិពីសហភាពអឺរ៉ុប(EU) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត(SIDA) ពីកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់

នឹងអាកាសធាតុ(SPCR)ដែលគាំទ្រថវិកាដោយមូលនិធិវិនិយោគអាកាសធាតុ(CIF) តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី(ADB) និងកម្មវិធីត្រៀមហិរញ្ញវត្ថុអាកាសធាតុរបស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់(GIZ)ដែលគាំទ្រថវិកាដោយទីភ្នាក់ងារសហរដ្ឋអាម៉េរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ(USAID)។

យើងសូមស្វាគមន៍ចំពោះការកែលម្អក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីធ្វើឱ្យសទ្ទានុក្រមនេះមានខ្លឹមសារគ្រប់ជ្រុងជ្រោយនិងច្បាស់លាស់។ សូមផ្ញើមតិរិះគន់ឬកែលម្អមកកាន់នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៦៣៣ ៨៣៧០ ឬសារអេឡិចត្រូនិច admin@camclimate.org.kh៕

សូមអរគុណ!

# របៀបប្រើប្រាស់សទ្ទានុក្រម

**សទ្ទានុក្រមបច្ចេកសព្ទស្ដីពីការប្រែប្រួលអាកាសធាតុ**នេះត្រូវបានរៀបចំឡើងដោយបែងចែកជាបីផ្នែកសំខាន់ៗ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកអាន ជាពិសេស ក្នុងការប្រើប្រាស់។

## ផ្នែកទី១ : បច្ចេកសព្ទនិងនិយមន័យ ខ្មែរ-អង់គ្លេស

អ្នកអាននឹងទទួលបានការពន្យល់ន័យនៃបច្ចេកសព្ទដែលមានប្រើប្រាស់ញឹកញាប់ក្នុងបរិបទការប្រែប្រួលអាកាសធាតុ។ បច្ចេកសព្ទទាំងអស់នៅក្នុងផ្នែកទី១នេះ ត្រូវបានរៀបចំតាមលំដាប់អក្ខរក្រមនៃអក្សរខ្មែរ។ របៀបរៀបចំនៅក្នុងផ្នែកទី១នេះមានដូចខាងក្រោម៖

- មេពាក្យត្រូវបានសរសេរជាអក្សរឈរនិងដិត អមដោយពាក្យសមមូលជាភាសាអង់គ្លេស។ មេពាក្យជាភាសាអង់គ្លេសដែលមានអក្សរសង្ខេបឬពាក្យបំប្រួញមានសរសេរក្នុងវង់ក្រចក។
- និយមន័យលម្អិតជាភាសាខ្មែរត្រូវបានរៀបរាប់នៅពីក្រោមមេពាក្យនីមួយៗ។
- សញ្ញា "/" មានន័យថាពាក្យទាំងពីរអាចប្រើជំនួសគ្នាទៅវិញទៅមកបាន។ ការប្រើដូចនេះ គឺដើម្បីរក្សាភាពដើមនៃបច្ចេកសព្ទជាភាសាអង់គ្លេស។ ឧទាហរណ៍ : ខ្សែគោល/យោង។
- មេពាក្យដែលប្រើក្នុងបរិបទពិសេសណាមួយឬបញ្ជាក់អត្ថន័យពេញលេញមានបញ្ជាក់បន្ថែមក្នុងវង់ក្រចក។ ឧទាហរណ៍ : ការបង្កើតឡើងវិញ(នៃអថេរអាកាសធាតុ)។
- ពាក្យដែលប្រើអក្សរ ***ពណ៌ខៀវ ទ្រេត និងដិត*** នៅក្នុងនិយមន័យ សម្គាល់ថាជាបច្ចេកសព្ទដែលមាននិយមន័យលម្អិតនៅក្នុងសទ្ទានុក្រមនេះ។

## ផ្នែកទី២ : បច្ចេកសព្ទ(អង់គ្លេស-ខ្មែរ)

មេពាក្យនីមួយៗត្រូវបានសរសេរជាអក្សរឈរនិងដិត ហើយរៀបតាមលំដាប់អក្ខរក្រមអង់គ្លេសពី A ដល់ Z អមដោយពាក្យសមមូលជាភាសាខ្មែរ។

## ផ្នែកទី៣ : អក្សរកាត់

- អក្សរកាត់នៅជួរឈរទី១រៀបតាមលំដាប់អក្ខរក្រមអង់គ្លេសពី A ដល់ Z អមដោយពាក្យជាភាសាអង់គ្លេសនៅជួរឈរទី២និងជាភាសាខ្មែរនៅជួរឈរទី៣។
- *ពាក្យជាអក្សរទ្រេតពណ៌ខៀវ* សម្គាល់ថាជាបច្ចេកសព្ទដែលមាននិយមន័យនៅក្នុងសទ្ទានុក្រមនេះ។
- ពាក្យជាអក្សរឈរ សម្គាល់ថាជាបច្ចេកសព្ទដែលមានប្រើប្រាស់ច្រើននៅក្នុងបរិបទប្រែប្រួលអាកាសធាតុ ប៉ុន្តែមិនបានបញ្ចូលនិយមន័យទៅក្នុងសទ្ទានុក្រមនេះទេ។
- អក្សរកាត់ជាភាសាខ្មែរដែលមានប្រើប្រាស់ជាផ្លូវការ ត្រូវបានដាក់ក្នុងវង់ក្រចក "()" នៅក្រោមអក្សរកាត់ជាភាសាអង់គ្លេស។

## ផ្នែកទី១

# បច្ចេកសព្ទនិងនិយមន័យ ខ្មែរ-អង់គ្លេស

# ក

**កម្ដៅតំបន់ទីក្រុង Urban Heat Island (UHI)**

កម្ដៅក្នុងតំបន់ទីក្រុងមួយ ធៀបទៅនឹងតំបន់ជនបទដែលនៅជុំវិញ ហើយបណ្ដាលមកពីសកម្មភាពមនុស្ស ការប្រែប្រួលលំហូរច្រោះ ការរាំងខ្ទប់ កម្ដៅមកពីព្រៃក្រាស់ ការប្រែប្រួលផ្ទៃអាល់បេដូ(Albedo) ការបំពុល និង*អាអេរ៉ូសូល (Aerosol)* ។ល។

**កម្ដៅភពផែនដី Global warming**

ការប្រែប្រួលសីតុណ្ហភាពខ្យល់លើផ្ទៃផែនដីហៅថា សីតុណ្ហភាពភពផែនដីដែលបានកើតឡើងដោយសារកំណើន*ផលផ្ទះកញ្ចក់* បង្កឡើងដោយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងខ្យល់។

**កម្ពស់ទឹកភ្លៀង Rainfall**

បរិមាណទឹកដែលធ្លាក់ចុះក្នុងទម្រង់ជាទឹកភ្លៀង ព្រឹល។ល។ ក្នុងរយៈពេលមួយនៅតំបន់ណាមួយ ដែលជាធម្មតា ស្ដែងចេញជាកម្ពស់ទឹកនៃស្ថានីយវាស់កម្ពស់ទឹកភ្លៀង។

**កម្ពស់រលកធំ Significant wave height (SWH)**

កម្ពស់មធ្យមរបស់រលកសមុទ្រស្មើនឹងមួយភាគបីនៃកម្ពស់រលកដែលខ្ពស់បំផុត( ពីផ្ទៃរហូតដល់កំពូល ) ចេញពីសមុទ្រនិងប៉ោងធំក្នុងរយៈពេលណាមួយ។

**កម្រិតចាប់ប្រែប្រួលអាកាសធាតុ Climate threshold**

ចំណុចដែល*កម្លាំងជំរុញពីខាងក្រៅ* នៃ*ប្រព័ន្ធអាកាសធាតុ* ដូចជា កំណើន*កំហាប់ឧស្ម័នផ្ទះកញ្ចក់* បង្កឱ្យមានព្រឹត្តិការណ៍អាកាសធាតុឬបរិស្ថានសំខាន់

ដែលមិនអាចកែសម្រួលឬស្តារឡើងវិញបានក្នុងរយៈពេលវែង ដូចជា ការរីកពាលដាលនៃផ្កាថ្មពណ៌សឬការផ្លាស់ប្តូរប្រព័ន្ធចរន្តមហាសមុទ្រ។

**កម្រិតអនុញ្ញាតបញ្ចេញឧស្ម័ន Emission permit**

ការកំណត់កម្រិតនៃការបញ្ចេញឧស្ម័ន(មិនអាចផ្ទេរ តែអាចធ្វើពាណិជ្ជកម្មបាន)ដោយអាជ្ញាធរមានសមត្ថកិច្ចដូចជា ស្ថាប័នអន្តររដ្ឋាភិបាល ស្ថាប័នថ្នាក់កណ្តាលឬមូលដ្ឋាន ទៅកាន់អង្គភាពថ្នាក់តំបន់(ប្រទេស ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ) ឬអង្គភាពតាមវិស័យ(ក្រុមហ៊ុន) ក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងបរិមាណជាក់លាក់មួយ។

**កម្លាំងវិកាយរស្មី Radiative forcing**

ការប្រែប្រួលដែលបានមកពីផលដករវាងចំណាំងកាំរស្មីចុះក្រោមនិងចំណាំងកាំរស្មីឡើងលើគិតជាវ៉ាត់ក្នុងមួយម៉ែត្រការ៉េ(w/m²)។

**កម្លាំងវិកាយរស្មីពពក Cloud radiative forcing**

ផលដករវាងលំនឹងថាមពលដែលបានមកពីចំណាំងវិកាយរស្មីនៃបរិយាកាសលើផែនដីនៅពេលផ្ទៃមេឃមានពពក ជាមួយនឹងលំនឹងថាមពលនៃចំណាំងវិកាយរស្មីក្នុងបរិយាកាសនៅពេលមេឃស្រឡះ ខ្នាតគិតជា w/m²។

**កម្លាំងជំរុញពីខាងក្រៅ External forcing**

ភ្នាក់ងារជំរុញពីក្រៅ*ប្រព័ន្ធអាកាសធាតុ*ដែលបណ្តាលឱ្យ*ប្រព័ន្ធអាកាសធាតុ*ប្រែប្រួល។

បន្ទុះភ្នំភ្លើង ការប្រែប្រួលកម្តៅព្រះអាទិត្យ ការប្រែប្រួលសមាសភាពបរិយាកាសដោយសារមនុស្ស និងការប្រែប្រួលការប្រើប្រាស់ដី គឺជាកម្លាំងជំរុញពីខាងក្រៅ។ កម្លាំងជំរុញតាមគន្លងព្រះអាទិត្យក៏ជាកម្លាំងជំរុញពីខាងក្រៅដែរ នៅពេលមានការប្រែប្រួលវិកាយរស្មីព្រះអាទិត្យជាមួយនឹងគន្លងព្រះអាទិត្យ ដំណើរទ្រេតនៃអ័ក្សផែនដី និងដំណើរនៃសមរាត្រី។

**កន្ទិបទឹកកក Ice cap**

ទឹកកកករាងជាសាជីគ្របដណ្តប់លើតំបន់ភ្នំ មានវិសាលភាពតូចជាង *ស្រទាប់ទឹកកក* យ៉ាងខ្លាំង។

**កសិធុរកិច្ច Agro-business/Agri-business**

ធុរកិច្ចខ្នាតធំដែលបម្រើឱ្យវិស័យកសិកម្ម រួមបញ្ចូលទាំងផលិតកម្ម ការកែច្នៃ ការវេចខ្ចប់ ការចែកចាយផលិតផលកសិកម្ម ការផលិតគ្រឿងយន្តកសិកម្ម ឧបករណ៍ គ្រឿងបរិក្ខារ សម្ភារៈផ្គត់ផ្គង់ និងផលិតកម្មកសិកម្មតាមកិច្ចសន្យា។

**កសិកម្មឆ្លាតខាងអាកាសធាតុ Climate-smart agriculture**

កសិកម្មដែលអាចបង្កើនផលិតភាពធន់ទៅនឹងអាកាសធាតុ កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ប្រកបដោយចីរភាព និងពង្រឹងការសម្រេចបាននូវសន្តិសុខស្បៀងនិងគោលដៅអភិវឌ្ឍន៍ជាតិ។

**កសិកម្មពឹងទឹកភ្លៀង Rainfed agriculture**

កសិកម្មដែលពឹងផ្អែកទាំងស្រុងលើទឹកភ្លៀងជាប្រភពទឹក។

**កសិកម្មអភិរក្ស Conservation agriculture**

កសិកម្មដែលប្រើវិធីសាស្ត្រដើម្បីគ្រប់គ្រងកសិប្រព័ន្ធអេកូឡូស៊ី សម្រាប់កែលម្អនិងរក្សាចីរភាពនៃផលិតភាពបង្កើនផលចំណេញនិង *សន្តិសុខស្បៀង* ដោយមានការថែរក្សានិងធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានធនធាននិងបរិស្ថាន។

កសិកម្មអភិរក្សផ្សារភ្ជាប់ដោយគោលការណ៍សំខាន់៣គឺ ការរំខានដីបែបមេកានិកជាបន្តបន្ទាប់ក្នុងកម្រិតអប្បបរមា គម្របដីសរីរាង្គអចិន្ត្រៃយ៍ និងពិពិធកម្មប្រភេទដំណាំនានាដែលបានដាំដុះតាមរដូវកាលនិង/ឬដំណាំពាក់ព័ន្ធ។

**កសិកម្មអតិផល Intensive Agriculture**

ប្រព័ន្ធកសិកម្មដែលផ្តល់ផលិតភាពខ្ពស់ក្នុងផ្ទៃក្រឡាមួយឯកតា។ ជាញឹកញាប់ ប្រព័ន្ធប្រពលវប្បកម្មកសិកម្មត្រូវការធនធានចូលខ្ពស់ ដែលពឹងផ្អែកលើគ្រឿងយន្ត ដី និងសារធាតុគីមីកសិកម្ម។

**កសិកម្មយថាផល Extensive agriculture or Extensive farming**

ការដាំដុះឬការចិញ្ចឹមសត្វ ដែលប្រើទុននិងពលកម្មតិច ហើយទទួលបានផលតាមលក្ខខណ្ឌធម្មជាតិ។

**កាបូនខ្មៅ Black carbon**

ប្រភេទ *អាអេរ៉ូសូល* ដែលត្រូវបានកំណត់ដោយផ្អែកលើរង្វាស់នៃការស្រូបពន្លឺនិងកម្រិតប្រតិកម្មគីមី និង/ឬភាពស៊ាប់នឹងកម្ដៅ។ ពេលខ្លះ កាបូនខ្មៅសំដៅដល់ម្រែងភ្លើង។

**កាបូនបម្រុង Carbon buffer**

បរិមាណ *ឥណទានកាបូន* ដែលត្រូវបានកំណត់ដោយផ្អែកលើការវិភាគហានិភ័យឬវិធាននៃស្តង់ដាមួយដែលត្រូវបានកំណត់ទុកដោយឡែកនិងហាមមិនឱ្យធ្វើពាណិជ្ជកម្ម ដើម្បីធានាសុពលភាពឥណទានកាបូនពីគម្រោងមួយពេលមានហេតុការណ៍ *ការលេចធ្លាយកាបូន* ឬភាពមិនអចិន្ត្រៃយ៍។

**ការកញ្ជ្រោលនៃព្យុះ Storm surge**

កំណើនបណ្ដោះអាសន្ននៃកម្រិតកម្ពស់(នីវ៉ូ)ទឹកសមុទ្រនៅកន្លែងណាមួយដោយសារលក្ខខណ្ឌឧតុនិយមមិនប្រក្រតី(សម្ពាធបរិយាកាសធាតុទាបនិង/ឬខ្យល់ខ្លាំង)។ ការកញ្ជ្រោលនៃព្យុះមានកម្រិតខ្ពស់លើសពីការរំពឹងទុកនៅពេលមានការប្រែប្រួលកម្លាំងទឹកជោរនៅទីកន្លែងនិងក្នុងពេលណាមួយ។

**ការកសាងសមត្ថភាព Capacity building**

ការអនុវត្តក្នុងការពង្រឹងភាពខ្លាំង លក្ខណសម្បត្តិ និងធនធានដែលមានចំពោះបុគ្គលម្នាក់ៗ សហគមន៍ ស្ថាប័នឬសង្គម ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល។

**ការកាត់បន្ថយ Mitigation**

អន្តរាគមន៍របស់មនុស្ស ដើម្បីឱ្យប្រភពបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថយចុះឬដើម្បីបង្កើន *អាងស្រូបឧស្ម័នផ្ទះកញ្ចក់* ។

**ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ Disaster Risk Reduction (DRR)**

ការចង្អុលបង្ហាញនូវគោលដៅនិងគោលបំណងផ្នែកគោលនយោបាយ វិធានការជាយុទ្ធសាស្ត្រ និងឧបករណ៍នានា ដែលបានប្រើប្រាស់ដើម្បីប៉ាន់ប្រមាណ*ហានិភ័យគ្រោះមហន្តរាយ* នាពេលអនាគត ដោយការកាត់បន្ថយការប្រឈម*មុខសញ្ញាគ្រោះថ្នាក់* ឬ*ភាពងាយរងគ្រោះ* ដែលកំពុងកើតមាននិងដោយការបង្កើនភាពធន់ទៅនឹងហានិភ័យទាំងនោះ។

**ការកាប់ឈើដោយកាត់បន្ថយផលប៉ះពាល់ Reduced Impact Logging (RIL)**

បច្ចេកទេសកាប់ឈើដែលបណ្តាលឱ្យព្រៃជុំវិញនិងប្រព័ន្ធអេកូឡូស៊ីព្រៃឈើខូចខាតតិចតួច។

**ការកំណត់បរិមាណ(បញ្ចេញឧស្ម័ន) Cap**

ការកំណត់ព្រំដែនដែលជាកាតព្វកិច្ចសម្រាប់បញ្ចេញឧស្ម័ននៅកម្រិតខ្ពស់បំផុត។

*ពិធីសារក្យូតូ* បានកំណត់ការបញ្ចេញ*ឧស្ម័នផ្ទះកញ្ចក់* ទៅតាមពេលវេលាពីសកម្មភាពមនុស្សនៅក្នុង*បណ្តាប្រទេសឧបសម្ព័ន្ធ B*។ ឧទាហរណ៍ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១២ សហភាពអឺរ៉ុបត្រូវកាត់បន្ថយការបញ្ចេញ*សមមូលឧស្ម័នកាបូនិក*នៃឧស្ម័នផ្ទះកញ្ចក់ចំនួន៦ប្រភេទ ឱ្យបានយ៉ាងតិច៥% ទាបជាងកម្រិតនៃការបញ្ចេញឧស្ម័ននៅឆ្នាំ១៩៩០។

**ការកំណត់បរិមាណនិងពាណិជ្ជកម្ម Cap and trade**

ប្រព័ន្ធគ្រប់គ្រងឬបទបញ្ញត្តិដែលកំណត់គោលដៅមួយសម្រាប់បញ្ចេញឧស្ម័ន ឬប្រើប្រាស់ធនធានធម្មជាតិ បន្ទាប់មក បែងចែក*កូតានៃការបញ្ចេញឧស្ម័ន* និងអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មទៅតាមតម្លៃរបស់វា។

**ការកំណត់ប៉ារ៉ាម៉ែត្រ Parameterization**

បច្ចេកទេសនៃការតាងបណ្តាលំនាំដែលមិនអាចស្រាយបំភ្លឺឱ្យច្បាស់លាស់បានក្នុងការដោះស្រាយជាទីកន្លែងឬពេលវេលានៃម៉ូដែលអាកាសធាតុ(លំនាំ

វិសាលភាពតូចៗ)ដោយមានទំនាក់ទំនងទៅនឹងលំនាំវិសាលភាពធំជាងពីម៉ូដែលបកស្រាយ និងផលប៉ះពាល់ទៅតាមតំបន់និងពេលវេលាជាមធ្យម។

**ការកំណត់ហានិភ័យអាកាសធាតុ Climate risk screening**

កិច្ចខិតខំប្រឹងប្រែងដើម្បីរកឱ្យឃើញច្បាស់នូវភាពងាយរងគ្រោះនិងហានិភ័យនានា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត ពាក់ព័ន្ធនឹង*ការប្រែប្រួលអាកាសធាតុ* ដែលជាបុរេលក្ខខណ្ឌសម្រាប់កំណត់និងដាក់ចេញវិធានការបន្សុំព្រមទាំងជាធាតុសំខាន់ក្នុងដំណើរការសមាហរណកម្មឬបញ្ជ្រាបការងារបន្សុំទៅក្នុងគម្រោងអភិវឌ្ឍន៍ និងដំណើរការរៀបចំផែនការនិងគោលនយោបាយ។

**ការគ្រប់គ្រងតាមបែបបន្សុំ Adaptive management**

ដំណើរការជាលក្ខណៈប្រព័ន្ធសម្រាប់កែលម្អជាបន្តបន្ទាប់នូវគោលនយោបាយគ្រប់គ្រងនិងការប្រតិបត្តិនានា តាមរយៈការរៀនសូត្រពីលទ្ធផលនៃការអនុវត្តគោលនយោបាយនិងការប្រតិបត្តិនានា កន្លងមក។

**ការគ្រប់គ្រងទេសភាពចម្រុះ Integrated landscape management**

ប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិ ដែលទទួលស្គាល់គុណតម្លៃរបស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីសម្រាប់អ្នកពាក់ព័ន្ធជាច្រើន និងរបៀបដែលនាំឱ្យអ្នកពាក់ព័ន្ធទាំងនោះប្រកាន់ខ្ជាប់នូវគោលដៅច្បាស់លាស់ក្នុងការប្រើប្រាស់ដីឬយុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិតផ្សេងៗគ្នា។

**ការគ្រប់គ្រងព្រៃឈើ Forest management**

ប្រព័ន្ធមួយនៃការប្រតិបត្តិសម្រាប់ការកាន់កាប់និងប្រើប្រាស់ដីព្រៃឈើក្នុងបំណងបំពេញមុខងារ*អេកូឡូស៊ី* (រួមទាំងនានាភាពជីវសាស្ត្រ) សេដ្ឋកិច្ច និងសង្គមរបស់ព្រៃឈើប្រកបដោយចីរភាព។

**ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ Disaster Risk Management (DRM)**

ដំណើរការបង្កើត អនុវត្ត និងវាយតម្លៃយុទ្ធសាស្ត្រ គោលនយោបាយ និងវិធានការ ដើម្បីបង្កើនការយល់ដឹងអំពី *ហានិភ័យគ្រោះមហន្តរាយ* ពង្រឹង *ការកាត់បន្ថយ* និង *ការផ្ទេរហានិភ័យគ្រោះមហន្តរាយ* ព្រមទាំងលើកកម្ពស់ការកែលម្អជាបន្តបន្ទាប់នូវការត្រៀមបង្ការគ្រោះមហន្តរាយ ការឆ្លើយតប និងការស្តារឡើងវិញ ក្នុងបំណងបង្កើនសន្តិសុខ សុខុមាលភាព គុណភាពនៃការរស់នៅ និង *ការអភិវឌ្ឍប្រកបដោយចីរភាព*។

**ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយតាមបែបកែតម្រូវ Corrective disaster risk management**

សកម្មភាពគ្រប់គ្រងនានាដែលដោះស្រាយនិងស្វែងរកការកែតម្រូវឬកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលអាចកើតមានឡើង។

**ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋាន Local Disaster Risk Management (LDRM)**

ដំណើរការដែលតួអង្គនៅមូលដ្ឋាន(ប្រជាជន សហគមន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការមិនស្វែងរកប្រាក់ចំណេញ ស្ថាប័ន និងផ្នែកធុរកិច្ច) ចូលរួមនិងមានភាពជាម្ចាស់ក្នុងការកំណត់ វិភាគ វាយតម្លៃ តាមដាន និងដោះស្រាយ *ហានិភ័យគ្រោះមហន្តរាយ* និងគ្រោះមហន្តរាយ តាមរយៈវិធានការនានាដែលអាចកាត់បន្ថយ ឬប្រមើលមើល *មុខសញ្ញាគ្រោះថ្នាក់* *ភាពប្រឈម* ឬ *ភាពងាយរងគ្រោះ* ផ្ទេរហានិភ័យ លើកកម្ពស់ការឆ្លើយតបនិងស្តារគ្រោះមហន្តរាយ ព្រមទាំងបង្កើនសមត្ថភាពទូទៅ។

ជាទូទៅ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋាន តម្រូវឱ្យមានការសម្របសម្រួល/ការគាំទ្រពីតួអង្គខាងក្រៅនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយថ្នាក់សហគមន៍កើតឡើងបន្ទាប់ពីមាន

ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋាន គឺនៅពេលដែលសមាជិកសហគមន៍និងអង្គការនានាបានមូលមតិធ្វើសេចក្តីសម្រេចចិត្តរួម។

**ការគ្រប់គ្រងហានិភ័យអាកាសធាតុ Climate risk management**

វិធីសាស្ត្រដើម្បីឈានដល់ការសម្រេចចិត្តដោះស្រាយភាពរួសអាកាសធាតុ ដោយព្យាយាមលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈការកាត់បន្ថយភាពងាយរងគ្រោះដែលពាក់ព័ន្ធនឹងហានិភ័យអាកាសធាតុ រួមបញ្ចូលនូវយុទ្ធសាស្ត្រនានា សំដៅបង្កើនលទ្ធផលវិជ្ជមានជាអតិបរមា និងបន្ថយលទ្ធផលអវិជ្ជមានឱ្យដល់កម្រិតអប្បបរមា សម្រាប់សហគមន៍ ទៅតាមវិស័យ ដូចជា កសិកម្ម សន្តិសុខស្បៀង ធនធានទឹក សុខាភិបាល ជាដើម។

**ការចេញលិខិតបញ្ជា Issuance**

សេចក្តីណែនាំរបស់ក្រុមប្រឹក្សាភិបាលទៅកាន់អ្នកគ្រប់គ្រង *ការចុះបញ្ជីគម្រោងយន្តការអភិវឌ្ឍន៍ស្អាត* ឱ្យចេញការបញ្ជាក់បរិមាណជាក់លាក់នៃការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់(CERs) ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបានបញ្ជាក់រយៈពេលវែង(LCERs) ឬការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបានបញ្ជាក់បណ្តោះអាសន្ន(TCERs) សម្រាប់សកម្មភាពតាមគម្រោង ឬសកម្មភាពតាមកម្មវិធី តាមដែលអាចអនុវត្តបាន ចូលទៅក្នុងគណនីរង់ចាំរបស់ក្រុមប្រឹក្សាភិបាលនៅក្នុង *បញ្ជីគម្រោងយន្តការអភិវឌ្ឍន៍ស្អាត* សម្រាប់ចែកចាយបន្តទៅកាន់គណនីអ្នកចូលរួមគម្រោង ស្របតាមវិធាននិងលក្ខខណ្ឌតម្រូវរបស់ *យន្តការអភិវឌ្ឍន៍ស្អាត*។

**ការចេញវិញ្ញាបនបត្រ Certification**

ការអះអាងជាលាយលក្ខណ៍អក្សរដែលចេញដោយ *អង្គភាពទទួលបន្ទុកប្រតិបត្តិ* ក្នុងកំលុងពេលមួយជាក់លាក់ ដែលបានផ្ទៀងផ្ទាត់ថា សកម្មភាពគម្រោង *យន្តការអភិវឌ្ឍន៍ស្អាត* បានសម្រេចការកាត់បន្ថយការបញ្ចេញ *ឧស្ម័នផ្ទះកញ្ចក់* ដោយសកម្មភាពផ្សេងៗរបស់មនុស្ស។

**ការចុះបញ្ជីគម្រោងយន្តការអភិវឌ្ឍន៍ស្អាត CDM registry**

ប្រព័ន្ធទិន្នន័យអេឡិចត្រូនិចដែលកត់ត្រាការចេញលិខិតបញ្ជាក់និងការបែងចែក*ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបានបញ្ជាក់* ដល់អ្នកចូលរួមអនុវត្តគម្រោង។ ប្រព័ន្ធចុះបញ្ជីគម្រោងយន្តការអភិវឌ្ឍន៍ស្អាត ត្រូវបានរក្សាទុកដោយលេខាធិការដ្ឋានយន្តការអភិវឌ្ឍន៍ស្អាត ហើយភ្ជាប់ទៅនឹងបញ្ជីថ្នាក់ជាតិនៃ*បណ្តាប្រទេសក្នុងឧបសម្ព័ន្ធ១* តាមរយៈប្រព័ន្ធចុះបញ្ជីប្រតិបត្តិការអន្តរជាតិ (International Transaction Log: ITL)។

**ការដកដង្ហើម Respiration**

ដំណើរការស្រូបយកអុកស៊ីសែនដោយសារពាង្គកាយរស់ដើម្បីបំប្លែងសារធាតុសរីរាង្គឱ្យទៅជាថាមពលនិងឧស្ម័នកាបូនិកដែលត្រូវបញ្ចេញចោល។

**ការដកដង្ហើមនៃភាវៈបរជីព Heterotrophic respiration**

ដំណើរបំប្លែងសារធាតុសរីរាង្គទៅជាឧស្ម័នកាបូនិក ដោយសារពាង្គកាយនានា(ក្រៅពីរុក្ខជាតិ)។

**ការដកដង្ហើមនៃភាវៈស្វយ័ជីព Autotrophic respiration**

ការបំប្លែងសារធាតុអសរីរាង្គតាមរស្មីសំយោគនៅពេលថ្ងៃនិងការស្រូបយកអុកស៊ីសែនដោយបញ្ចេញឧស្ម័នកាបូនិកនៅពេលយប់របស់សារពាង្គកាយរុក្ខជាតិ។

**ការដឹកជញ្ជូនបៃតង Green transport**

ហេដ្ឋារចនាសម្ព័ន្ធនិងមធ្យោបាយដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ទូរគមនាគមន៍ និងបណ្តាញថាមពលអគ្គិសនី ដែលជួយលើកកម្ពស់បរិស្ថានបៃតង ដូចជា អយស្ម័យយាន រថយន្តក្រុងដឹកអ្នកដំណើរ ផ្លូវនាវាចរណ៍ បណ្តាញខ្សែកាបអុបទិក ប្រព័ន្ធផ្គាយរណប និងបណ្តាញខ្សែបញ្ជូនអគ្គិសនី។

**ការដាំព្រៃឈើ Afforestation**

ការដាំដើមឈើដើម្បីបង្កើត*ព្រៃឈើ* នៅលើផ្ទៃដីដែលមានប្រវត្តិគ្មានដើមឈើពីមុន(រយៈពេលយ៉ាងហោចណាស់៥០ឆ្នាំ)។

**ការឆ្លើយតប Coping**

ការប្រើប្រាស់ជំនាញ ធនធាន និងឱកាសដែលមាន ដើម្បីដោះស្រាយ គ្រប់គ្រង និងជម្នះរាល់បញ្ហាអវិជ្ជមាន ក្នុងគោលបំណងធានាឱ្យមានដំណើរការជាមូលដ្ឋាននៅក្នុងរយៈពេលខ្លីឬមធ្យម។

**ការទទួលខុសត្រូវរួម តែមានកម្រិតផ្សេងគ្នា Common but differentiated responsibilities**

អាទិភាពនិងការប្តេជ្ញាចិត្តមិនស្មើគ្នារវាងប្រទេសឧស្សាហកម្មនិងប្រទេសកំពុងអភិវឌ្ឍក្នុងឧបសម្ព័ន្ធ១នៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ* ពោលគឺប្រទេសកំពុងអភិវឌ្ឍត្រូវទទួលខុសត្រូវក្នុងការអភិវឌ្ឍប្រកបដោយចីរភាពនិងចាត់វិធានការបន្សាំទៅនឹងឥទ្ធិពលនៃ*ការប្រែប្រួលអាកាសធាតុ* ហើយប្រទេសអភិវឌ្ឍន៍ត្រូវប្តេជ្ញាចិត្តកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ខ្លួន ស្របតាមគោលដៅនៃការកាត់បន្ថយនិងរយៈពេលដូចមានចែងក្នុងមាត្រា៤.២ នៃ*ពិធីសារក្យូតូ*។

**ការទប់នឹងអាកាសធាតុ Climate proofing**

សកម្មភាពឬវិធីសាស្ត្រដើម្បីធានាថាហានិភ័យអាកាសធាតុត្រូវបានកាត់បន្ថយដល់កម្រិតមួយអាចទទួលយកបានតាមរយៈការផ្លាស់ប្តូរដែលអាចទទួលយកបានពីសង្គម សេដ្ឋកិច្ច និងបរិស្ថានក្នុងរយៈពេលយូរ និងអាចអនុវត្តក្នុងដំណាក់កាលមួយឬច្រើននៃវដ្តគម្រោង។

**ការទប់ស្កាត់ Prevention**

ការបញ្ចៀសផលប៉ះពាល់ធ្ងន់ធ្ងរនៃ*មុខសញ្ញាគ្រោះថ្នាក់* និងគ្រោះមហន្តរាយនានាដែលពាក់ព័ន្ធ។

**ការទស្សន៍ទាយអាកាសធាតុ/ទំនាយអាកាសធាតុ Climate prediction**

លទ្ធផលនៃការប៉ាន់ស្មានអំពីការវិវត្តអាកាសធាតុជាក់ស្តែងនៅពេលអនាគត (តាមរដូវកាល តាមឆ្នាំឬតាមរយៈពេលវែង) ហើយលទ្ធផលនេះមានលក្ខណៈ

ប្រហាក់ប្រហែលដោយផ្អែកលើការវិវត្តនៃប្រព័ន្ធអាកាសធាតុ នាពេលអនាគត ស្របតាមភាពរួសខ្ពស់នៃលក្ខខណ្ឌដើមមួយចំនួន។

**ការទូទាត់សេវាកម្មបរិស្ថាន Payment for Environmental services (PES)**

ឧបករណ៍សេដ្ឋកិច្ចមួយដែលរៀបចំឡើងសំដៅលើកទឹកចិត្តដល់អ្នកប្រើប្រាស់ដីកសិកម្មនិងអ្នកពាក់ព័ន្ធនឹងការងារគ្រប់គ្រងតំបន់ឆ្នេរឬសមុទ្រ ហើយការលើកទឹកចិត្តនេះនឹងធ្វើឱ្យការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីកាន់តែប្រសើរឡើង និងមានដំណើរការជាបន្តបន្ទាប់ដែលអាចផ្តល់អត្ថប្រយោជន៍ត្រឡប់ទៅដល់សង្គមទាំងមូល។

**ការទូទាត់សេវាកម្មប្រព័ន្ធអេកូឡូស៊ី Payment for Ecosystem services (PES)**

ការថៃទាំលំហូរសេវាកម្មប្រព័ន្ធអេកូឡូស៊ីជាក់លាក់មួយ ដូចជាទឹកស្អាត ជម្រកជីវៈចម្រុះ ឬសមត្ថភាពស្រូបយកកាបូនជាការដោះដូរទៅនឹងអ្វីមួយក្នុងតម្លៃសេដ្ឋកិច្ច។

**ការធ្លាក់ចុះ Subduction**

ដំណើរការនៅក្នុងមហាសមុទ្រ ដែលទឹកស្រទាប់លើហូរចូលទៅស្រទាប់ខាងក្នុងនៃមហាសមុទ្រ តាមរយៈ*ការបូមអែកមេន* និង*បន្ទេរកម្តៅតាមខ្សែរដេក*ពីចំហៀង។ ក្រោយមក ដំណើរការនេះកើតឡើងនៅពេលទឹកស្រទាប់លើបានផ្លាស់ទីតាមខ្សែរដេកទៅតំបន់ដែលមានដង់ស៊ីតេទាប ជាហេតុធ្វើឱ្យហូរចូលទៅខាងក្រោមទឹកស្រទាប់លើដោយគ្មានការប្រែប្រួលដង់ស៊ីតេ។

**ការធ្វើពាណិជ្ជកម្មការបញ្ចេញឧស្ម័ន Emission trading**

វិធីសាស្ត្របែបទីផ្សារ ដើម្បីសម្រេចគោលដៅបរិស្ថានឱ្យមានការប្រើប្រាស់ ឬធ្វើពាណិជ្ជកម្មបរិមាណឧស្ម័នផ្ទះកញ្ចក់ដែលលើស ហើយត្រូវកាត់បន្ថយ ឬបរិមាណឧស្ម័នផ្ទះកញ្ចក់ដែលបញ្ចេញទាបជាងគោលដៅកំណត់ដោយទូទាត់ជាមួយការបញ្ចេញពីប្រភពដទៃទៀតនៅក្នុងប្រទេស ឬក្រៅប្រទេស។

សម្គាល់៖ ជាទូទៅ ពាណិជ្ជកម្មកាបូនអាចធ្វើបានទាំងក្រុមហ៊ុនក្នុងស្រុកនិងអន្តរជាតិ។ របាយការណ៍វាយតម្លៃលើកទីពីររបស់*ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ* បានអនុម័តឱ្យប្រើប្រាស់ពាក្យ "ការអនុញ្ញាត" សម្រាប់ប្រព័ន្ធពាណិជ្ជកម្មក្នុងប្រទេស និង "កូតា" សម្រាប់ប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ។ ការធ្វើពាណិជ្ជកម្មការបញ្ចេញឧស្ម័នក្នុងមាត្រា១៧នៃ*ពិធីសារក្យូតូ* គឺជាប្រព័ន្ធកូតាដែលអាចធ្វើពាណិជ្ជកម្មបាន ដោយផ្អែកលើបរិមាណកំណត់ដែលបានពីការគណនាបរិមាណកាត់បន្ថយឧស្ម័ននិងការប្តេជ្ញាចិត្ត ដូចមានចែងនៅក្នុងឧបសម្ព័ន្ធBនៃពិធីសារនេះ។

**ការបង្កើតជីជាតិដោយឧស្ម័នកាបូនិក Carbon dioxide ($CO_2$) fertilization**

កំណើននៃការលូតលាស់របស់រុក្ខជាតិ ដែលជាលទ្ធផលបានមកពីការកើនឡើងនៃកំហាប់ *ឧស្ម័នកាបូនិក* ក្នុង *បរិយាកាស* ។

**ការបង្កើតឡើងវិញ(នៃអថេរអាកាសធាតុ) Reconstruction (of climate variable)**

វិធីសាស្ត្រដើម្បីបង្កើតឡើងវិញនូវទិន្នន័យនៃអថេរអាកាសធាតុទៅតាមលក្ខណៈសម្គាល់នៃពេលវេលានិងទីកន្លែងពីអតីតកាលដែលបានមកពីឧបករណ៍ទស្សន៍ទាយ។

ឧបករណ៍ទស្សន៍ទាយនេះអាចជាទិន្នន័យកត់ត្រា ប្រសិនបើការបង្កើតឡើងវិញត្រូវបានប្រើប្រាស់ ដើម្បីបំពេញទិន្នន័យដែលនៅខ្វះចន្លោះ ឬអាចជាទិន្នន័យជំនួសប្រសិនបើការបង្កើតឡើងវិញត្រូវបានយកទៅប្រើប្រាស់ ដើម្បីបង្កើតអាកាសធាតុនៃបុរាណកាលឡើងវិញ។ ក្នុងគោលបំណងនេះ បច្ចេកទេសខុសៗគ្នាត្រូវបានបង្កើតឡើង ដូចជា វិធីសាស្ត្រដោយផ្អែកលើសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ(រេក្រេស្យុងពហុអថេរលីនេអ៊ែ) វិធីសាស្ត្របាយ៉េសមិនលីនេអ៊ែ និងវិធីសាស្ត្រប្រដូច(វិធីសាស្ត្រអាណាឡូក)។

**ការបង្កើនការដាំដុះ Enrichment planting**

ដំណើរការដាំដើមឈើ ដើម្បីបង្កើនដង់ស៊ីតេប្រភេទឈើដែលមានស្រាប់ ឬបង្កើនភាពសម្បូរបែបនៃប្រភេទឈើតាមរយៈការដាំប្រភេទឈើបន្ថែមនៅក្នុងព្រៃរេចរឹល។

**ការបង្កើនការបង្ខាំងកាបូន Carbon stock enhancement**

ផ្នែកមួយនៃយុទ្ធសាស្ត្ររេដបូក(REDD$^{+}$) ដែលអាចបញ្ចូលទាំងការស្តារទាំងការកែលម្អព្រៃឈើដែលមានស្រាប់តែរេចរឹល និងទាំងការបង្កើនគម្របព្រៃឈើតាមរយៈ*ការដាំ* និង*ការស្តារព្រៃឈើឡើងវិញ* សមស្របនឹងបរិស្ថាន។

**ការបង្កើនឧស្ម័នកាបូនិកក្នុងបរិយាកាស Free air carbon dioxide enrichment**

វិធីសាស្ត្រនិងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ពិសោធដែលប្រើដោយអ្នកឯកទេសបរិស្ថាននិងរុក្ខវិទ្យា ដើម្បីបង្កើនកំហាប់ឧស្ម័នក្នុងបរិយាកាសនៃតំបន់ផ្សេងៗតាមរយៈការគ្រប់គ្រងបរិមាណ *ឧស្ម័នកាបូនិក* ដោយមិនប្រើប្រាស់វត្ថុបិទបាំងឬជញ្ជាំង ដែលអាចឱ្យវាស់វែងនូវការលូតលាស់របស់រុក្ខជាតិបាន។

**ការបញ្ចេញឧស្ម័ន Emission**

ការបញ្ចេញ *ឧស្ម័នផ្ទះកញ្ចក់* និង/ឬបុរេករនិង*អាអេរ៉ូសូល*ទៅក្នុង*បរិយាកាស* នៅក្នុងតំបន់ណាមួយ និងក្នុងកំលុងពេលកំណត់មួយ។

**ការបញ្ចេញឧស្ម័នកាបូនិកអវិជ្ជមាន Negative carbon dioxide emission**

ដំណើរការស្រូបយកចេញពីបរិយាកាសជាអចិន្ត្រៃយ៍នូវឧស្ម័នផ្ទះកញ្ចក់ក្នុងសណ្ឋានអវិជ្ជមាននៃកាបូន ដោយព្រៃឈើនិងវិស័យផ្សេងទៀតលើមូលដ្ឋាននៃកាបូនសមមូល។

**ការបញ្ចេញឧស្ម័នដោយប្រយោល Indirect emission**

ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយសារការប្រើប្រាស់ចរន្តអគ្គិសនីនៅក្នុងអគារលំនៅឋាន ឬអាជីវកម្មនានា ហើយចរន្តអគ្គិសនីនោះបានមកពីរោងចក្រអគ្គិសនីដែលជាប្រភពនៃការបញ្ចេញឧស្ម័នដោយផ្ទាល់។

**ការបញ្ចេញឧស្ម័នដោយសកម្មភាពមនុស្ស** **Anthropogenic emission**

*ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ សារធាតុបង្កជាឧស្ម័នផ្ទះកញ្ចក់* និង *អាអេរ៉ូសូល* ដែលពាក់ព័ន្ធនឹងសកម្មភាពមនុស្ស ដូចជា ការដុតឥន្ធនៈហ្វូស៊ីល *ការបាត់បង់ព្រៃឈើ* ការប្រែប្រួលការប្រើប្រាស់ដី ផលិតកម្មសត្វ ការប្រើប្រាស់ជី ការគ្រប់គ្រងសំណល់ និងដំណើរការឧស្សាហកម្ម។

**ការបញ្ចេញឧស្ម័នពីឥន្ធនៈហ្វូស៊ីល** **Fossil fuel emission**

ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ពិសេស *ឧស្ម័នកាបូនិក* ពីចំហេះឥន្ធនៈដែលបានពីកំណកកាបូនហ្វូស៊ីល ដូចជា ប្រេងឧស្ម័នធម្មជាតិ ធ្យូងថ្ម ជាដើម។

**ការបញ្ជ្រាប** **Mainstreaming**

ការដាក់បញ្ចូលវិធានការបន្សាំនិងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ សមស្របនានាទៅក្នុងគោលនយោបាយ ច្បាប់ បទបញ្ញត្តិ ផែនការ កម្មវិធី សកម្មភាព ឬទម្លាប់ប្រតិបត្តិនានា ដោយពិចារណាលើសក្ដានុពលនៃ *ផលប៉ះពាល់* ដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ។

**ការប្រមូលផ្ដុំទិន្នន័យអាកាសធាតុ** **Climate data aggregation**

ដំណើរការប្រមូលផ្ដុំនិងបង្ហាញព័ត៌មានអាកាសធាតុជាទម្រង់សង្ខេបសម្រាប់គោលបំណងផ្សេងៗ ដូចជា វិភាគស្ថិតិអាកាសធាតុ ជាដើម។

**ការបាត់បង់ព្រៃឈើ** **Deforestation**

ការប្រែក្លាយពីស្ថានភាពមាន *ព្រៃឈើ* ទៅជាគ្មានព្រៃឈើ។

**ការបាត់បង់ព្រៃឈើតំបន់ជួរមុខ** **Frontier deforestation**

ការបាត់បង់ព្រៃឈើដែលត្រូវបានព្យាករថានឹងកើតមានឡើងនៅកន្លែងណាមួយក្នុងកំលុងពេលទទួលបានឥណទានគម្រោងនៅក្នុងតំបន់មានអត្រាបាត់បង់ព្រៃឈើទាបជាប្រវត្តិសាស្ត្រ តែតំបន់នោះអាចនឹងមានសក្ដានុពលសម្រាប់ការទន្ទ្រាន ការសាងសង់លំនៅឋាន និង/ឬការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត។

**ការបំប្រួញមាត្រដ្ឋាន Downscaling**

វិធីសាស្ត្រមួយដែលទទួលបានព័ត៌មានមាត្រដ្ឋានកម្រិតមូលដ្ឋាន ដល់មាត្រដ្ឋានកម្រិតតំបន់(១០ទៅ១០០គីឡូម៉ែត្រ) ដោយទាញចេញពីម៉ូដែល ឬការវិភាគទិន្នន័យមាត្រដ្ឋានធំជាង។

វិធីបំប្រួញមាត្រដ្ឋានមានពីរខុសគ្នា៖ ការបំប្រួញមាត្រដ្ឋានឌីណាមិក និងការបំប្រួញមាត្រដ្ឋានតាមការសង្កេត/ស្ថិតិ។ វិធីឌីណាមិកប្រើប្រាស់លទ្ធផលម៉ូដែលអាកាសធាតុកម្រិតតំបន់ និងម៉ូដែលកម្រិតពិភពលោកដែលផ្តល់រូបភាព ទីកន្លែងច្បាស់។ វិធីតាមការសង្កេត/ស្ថិតិបង្កើតទំនាក់ទំនងស្ថិតិដែលតភ្ជាប់អថេរបរិយាកាសមាត្រដ្ឋានធំ ទៅនឹងអថេរអាកាសធាតុកម្រិតមូលដ្ឋាន/តំបន់។ គ្រប់ករណីទាំងអស់នៃព័ត៌មានដែលបានពីការបំប្រួញមាត្រដ្ឋាន អាស្រ័យលើគុណភាពម៉ូដែលដែលបានប្រើប្រាស់ ហើយគុណភាពម៉ូដែលអាស្រ័យលើគុណភាពព័ត៌មាននៃការបំប្រួញមាត្រដ្ឋាននេះដែរ។

**ការបំពុលពីប្រភពច្បាស់លាស់ Point-source pollution**

ការបំពុលចេញពីប្រភពនានានៅនឹងកន្លែង ដូចជា ស្ថានីយប្រព្រឹត្តិកម្មសំណល់រាវ ស្ថានីយថាមពល តំបន់ឧស្សាហកម្មផ្សេងៗ និងពីប្រភពផ្សេងទៀត ដូចជា បំពង់លូ ប្រឡាយ ការដឹកជញ្ជូន រណ្តៅអាជីវកម្មរ៉ែ បំពង់ផ្សែង ជាដើម។

**ការបំពុលពីប្រភពមិនច្បាស់លាស់ Non-point-source pollution**

ការបំពុលចេញពីប្រភពនានា ដែលមិនអាចកំណត់ចំណុចច្បាស់លាស់ ដូចជា តំបន់ផលិតកម្មដំណាំ អាជីវកម្ម ព្រៃឈើ អាជីវកម្មរ៉ែ ការបោះចោលសំរាម ការសាងសង់ ជាដើម។

**ការប្តូរឥន្ធនៈ Fuel switching**

ការជំនួសឥន្ធនៈដែលមានជាតុស្ពាន់ធ័រកម្រិតខ្ពស់ដោយស្ពាន់ធ័រកម្រិតទាប ដែលជាវិធីមួយក្នុងចំណោមវិធីដែលងាយស្រួលបំផុតក្នុងការគ្រប់គ្រងការបញ្ចេញឧស្ម័នអាស៊ីត។

ការប្ដូរផន្ទុះដែលនិយមជាងគេ គឺការជំនួសធ្យូងថ្មដែលមានស្ពាន់ធ័រកម្រិតខ្ពស់ដោយធ្យូងថ្មដែលមានស្ពាន់ធ័រកម្រិតទាប។ ធ្យូងថ្មក៏អាចជំនួសទាំងស្រុងដោយប្រេង ឬឧស្ម័នធម្មជាតិផងដែរ។

## ការប្រែប្រួលនីវ៉ូទឹកសមុទ្រ Sea level change

ការកើនឡើងឬការថយចុះនូវនីវ៉ូទឹកសមុទ្រទាំងនៅកម្រិតសកល ទាំងនៅតាមតំបន់ ដោយសារតែ (១) ការប្រែប្រួលសណ្ឋានផ្ទៃមហាសមុទ្រ (២) ការប្រែប្រួលមាឌមហាសមុទ្រដែលបណ្ដាលមកពីការប្រែប្រួលម៉ាសទឹកនៅក្នុងមហាសមុទ្រ និង(៣) ការប្រែប្រួលមាឌមហាសមុទ្របណ្ដាលមកពីការប្រែប្រួលដង់ស៊ីតេទឹក។

ការប្រែប្រួលនីវ៉ូទឹកសមុទ្រមធ្យមសកលកើតចេញពីការប្រែប្រួលម៉ាសទឹកក្នុងមហាសមុទ្រហៅថា បារីស្តាទិក(barystatic)។ ទំហំនៃការប្រែប្រួលនីវ៉ូទឹកសមុទ្រតាមលក្ខខណ្ឌបារីស្តាទិក អាស្រ័យលើការកើនឡើងឬការថយចុះម៉ាសទឹកហៅថា សមមូលនីវ៉ូទឹកសមុទ្រ(SLE)។

ការប្រែប្រួលនីវ៉ូទឹកសមុទ្រនៅកម្រិតសកលនិងតំបន់ បណ្ដាលមកពីការប្រែប្រួលដង់ស៊ីតេទឹកហៅថា ស្តេរិក(steric)។ការប្រែប្រួលដង់ស៊ីតេដែលបណ្ដាលមកពីការប្រែប្រួលសីតុណ្ហភាពហៅថា ទែម៉ូស្តេរិក(thermosteric) ឯការប្រែប្រួលដង់ស៊ីតេដែលបណ្ដាលមកពីការប្រែប្រួលកម្រិតជាតិប្រៃហៅថា ហាឡូស្តេរិក (halosteric)។

## ការប្រែប្រួលអាកាសធាតុ Climate change

ការប្រែប្រួលស្ថានភាពអាកាសធាតុដែលអាចកំណត់អត្តសញ្ញាណបាន(តាមរយៈការវិភាគស្ថិតិ)តាមរយៈការប្រែប្រួលតួលេខមធ្យមនិងតួលេខអថេរនៃអាកាសធាតុ ហើយការប្រែប្រួលនោះបន្តកើតឡើងក្នុងរយៈពេលវែងជាច្រើនទសវត្សរ៍ឬយូរជាងនេះ។

ការប្រែប្រួលអាកាសធាតុអាចបណ្តាលមកពីដំណើរផ្ទៃក្នុងរបស់ធម្មជាតិ *កម្លាំងជំរុញពីខាងក្រៅ* ការប្រែប្រួលរយៈពេលវែងនៃសមាសភាពបរិយាកាសឬសកម្មភាពមនុស្សដូចជា ការប្រើប្រាស់ដី ការបញ្ចេញឧស្ម័នពីរោងចក្រ ជាដើម។ ក្នុងមាត្រា១នៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ* បានឱ្យនិយមន័យការប្រែប្រួលអាកាសធាតុជា "ការប្រែប្រួលអាកាសធាតុដែលជាប់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសកម្មភាពមនុស្ស ដែលធ្វើឱ្យផ្លាស់ប្តូរសមាសភាពបរិយាកាសពិភពលោក និងការបន្ថែមលើការប្រែប្រួលអាកាសធាតុដោយសារធម្មជាតិ ដែលសង្កេតឃើញក្នុងរយៈពេលប្រហាក់ប្រហែលគ្នា"។ អនុសញ្ញានេះបញ្ជាក់ពីភាពខុសគ្នារវាងការប្រែប្រួលអាកាសធាតុពីសកម្មភាពមនុស្ស ដែលបណ្តាលឱ្យផ្លាស់ប្តូរសមាសភាពបរិយាកាសនិងអថេរអាកាសធាតុពីធម្មជាតិ។

**ការប្រែប្រួលអាកាសធាតុហួសពីការរំពឹងទុក Abrupt climate change**

ការប្រែប្រួលទ្រង់ទ្រាយធំនៅក្នុង*ប្រព័ន្ធអាកាសធាតុ* ដែលកើតឡើងក្នុងរយៈពេលពីរឬបីទសវត្សរ៍ ឬតិចជាងនេះ និងនៅតែបន្តកើតមានឬមានការប្រមើលឃើញថានៅតែបន្តកើតឡើងយ៉ាងហោចណាស់ក្នុងរយៈពេលពីរឬបីទសវត្សរ៍ ហើយបណ្តាលឱ្យមានការរំខានយ៉ាងខ្លាំងដល់មនុស្សនិងប្រព័ន្ធធម្មជាតិ។

**ការប្រើប្រាស់ដីនិងការប្រែប្រួលការប្រើប្រាស់ដី Land use and land use change**

ការចាត់ចែង សកម្មភាព និងការប្រើប្រាស់ធនធានសម្រាប់ប្រភេទគម្របដីណាមួយ(បណ្តុំសកម្មភាពរបស់មនុស្ស) និង/ឬការគ្រប់គ្រងដីសង្គមនិងសេដ្ឋកិច្ចដូចជា ការដាំស្មៅ ការដកហូតឈើ និងការអភិរក្ស ព្រមទាំងការគ្រប់គ្រងដីដោយសារមនុស្ស ដែលអាចនាំឱ្យមានការប្រែប្រួលគម្របដី។

ការប្រែប្រួលគម្របដី និងការប្រើប្រាស់ដីអាចមានផលប៉ះពាល់លើអាល់បេដូផ្ទៃដី *រំហួត រំភាយចំហាយទឹក* ប្រភព និង*អាងស្រូបឧស្ម័នផ្ទះកញ្ចក់* ឬលក្ខណៈផ្សេងទៀតនៃ*ប្រព័ន្ធអាកាសធាតុ* ដូច្នេះវាអាចមានកម្លាំងរំភាយរស្មី និង/ឬ ឥទ្ធិពលផ្សេងទៀតមកលើអាកាសធាតុក្នុងតំបន់ឬសកលលោក។

**ការផ្តល់សុពលភាព/សុពលកម្ម Validation**

ដំណើរការនៃការវាយតម្លៃឯករាជ្យមួយទៅលើសកម្មភាពគម្រោង *យន្តការអភិវឌ្ឍន៍ស្អាត* ឬសកម្មភាពតាមកម្មវិធីដោយ *អង្គភាពទទួលបន្ទុកប្រតិបត្តិ* ដោយធ្វើការ *ផ្ទៀងផ្ទាត់* វិធាននិងលក្ខខណ្ឌតម្រូវរបស់ *យន្តការអភិវឌ្ឍន៍ស្អាត* ទៅនឹងលក្ខខណ្ឌតម្រូវនៃការរៀបចំឯកសារគម្រោងឬឯកសារសកម្មភាពលម្អិតរបស់កម្មវិធីនិងឯកសារសកម្មភាពលម្អិតនៃគម្រោងតាមផ្នែក។

**ការផ្តល់ហិរញ្ញវត្ថុបន្ទាន់ Fast-start finance (FSF)**

ការសន្យារបស់ប្រទេសអភិវឌ្ឍនា *សន្និសីទបណ្តាភាគី* លើកទី១៥ នៅទីក្រុងកូប៉េនហាកឆ្នាំ២០០៩ ក្នុងការផ្តល់ធនធានហិរញ្ញវត្ថុថ្មីនិងបន្ថែមប្រមាណជិត៣០ប៊ីលាន(៣០ពាន់លាន)ដុល្លារអាម៉េរិកពីឆ្នាំ២០១០ដល់២០១២ សម្រាប់វិស័យនានា រួមទាំងវិស័យព្រៃឈើនិងការវិនិយោគផងដែរ ដោយបែងចែកឱ្យមានតុល្យភាពរវាងសកម្មភាព *កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់* និង *សកម្មភាពបន្សាំ* ។

**ការផ្តល់ឥណទានជាក្រោយ Ex post crediting**

ការចេញលិខិតបញ្ជាក់ពីការផ្តល់ឥណទាន បន្ទាប់ពីមានការ *ផ្ទៀងផ្ទាត់* ដោយឯករាជ្យអំពីការកាត់បន្ថយការបញ្ចេញឧស្ម័ន។

**ការផ្តល់ឥណទានជាមុន Ex ante crediting**

ការចេញលិខិតបញ្ជាក់ពីការផ្តល់ឥណទានជាមុន ដោយរំពឹងថានឹងមានការកាត់បន្ថយការបញ្ចេញឧស្ម័ន នាពេលអនាគត(មិនអនុវត្តក្រោមពិធីសារក្យូតូឡើយ)។

**ការផ្ទេរបច្ចេកវិទ្យា Technology transfer**

ការផ្លាស់ប្តូរចំណេះដឹងផ្នែករឹងនិងទន់ រូបិយវត្ថុនិងទំនិញ ក្នុងចំណោមភាគីពាក់ព័ន្ធ ដែលនាំឱ្យមានការរីកសាយបច្ចេកវិទ្យាសម្រាប់ *បន្សាំ* ឬ *ការកាត់បន្ថយ* និង/ឬការផ្សព្វផ្សាយបច្ចេកវិទ្យានិងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកវិទ្យាទាំងក្នុងនិងក្រៅប្រទេស។

### ការផ្ទេរហានិភ័យ Risk transfer

ទម្លាប់នៃការផ្លាស់ប្ដូរជាផ្លូវការឬក្រៅផ្លូវការនូវផលវិបាកផ្នែកហិរញ្ញវត្ថុក្នុងកម្រិតណាមួយដែលកើតចេញពីហានិភ័យសម្រាប់ព្រឹត្តិការណ៍អវិជ្ជមានដោយឡែកនានា ពីភាគីមួយឱ្យទៅភាគីមួយផ្សេងទៀត។

### ការផ្ទៀងផ្ទាត់ Verification

ការវាយតម្លៃជាទៀងទាត់ដោយស្ថាប័នឯករាជ្យ នៅមុននិងបន្ទាប់ពីការកំណត់របស់*អង្គភាពទទួលបន្ទុកប្រតិបត្តិ* លើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពមនុស្សដែលបានតាមដាន សម្រាប់ប្រភពឧស្ម័នផ្ទះកញ្ចក់ដែលកើតឡើងជាលទ្ធផលនៃសកម្មភាពគម្រោង*យន្តការអភិវឌ្ឍន៍ស្អាត* ដែលបានចុះបញ្ជីឬសកម្មភាពតាមកម្មវិធី(ក្រៅពីគម្រោងព្រៃឈើ)។

### ការផ្លាស់ប្ដូរអាកាសធាតុ ឬការផ្លាស់ប្ដូររបបអាកាសធាតុ Climate shift or climate regime shift

ការផ្លាស់ប្ដូរភ្លាមៗ ឬការឡើងខ្ពស់នៃតម្លៃលេខមធ្យម ដែលបង្ហាញពីការប្រែប្រួលរបបអាកាសធាតុ និងដែលភាគច្រើនត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយលើការផ្លាស់ប្ដូរអាកាសធាតុឆ្នាំ១៩៧៦/១៩៧៧ ដែលទំនងជាឆ្លើយតបនឹងការប្រែប្រួល*បាតុភូតចរន្តអែលនីញ៉ូខាងត្បូង*។

### ការពន្យល់បុព្វហេតុ Attribution

ការប្រែប្រួលណាមួយដែលសង្កេតឃើញនៅក្នុងប្រព័ន្ធមួយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុបណ្ដាលពីសកម្មភាពមនុស្ស ដែលមានពីរដំណាក់កាលគឺ ការប្រែប្រួលដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតតំបន់ដោយមានបញ្ជាក់អំពីកម្រិតទំនុកចិត្ត និងការប្រែប្រួលអាកាសធាតុនៅកម្រិតតំបន់ដែលអាចវាស់វែងបាន ឬការប្រែប្រួលដែលសង្កេតឃើញនៅក្នុងប្រព័ន្ធនោះដោយពាក់ព័ន្ធជាមួយនឹងអំណាចអាកាសធាតុពីសកម្មភាពមនុស្សនៅកម្រិតជឿជាក់ប្រហែលគ្នា។

### ការពន្យល់បុព្វហេតុរួមគ្នា **Joint attribution**

ការជាប់ពាក់ព័ន្ធនឹង *ការប្រែប្រួលអាកាសធាតុ* ថ្នាក់តំបន់ដែលបានសង្កេតឃើញ និងអាចវាស់បាន ឬការប្រែប្រួល ដែលបានសង្កេតឃើញនៅក្នុងប្រព័ន្ធដែលបង្កពីសកម្មភាពមនុស្សនិងហួសពី *វិសមរូបធម្មជាតិ* ។

ដំណើរការនេះពាក់ព័ន្ធជាមួយការវិភាគគ្រាប់តាមវិធីស្ថិតិនៃការប្រែប្រួលអាកាសធាតុបានពី *ម៉ូដែលអាកាសធាតុ* ជាមួយនឹងការឆ្លើយតបដែលសង្កេតឃើញនៅក្នុងប្រព័ន្ធធម្មជាតិនិងប្រព័ន្ធគ្រប់គ្រង។ ទំនុកចិត្តលើការជាប់ទាក់ទងការពន្យល់បុព្វហេតុរួមគ្នា ត្រូវតែទាបជាងទំនុកចិត្តលើជំហាននៃការជាប់ទាក់ទងនីមួយៗដោយសារតែបង្គុំនៃការវាយតម្លៃស្ថិតិចំនួនពីរនៅជាប់ពីគ្នា។

### ការពិសោធអាកាសធាតុដែលមានលំនឹងនិងគ្មានលំនឹង **Equilibrium and transient climate experiment**

"ការពិសោធអាកាសធាតុដែលមានលំនឹង" គឺជាការពិសោធមួយដែលអនុញ្ញាតឱ្យ *ម៉ូដែលអាកាសធាតុ* មួយអាចកែតម្រូវទៅតាមការប្រែប្រួល *កម្លាំងវិកាយរស្មី* បានទាំងស្រុង។ ការពិសោធបែបនេះផ្តល់ព័ត៌មានអំពីភាពខុសគ្នារវាងស្ថានភាពដំបូងនិងចុងក្រោយនៃ *ម៉ូដែលអាកាសធាតុ* ប៉ុន្តែមិនមានប្រតិកម្មតបតាមកាលឡើយ។ ផ្ទុយមកវិញ ប្រសិនបើគេឱ្យ *កម្លាំងវិកាយរស្មី* នេះវិវត្តបន្តិចម្តងៗទៅតាម *ចំហាកបញ្ចេញឧស្ម័ន* ដែលបានកំណត់នោះ ប្រតិកម្មតបតាមកាលនៃ *ម៉ូដែលអាកាសធាតុ* នឹងត្រូវយកមកវិភាគ។ ការពិសោធបែបនេះហៅថា "ការពិសោធអាកាសធាតុគ្មានលំនឹង"។

### ការព្យាករ/ចំណោល **Projection**

ការគន់គិតជាមុននូវការវិវត្តនៃស្ថានភាពមួយឬច្រើនដែលអាចកើតឡើងនាពេលអនាគត ជាញឹកញាប់មាន ការគណនាពីម៉ូដែលជំនួយ។ ព្យាករណ៍ខុសពីទស្សន៍ទាយ។ និយាយឱ្យចំព្យាករណ៍ពាក់ព័ន្ធនឹងការសន្មតដែលទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យានាពេលអនាគតដែលអាចឬមិនអាចកើតឡើង។ ដូច្នេះវាពាក់ព័ន្ធនឹង *ភាពមិនប្រាកដប្រជា* ។

**ការព្យាករតាមទម្លាប់ធម្មតា Business As Usual (BAU)**

*ការព្យាករ* តាមទម្លាប់ធម្មតាត្រូវបានធ្វើឡើងដោយផ្អែកលើការសន្មត ដែលការងារប្រតិបត្តិនិងគោលនយោបាយនៅតែដូចទៅនឹងអ្វីដែលមាននាពេលបច្ចុប្បន្ន។ ទោះបីជាចំហាកគោល អាចបញ្ចូលលក្ខណៈពិសេសរបស់ចំហាកតាមទម្លាប់ធម្មតា( ឧទាហរណ៍ : ការហាមឃាត់បច្ចេកវិទ្យាណាមួយ) ក៏ចំហាកតាមទម្លាប់ធម្មតាគ្មានទម្លាប់ប្រតិបត្តិ ឬគោលនយោបាយខុសពីបច្ចុប្បន្នឡើយ។

**ការព្យាករអាកាសធាតុ/ចំណោលអាកាសធាតុ Climate projection**

ការគន់គិតជាមុនអំពីការឆ្លើយតបនៃ*ប្រព័ន្ធអាកាសធាតុ* ទៅនឹងចំហាកការបញ្ចេញឧស្ម័ននាពេលអនាគត ឬចំហាកកំហាប់ឧស្ម័នផ្ទះកញ្ចក់និង*អាអេរ៉ូសូល* ជាទូទៅបានមកពីការប្រើប្រាស់*ម៉ូដែលអាកាសធាតុ* ។ ការព្យាករអាកាសធាតុខុសពី*ការទស្សន៍ទាយអាកាសធាតុ* ព្រោះថាការព្យាករអាកាសធាតុពឹងផ្អែកលើ*ចំហាកបញ្ចេញឧស្ម័ន*/កំហាប់ឧស្ម័ន/*កម្លាំងវិកាយរស្មី* ដែលបានប្រើប្រាស់ដោយផ្អែកលើការសន្មត ដូចជាការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យានាពេលអនាគតដែលអាចឬមិនអាចដឹងបាន។

**ការរីកមាឌដោយកម្ដៅ Thermal expansion**

កំណើននៃមាឌនិងការថយចុះដង់ស៊ីតេ ដែលបណ្ដាលមកពីទឹកឡើងក្ដៅ ហើយដែលបណ្ដាលឱ្យនីវ៉ូទឹកសមុទ្រកើនឡើង។

**ការរេចរឹលបរិស្ថាន Environmental degradation**

ការខូចខាតបរិស្ថានតាមរយៈការថយចុះធនធាននានា ដូចជា ទឹក ខ្យល់ ដីជាដើម ការបំផ្លាញប្រព័ន្ធអេកូឡូស៊ី និងការផុតពូជនៃរុក្ខជាតិនិងសត្វព្រៃ។

**ការរេចរឹលព្រៃឈើ Forest degradation**

ស្ថានភាពព្រៃឈើដែលបានថយចុះរហូតដល់ក្រោមសមត្ថភាពធម្មជាតិរបស់ព្រៃឈើ ប៉ុន្តែការថយចុះនោះតិចជាង១០% នៃគម្របព្រៃឈើ។

**ការលិចទឹក Inundation**

ស្ថានភាពទឹកដែលបានឬកំពុងជន់លិច ហៀរហូរ កើនឡើង និងបាចសាច ពេញផ្ទៃដី។

**ការវាយតម្លៃចម្រុះ Integrated assessment**

វិធីសាស្ត្រនៃការវិភាគដែលរួមបញ្ចូលលទ្ធផលនិងម៉ូដែលនៃរូបសាស្ត្រ ជីវសាស្ត្រ សេដ្ឋកិច្ច និងវិទ្យាសាស្ត្រសង្គម ព្រមទាំងអន្តរកម្មរវាងសមាសភាគទាំងនេះក្នុងក្របខណ្ឌដែលមានសង្គតិភាពមួយដើម្បីវាយតម្លៃពីស្ថានភាពនិងផលវិបាកនៃការប្រែប្រួលបរិស្ថាន និងវិធានការឆ្លើយតបនៃគោលនយោបាយចំពោះការប្រែប្រួលនេះ។

**ការវាយតម្លៃបន្សុំា Adaptation assessment**

ការកំណត់ជម្រើសនានា ដើម្បី*បន្សុំា* ទៅនឹងការប្រែប្រួលអាកាសធាតុ ហើយការវាយតម្លៃជម្រើសទាំងនោះអាស្រ័យលើលក្ខណវិនិច្ឆ័យព័ត៌មាន អត្ថប្រយោជន៍ ថ្លៃចំណាយ ប្រសិទ្ធផល ប្រសិទ្ធភាព និងលទ្ធភាពដែលអាចអនុវត្តបាន។

**ការវាយតម្លៃផលប៉ះពាល់ Impact assessment**

ការកំណត់និងវាយតម្លៃឥទ្ធិពលនៃ*ការប្រែប្រួលអាកាសធាតុ* មកលើប្រព័ន្ធធម្មជាតិ និង/ឬមនុស្សគិតជារូបិយវត្ថុនិងមិនមែនរូបិយវត្ថុ។

**ការវាយតម្លៃភាពងាយរងគ្រោះ Vulnerability assessment**

ការកំណត់ថានរណានិងអ្វីដែលអាចនឹងទទួលរងផលប៉ះពាល់និងងាយរងគ្រោះដោយសារការផ្លាស់ប្តូរ ហើយការវាយតម្លៃភាពងាយរងគ្រោះនេះ ចាប់ផ្តើមដោយការពិចារណាលើកត្តាដែលនាំឱ្យមនុស្សឬបរិស្ថានងាយនឹងជួបគ្រោះថ្នាក់ ពោលគឺ*ភាពងាយរងគ្រោះ* ទៅនឹងការទទួលបានធនធានធម្មជាតិនិងហិរញ្ញវត្ថុ លទ្ធភាពការពារខ្លួន និងបណ្តាញគាំទ្រ។ល។

### ការវិភាគហានិភ័យមិនអចិន្ត្រៃយ៍ Non-permanence risk analysis

ដំណើរការវាយតម្លៃហានិភ័យលើគម្រោងដែលត្រូវបានធ្វើឡើងនិងធ្វើឱ្យមានសុពលភាពជាបន្តបន្ទាប់ ដោយអង្គភាពឯករាជ្យទទួលស្គាល់ស្តង់ដាកាបូនស្ម័គ្រចិត្ត។

ដោយផ្អែកលើការវាយតម្លៃនេះ អ្នកផ្តល់សុពលភាពឬអ្នកផ្ទៀងផ្ទាត់អាចកំណត់ពីកម្រិតហានិភ័យរបស់គម្រោងនិងភាគរយ*ឥណទានកាបូន* របស់គម្រោងដែលត្រូវផ្ទេរទៅក្នុងគណនីបម្រុងអាងបង្ខាំងនៃការផ្តល់ឥណទានដល់ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់តាមរយៈវិស័យកសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដី។

### ការលេចធ្លាយ Leakage

ការប្រែប្រួលសរុបនៃការបញ្ចេញឧស្ម័នពីសកម្មភាពមនុស្ស តាមប្រភពបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលកើតឡើងនៅខាងក្រៅព្រំដែនគម្រោង ព្រមទាំងអាចវាស់វែងបាននិងជាប់ពាក់ព័ន្ធនឹងសកម្មភាពគម្រោង*យន្តការអភិវឌ្ឍន៍ស្អាត* ឬសកម្មភាពតាមកម្មវិធីតាមដែលអាចអនុវត្តបាន។

### ការលេចធ្លាយកាបូន Carbon leakage

ផ្នែកមួយនៃការកាត់បន្ថយការបញ្ចេញឧស្ម័នក្នុង*បណ្តាប្រទេសឧបសម្ព័ន្ធ B នៃពិធីសារក្យូតូ* ដែលអាចទូទាត់បានដោយបង្កើនការបញ្ចេញឧស្ម័នច្រើនជាងកម្រិតគោល សម្រាប់ប្រទេសមិនជាប់កាតព្វកិច្ចកាត់បន្ថយ។

ការទូទាត់នេះអាចកើតឡើងតាមរយៈ ទី១ ការប្តូរទីតាំងផលិតកម្មដែលប្រើប្រាស់ថាមពលច្រើន ទៅកាន់តំបន់ដែលមិនជាប់កាតព្វកិច្ចកាត់បន្ថយ ទី២ កំណើនប្រើប្រាស់ឥន្ធនៈហ្វូស៊ីលក្នុងតំបន់ តាមរយៈការធ្លាក់ចុះតម្លៃប្រេងនិងឧស្ម័នលើទីផ្សារអន្តរជាតិ ដែលបណ្តាលមកពីតម្រូវការថាមពលតិច និងទី៣ ការប្រែប្រួលប្រាក់ចំណូល(តម្រូវការថាមពលក៏ដូច្នោះដែរ) ដោយសារលក្ខខណ្ឌពាណិជ្ជកម្មប្រសើរជាងមុន។

**ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ Measurement, Reporting and Verification (MRV)**

វិធានបច្ចេកទេសមួយដើម្បីបញ្ជាក់ពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ជាសត្យានុម័ត ហើយអាចប្រើប្រាស់ដើម្បីកំណត់ហិរញ្ញវត្ថុអាកាសធាតុ។

**ការវិភាគថ្លៃដើម-ផលប្រយោជន៍ Cost-benefit analysis**

ការប្រៀបធៀបថ្លៃដើមទៅនឹងផលប្រយោជន៍ក្នុងការសម្រេចចិត្ត ដើម្បីអនុវត្តគម្រោងឬកម្មវិធីណាមួយ។

**ការវិលត្រឡប់នៃសម័យក្រោយយុគទឹកកក Post-glacial rebound**

ចលនាតាមខ្សែឈររបស់ទ្វីបនិងបាតសមុទ្រ បន្ទាប់ពីមានការបាត់បង់និងរួមតូចនៃ *ស្រទាប់ទឹកកក* ។ ការវិលត្រឡប់នេះ គឺជាចលនាអ៊ីសូស្តាទិកនៃដី។

**ការសន្សំសំចៃថាមពល Energy saving**

ការបន្ថយអាំងតង់ស៊ីតេថាមពលដោយសារការផ្លាស់ប្តូរសកម្មភាពដែលត្រូវការធាតុចូលជាថាមពល។ ការសន្សំសំចៃថាមពលអាចសម្រេចទៅបានតាមរយៈសកម្មភាពបច្ចេកទេស ការចាត់ចែងស្ថាប័ននិងរចនាសម្ព័ន្ធ និងការផ្លាស់ប្តូរឥរិយាបថ។

**ការស្តារព្រៃឡើងវិញ Reforestation**

ការដាំដើមឈើនៅលើដីដែលពីមុនធ្លាប់មានព្រៃ ប៉ុន្តែត្រូវបានប្រែក្លាយសម្រាប់គោលបំណងផ្សេងទៀត។

**ការស្តារឡើងវិញ Recovery**

ការធ្វើឱ្យប្រសើរឡើងវិញនូវសុខុបត្ថម្ភវត្ថុ ជីវភាព និងលក្ខខណ្ឌរស់នៅរបស់សហគមន៍ដែលទទួលរងផលប៉ះពាល់ពីគ្រោះមហន្តរាយ រួមទាំងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយកត្តានានាដែលនាំឱ្យមាន *ហានិភ័យគ្រោះមហន្តរាយ* ។

**ការស្រូបទុកកាបូន/ការបង្ខាំងកាបូន Carbon sequestration/Carbon storage**

ការស្រូបនិងការបង្ខាំងកាបូនពីបរិយាកាសនៅក្នុង*អាងស្រូបកាបូន* (ដូចជា មហាសមុទ្រ ព្រៃឈើ ឬដី) តាមរយៈដំណើរការរូបសាស្រ្តឬជីវសាស្រ្ត ដូចជា *រស្មីសំយោគ* ។

ជាគោលការណ៍ ការស្រូបទុកកាបូន សំដៅលើការបង្ខាំងទុកកាបូន បើពុំនោះទេវានឹងបញ្ចេញទៅក្នុងបរិយាកាស។ វិធីសាស្រ្តនៃការអភិវឌ្ឍនិងការរកឃើញមានបីសំខាន់ក្នុងស្ថានភាពផ្សេងៗគឺ៖ ទី១ ការបង្ខាំងរយៈពេលខ្លីនៅក្នុងជីវមណ្ឌលដែនដីគោក ជាទីដែលរុក្ខជាតិស្រូបយក*ឧស្ម័នកាបូនិក* ហើយបង្ខាំងទុកក្នុង*ជីវម៉ាស* និងក្នុងដី ទី២ ការបង្ខាំងរយៈពេលវែងនៅក្នុងដី ត្រូវបានរកឃើញតាមរយៈការបូមបញ្ចូល*ឧស្ម័នកាបូនិក* ទៅក្នុងអាងដែលមានស្រាប់ឬខ្លងដីកជ្រៅទៅក្នុងស្រទាប់ដី និងទី៣ ការបង្ខាំងរយៈពេលវែងនៅក្នុងមហាសមុទ្រ ត្រូវបានរកឃើញតាមរយៈការចាក់បញ្ចូលឧស្ម័នកាបូនិកក្នុងជម្រៅរាប់ពាន់ហ្វីត (feet) ឬរាប់រយម៉ែត្រ ហើយត្រូវបានស្រូបដោយទឹក។

**ការស្រូបលើស Uptake**

ការស្រូបបន្ថែមសារធាតុពាក់ព័ន្ធផ្សេងៗទៅក្នុង*អាងបង្ខាំង* ។

ការស្រូបយកសារធាតុដែលមានវត្ថមានកាបូន ជាពិសេសឧស្ម័នកាបូនិកភាគច្រើនត្រូវបានគេហៅថា*ការស្រូបទុក(កាបូន)* ។

**ការហូរច្រោះ Erosion**

ដំណើរការនៃការដាច់ចេញឬការហូរនាំដី ថ្ម និងសមាសធាតុផ្សេងៗទៀតដោយសារធាតុអាកាស សកម្មភាពចរន្តទឹក ការរលាយទឹកកក រលក ខ្យល់ និងទឹកក្រោមដី។

**ការហូរច្រោះដី Soil erosion**

ដំណើរបាត់បង់ដីស្រទាប់លើដែលជាស្រទាប់មានជីជាតិជាងគេ ដោយសារខ្យល់ ឬទឹកហូរច្រោះ ពិសេស នៅតំបន់ដែលមានចំណោតលើសពី២ដឺក្រេ។

**ការអនុវត្តរួមគ្នា Joint Implementation (JI)**

សកម្មភាពអនុវត្តគម្រោងរួមគ្នារបស់ប្រទេសឬក្រុមហ៊ុនស្ថិតក្នុង*បណ្ដាប្រទេសឧបសម្ព័ន្ធ១* ដែលជាយន្តការអនុវត្តផ្អែកលើទីផ្សារដែលមានចែងក្នុងមាត្រា៦នៃ*ពិធីសារក្យូតូ* ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន ឬបង្កើនការស្រូបនិងចែករំលែកបរិមាណនៃការកាត់បន្ថយការបញ្ចេញឧស្ម័ន។

សកម្មភាពនៃការអនុវត្តរួមគ្នាក៏មានចែងក្នុងមាត្រា៤.២(a) នៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ* ផងដែរ។

**កាលវិទ្យា Chronology**

ការរៀបចំព្រឹត្តិការណ៍ដែលកើតឡើងតាមលំដាប់នៃកាលបរិច្ឆេទឬពេលវេលា។

**កាលាយុសាស្ត្រ Chronosequence**

បណ្ដុំតំបន់ព្រៃឈើមានកេតនកណ្ឌស្រដៀងគ្នា ប៉ុន្តែមានអាយុកាលខុសគ្នា។ ដោយសារដំណើរការអេកូឡូស៊ីព្រៃឈើត្រូវចំណាយពេលយូរ(ច្រើនទសវត្សរ៍ឬសតវត្សរ៍)ដើម្បីលូតលាស់ វិធីសាស្ត្រកាលាយុសាស្ត្រត្រូវបានប្រើជា គំរូតាងនិងសិក្សាពីពេលវេលាត្រូវការដើម្បីអភិវឌ្ឍព្រៃឈើ។ ទិន្នន័យទីវាលពីកាលាយុសាស្ត្រអាចត្រូវបានប្រមូល ក្នុងរយៈពេលច្រើនខែ។ ឧទាហរណ៍ កាលាយុសាស្ត្រត្រូវបានប្រើជាញឹកញាប់ដើម្បីសិក្សាពីការផ្លាស់ប្ដូរនៃសារព័នរុក្ខជាតិជំនាន់ក្រោយ។

**កិច្ចបាត់បង់និងខូចខាត Loss and damage**

កម្មវិធីការងារមួយនៃក្របខណ្ឌបន្សាំទីក្រុងកាន់គុន ដែលត្រូវបានបង្កើតដោយបណ្ដារដ្ឋាភិបាលនៅក្នុង*សន្និសីទបណ្ដាភាគី* លើកទី១៦ នៅទីក្រុងកាន់គុនឆ្នាំ២០១០ ក្នុងគោលបំណងពិចារណាពីវិធីសាស្ត្រនានា ដើម្បីដោះស្រាយការបាត់បង់និងការខូចខាតនៅតាមបណ្ដាប្រទេសកំពុងអភិវឌ្ឍដែលបណ្ដាលមកពី*ផលប៉ះពាល់* នៃ*ការប្រែប្រួលអាកាសធាតុ* ពិសេស*ភាពងាយរងគ្រោះ* ទៅនឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ។

**កិច្ចប្រជុំបណ្ដាភាគី(នៃពិធីសារក្យូតូ) Meeting of the Parties (MOP)**

អង្គជាន់ខ្ពស់នៃពិធីសារក្យូតូដែលបានចូលជាធរមាននៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥ ហើយជាផ្នែកមួយនៃសន្និសីទបណ្ដាភាគីនៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ* ដែលអនុញ្ញាតឱ្យតែបណ្ដាប្រទេសនៃ*ពិធីសារក្យូតូ* ប៉ុណ្ណោះ ចូលរួមប្រជុំជារៀងរាល់ឆ្នាំដើម្បីពិភាក្សានិងធ្វើសេចក្ដីសម្រេចចិត្ត។

**កិច្ចព្រមព្រៀងម៉ារ៉ាកេស Marrakesh Accord**

កិច្ចព្រមព្រៀងធ្វើឡើងនៅក្នុង*សន្និសីទបណ្ដាភាគី* លើកទី៧ ដែលបានកំណត់វិធានជាច្រើនសម្រាប់ប្រតិបត្តិការ*ពិធីសារក្យូតូ* ឱ្យកាន់តែស៊ីជម្រៅ និងបានរៀបរាប់លម្អិតអំពីការបង្កើតប្រព័ន្ធពាណិជ្ជកម្មឧស្ម័នផ្ទះកញ្ចក់ ការអនុវត្តនិងការពិនិត្យតាមដាន*យន្តការអភិវឌ្ឍន៍ស្អាត* ព្រមទាំងការបង្កើតនិងប្រតិបត្តិការមូលនិធិចំនួនបីដើម្បីគាំទ្រកិច្ចប្រឹងប្រែងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

**កិច្ចសហប្រតិបត្តិការត្បូង-ត្បូង South-South Cooperation (SSC)**

កិច្ចសហប្រតិបត្តិការដែលប្រទេសកំពុងអភិវឌ្ឍធ្វើការរួមគ្នាដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមរួមនៃការអភិវឌ្ឍ ហើយដែលជំរុញឱ្យមានកិច្ចសហប្រតិបត្តិការបច្ចេកទេសនិងសេដ្ឋកិច្ចកាន់តែជិតស្និទ្ធរវាងប្រទេសកំពុងអភិវឌ្ឍក្នុងការចែករំលែកការអនុវត្តល្អៗ ព្រមទាំងធ្វើឱ្យមានពិពិធភាព បង្កើនជម្រើសនៃការអភិវឌ្ឍ និងផ្សារភ្ជាប់សេដ្ឋកិច្ច។

**កូតានៃការបញ្ចេញឧស្ម័ន Emission quota**

បរិមាណឬចំណែកនៃការបញ្ចេញឧស្ម័នសរុបដែលកំណត់ឱ្យប្រទេសឬបណ្ដាក្រុមប្រទេសអាចបញ្ចេញឧស្ម័ននៅក្រោមក្របខណ្ឌនៃការបញ្ចេញឧស្ម័នសរុបជាអតិបរមា និងទៅតាមការវិភាជធនធានកាតព្វកិច្ច។

**កូនយុគទឹកកក Little Ice Age (LIA)**

រយៈពេលមួយក្នុងសហស្សវត្សរ៍ទី២នៃគ្រិស្តសករាជ ដែលមានកំណើនយ៉ាងខ្លាំងនិងការរួមតូចមកវិញក្នុងកម្រិតមធ្យមនៃភ្នំទឹកកកនៅចន្លោះពីឆ្នាំ១៤០០ ដល់១៩០០ ទាំងនៅអឌ្ឍគោលខាងជើងនិងអឌ្ឍគោលខាងត្បូង។ ថេរវេលាសម្រាប់ភ្នំទឹកកករីកធំមានភាពខុសគ្នាទៅតាមតំបន់ ដូច្នេះពុំមានការកំណត់ពេលវេលានៃកូនយុគទឹកកកច្បាស់លាស់ឡើយ។

ម៉ូដែលបច្ចុប្បន្នដែលបានមកពីការបង្កើតឡើងវិញនៃសីតុណ្ហភាពមធ្យមនៅអឌ្ឍគោលខាងជើង បង្ហាញថា អំឡុងពេលត្រជាក់បំផុតនៅអឌ្ឍគោលនោះ អាចកើតឡើងរវាងឆ្នាំ១៤៥០ដល់១៨៥០នៃគ្រិស្តសករាជ។

**កំណកអាកាស Precipitation**

ទម្រង់ផ្សេងៗរបស់ទឹកនៅក្នុងបរិយាកាសជាលក្ខណៈរឹងឬរាវដែលធ្លាក់មកលើផ្ទៃផែនដី ឬភាយចេញពីផែនដី ដូចជា ភ្លៀង ទឹកកកសំឡី ព្រឹល ទឹកសន្សើម អព្ទ ជាដើម។

**កម្រិតអាល់កាលី Alkalinity**

រង្វាស់ចំណុះរបស់សូលុយស្យុងមួយក្នុងការបន្សាបអាស៊ីត។

**ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ Intergovernmental Panel on Climate Change (IPCC)**

អង្គភាពអន្តរជាតិនាំមុខសម្រាប់សិក្សាវាយតម្លៃការប្រែប្រួលអាកាសធាតុ ដែលត្រូវបានបង្កើតឡើងដោយកម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP) និងអង្គការឧតុនិយមពិភពលោក(WMO) ដើម្បីផ្តល់ឱ្យពិភពលោកនូវទស្សនៈវិទ្យាសាស្រ្តច្បាស់លាស់ស្តីពីបច្ចុប្បន្នភាពចំណេះដឹងអំពី*ការប្រែប្រួលអាកាសធាតុ* និងផលប៉ះពាល់បរិស្ថាននិងសេដ្ឋកិច្ចសង្គម ដែលអាចកើតមាន។ IPCC គឺជាក្រុមអ្នកវិទ្យាសាស្រ្តមួយ ដែលមានភារកិច្ច ពិនិត្យ និងវាយតម្លៃព័ត៌មានវិទ្យាសាស្រ្ត បច្ចេកទេស និងសេដ្ឋកិច្ចសង្គមថ្មីៗបំផុតពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុសម្រាប់ពិភពលោក។

មហាសន្និបាតសហប្រជាជាតិបានអនុម័តសកម្មភាពរបស់អង្គការឧតុនិយមពិភពលោក(WMO) និងកម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP) ក្នុងការបង្កើត IPCC រួមគ្នា។

**កំណកអចិន្ត្រៃយ៍ Permafrost**

ស្រទាប់ដី(ដីឬថ្ម រួមទាំងទឹកកកនិងសារធាតុសរីរាង្គ) ដែលមានសីតុណ្ហភាពស្មើឬក្រោមសូន្យអង្សាសេ ក្នុងរយៈពេលយ៉ាងហោចណាស់ពីរឆ្នាំជាប់គ្នា។

**កំណើនផលផ្ទះកញ្ចក់ Enhanced greenhouse effect**

ផលផ្ទះកញ្ចក់ធម្មជាតិដែលកើនឡើងដោយសារកំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស ដូចជា ឧស្ម័នកាបូនិកនិងមេតាន ដែលបញ្ចេញដោយសកម្មភាពមនុស្ស។

កំណើនផលផ្ទះកញ្ចក់ទាំងនេះបង្កឱ្យផែនដីកាន់តែឡើងកម្តៅ។

**កំណើននីវ៉ូទឹកសមុទ្រ Sea level rise**

កំណើនមធ្យមនៃនីវ៉ូមហាសមុទ្រ ដែលអ្នកធ្វើម៉ូដែលអាកាសធាតុភាគច្រើនធ្វើការប៉ាន់តាមបែបអឺស្តាទិកពីការផ្លាស់ប្តូរនីវ៉ូទឹកសមុទ្រមធ្យមសកលដែលបណ្តាលឱ្យមានការផ្លាស់ប្តូរមាឌមហាសមុទ្រពិភពលោកដោយធៀបកំណើននីវ៉ូទឹកសមុទ្រនៅកន្លែងដែលមានកំណើននីវ៉ូទឹកសមុទ្រពិតទៅនឹងចលនាដីក្នុងតំបន់។

**កំលុងពេលទទួលបានឥណទាន Crediting period**

កំលុងពេលដែលត្រូវបានផ្ទៀងផ្ទាត់និងចេញលិខិតបញ្ជាក់ជាផ្លូវការអំពីការកាត់បន្ថយឧស្ម័នឬការស្រូបយកឧស្ម័នផ្ទះកញ្ចក់ដែលពាក់ព័ន្ធក្នុង***គម្រោងយន្តការអភិវឌ្ឍន៍ស្អាត*** ឬសកម្មភាពគម្រោងតាមផ្នែក(CPA)ដែលអាចអនុវត្តបានដើម្បីទទួលបានលិខិតបញ្ជាក់ជាផ្លូវការពីការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ (CERs) ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបានបញ្ជាក់រយៈពេលវែង(ICERs) ឬការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបានបញ្ជាក់បណ្តោះអាសន្ន (tCERs)។

រយៈពេលដែលបានប្រើប្រាស់ក្នុងកំលុងពេលនៃការទទួលបាន *ឥណទានកាបូន* សម្រាប់សកម្មភាពគម្រោង *យន្តការអភិវឌ្ឍន៍ស្អាត* ឬសកម្មភាពគម្រោងតាមផ្នែក(CPA) ត្រូវបានកំណត់ដោយអនុលោមតាមវិធាននិងលក្ខខណ្ឌតម្រូវរបស់ *យន្តការអភិវឌ្ឍន៍ស្អាត* ហើយអាចនឹងបន្តទៀតឬមានកាលកំណត់ដោយអនុលោមតាមវិធាន និងលក្ខខណ្ឌតម្រូវនោះ។

## កំលុងពេលប្តេជ្ញាចិត្តអនុវត្ត Commitment period

កំលុងពេលនៃគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ឱ្យបានទៀងទាត់ ដែលក្នុងពេលនោះតម្រូវឱ្យប្រទេសមួយចំនួនកាត់បន្ថយការបញ្ចេញឧស្ម័នក្នុងបរិមាណជាក់លាក់។

កំលុងពេលប្តេជ្ញាចិត្តអនុវត្តដំណាក់កាលទី១នៃ *ពិធីសារក្យូតូ* បានចាប់ផ្តើមពីឆ្នាំ២០០៨ ដល់ចុងឆ្នាំ២០១២។

ការប្តេជ្ញាចិត្តថ្មីរបស់ *បណ្តាប្រទេសភាគីក្នុងឧបសម្ព័ន្ធ១* នៃ *ពិធីសារក្យូតូ* បានឯកភាពលើការប្តេជ្ញាចិត្តដំណាក់កាលទីពីរ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

## ក្លរ៉ូភ្លុយអូរ៉ូកាបួ Chlorofluorocarbons (CFCs)

ប្រភេទ *ឧស្ម័នផ្ទះកញ្ចក់* ស្ថិតក្រោម *ពិធីសារម៉ុងរ៉េអាល់* ឆ្នាំ១៩៨៧ ហើយត្រូវបានប្រើប្រាស់សម្រាប់ទូរទឹកកក ម៉ាស៊ីនត្រជាក់ សម្ភារៈវេចខ្ចប់ អ៊ីសូឡង់សារធាតុរំលាយ ឬសារធាតុបាញ់អាអេរ៉ូសូល។

ដោយសារឧស្ម័នក្លរ៉ូភ្លុយអូរ៉ូកាបួមិនអាចត្រូវបានបំផ្លាញនៅក្នុងបរិយាកាសទាប វាបានសោត់ចូលបរិយាកាសខ្ពស់បំបែក *ស្រទាប់អូសូន* ក្នុងលក្ខខណ្ឌសមស្រប។ ឧស្ម័នទាំងនេះកំពុងត្រូវបានជំនួសដោយសមាសធាតុផ្សេងទៀត រួមមានពពួក *អ៊ីដ្រូក្លរ៉ូភ្លុយអូរ៉ូកាបួ* និង *អ៊ីដ្រូភ្លុយអូរ៉ូកាបួ* ដែលជាប្រភេទឧស្ម័នផ្ទះកញ្ចក់ស្ថិតក្រោម *ពិធីសារក្យូតូ* ដែលត្រូវបានអនុម័តនៅឆ្នាំ១៩៩៧និងបានចូលជាធរមាននៅឆ្នាំ២០០៥។

**ក្លាត្រាត(មេតាន) Clathrate (methane)**

ល្បាយឧស្ម័នមេតាននិងទឹកកកដែលមានសភាពខាប់និងកកតាមផ្នែក ដែលច្រើនឃើញមាននៅក្នុងកម្អេចកំណ។

# ខ

**ខ្យល់ក្តៅ Hot air**

ការព្រួយបារម្ភចំពោះរដ្ឋាភិបាលមួយចំនួនដែលនឹងអាចសម្រេចបានតាមគោលដៅនៃការកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ប្រទេសខ្លួននៅក្រោម*ពិធីសារក្យូតូ* តាមរយៈកិច្ចខិតខំប្រឹងប្រែងតែបន្តិចបន្តួច ហើយបន្ទាប់មកធ្វើឱ្យជន់លិចទីផ្សារ*ឥណទានកាបូន* ដែលសកម្មភាពទាំងនេះអាចបណ្តាលឱ្យប្រទេសផ្សេងទៀតបាក់ទឹកចិត្តក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នក្នុងប្រទេសរបស់ពួកគេ។

**ខ្យល់មូសុង Monsoon**

ខ្យល់រដូវនៅតំបន់រយៈទទឹងត្រូពិក មានរបបទៀងទាត់ ហើយបក់ពីសមុទ្រមកទ្វីបនៅរដូវវស្សា ដោយនាំមកជាមួយនូវភ្លៀងយ៉ាងច្រើន និងបក់ពីទ្វីបទៅសមុទ្រនៅរដូវប្រាំង ដែលជាខ្យល់ស្ងួតត្រជាក់។

**ខ្សែកោងអន្តរកាលព្រៃឈើ Forest transition curve**

ការផ្លាស់ប្តូរគម្របព្រៃឈើក្នុងរយៈពេលជាក់លាក់មួយ ដោយតម្លៃនៃការប្រែប្រួលការប្រើប្រាស់ដីដែលមានលក្ខណៈប្រកួតប្រជែងនៅក្នុងតំបន់ ដែលជាទូទៅអាចបណ្តាលឱ្យមានការថយចុះយ៉ាងឆាប់រហ័សនៃផ្ទៃព្រៃក្នុងកំលុងពេលដំបូងនៃឧស្សាហូបនីយកម្មនិងការអភិវឌ្ឍ ហើយបន្ទាប់មកគម្របព្រៃឈើកើនឡើងយឺតៗតិចជាងកម្រិតដើម។

**ខ្សែគោល/យោង Baseline/reference**

ស្ថានភាពមួយដែលត្រូវបានប្រើប្រាស់សម្រាប់វាស់វែងការផ្លាស់ប្តូរ។

រយៈពេលគោលបានពីការគណនារយៈពេលពាក់ព័ន្ធនៃភាពមិនប្រក្រតី។

កំហាប់គោលរបស់ឧស្ម័នកម្រមួយ ត្រូវបានវាស់វែងនៅទីកន្លែងដែលមិនទទួលរងឥទ្ធិពលពីការបញ្ចេញឧស្ម័នដោយសកម្មភាពមនុស្សក្នុងតំបន់នោះ។

**ខ្សែគោលស្តង់ដា Standardized baseline**

គោលស្តង់ដាមួយដែលបានបង្កើតដោយភាគីមួយឬភាគីមួយក្រុមនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ឬក្រុមនៃបណ្តាប្រទេសនានា ជាជាងបង្កើតដោយគម្រោងមួយ ដើម្បីជួយសម្រួលដល់ការគណនាបរិមាណ *ឧស្ម័នផ្ទះកញ្ចក់* ដែលបានកាត់បន្ថយនិងបរិមាណស្រូបដោយ*អាងស្រូបកាបូន* និង/ឬសម្រួលដល់ការកំណត់*ផលបន្ថែម* សម្រាប់សកម្មភាពគម្រោង*យន្តការអភិវឌ្ឍន៍ស្អាត* ឬសកម្មភាពគម្រោងតាមកម្មវិធីក្នុងការធានាគុណភាពបរិស្ថាន។

**ខ្សែដីឬតំបន់ដី Grounding line/zone**

កន្លែងជួបគ្នារវាង*ផែនទឹកកក* ឬ*ស្រទាប់ទឹកកក* និង*ផ្ទាំងទឹកកក* ដែលជាកន្លែងទឹកកកចាប់ផ្តើមអណ្តែត។

**ខ្សែចង្វាក់តម្លៃអាហារ Food value chain**

ភាពពេញលេញនៃចង្វាក់ផលិតកម្មរបស់កសិដ្ឋាននិងក្រុមហ៊ុន ហើយនឹងសកម្មភាពនានាដែលមានគុណតម្លៃបន្ថែមក្នុងការកែច្នៃវត្ថុធាតុដើមកសិកម្មឱ្យទៅជាផលិតផលស្បៀង លក់ចេញទៅឱ្យអ្នកប្រើប្រាស់ និងបញ្ចេញជាសំណល់បន្ទាប់ពីប្រើប្រាស់រួច។

**ខ្សែលំនឹង Equilibrium line**

ព្រំប្រទល់មធ្យមនៃទីតាំងក្នុងពេលវេលាណាមួយ ដែលជាទូទៅត្រូវបានគេជ្រើសជាតំបន់មានផ្ទាំងគំនរទឹកកកទាបបំផុតនៅចុងរដូវក្តៅនៅតំបន់មានផែនទឹកកក រវាងតំបន់មានការបាត់បង់ផ្ទាំងគំនរទឹកកកពិតប្រចាំឆ្នាំ(តំបន់រលាយ) និងតំបន់មានកំណើនផ្ទាំងគំនរទឹកកកពិតប្រចាំឆ្នាំ(កន្លែងកើនម៉ាស)។

គេហៅរយៈកម្ពស់នៃព្រំប្រទល់នេះថា រយៈកម្ពស់ខ្សែលំនឹង។

# គ

**គណនេយ្យកាបូន Carbon accounting**

ការតាមដានភាពប្រែប្រួលនៃបរិមាណកាបូន ក្នុង*អាងបង្ខាំង* ដែលពាក់ព័ន្ធនឹងប្រភពបញ្ចេញឧស្ម័ននានា ភាគច្រើនចេញពីសកម្មភាពមនុស្ស និងតាមដាន *អាងស្រូប* ឧស្ម័នផ្ទះកញ្ចក់។

**គណនេយ្យបៃតង Green accounting**

គណនេយ្យមួយប្រភេទដែលមានគោលបំណងបញ្ច្រាបវិធានការសុខុមាលភាពសង្គមឱ្យទូលំទូលាយទៅក្នុងការសិក្សាម៉ាក្រូសេដ្ឋកិច្ច ដោយផ្តោតលើគោលនយោបាយសង្គម បរិស្ថាន និងអភិវឌ្ឍន៍។

គណនេយ្យបៃតងរួមបញ្ចូលទាំងការវាយតម្លៃគិតជារូបិយវត្ថុក្នុងបំណងគណនា "ផលិតផលជាតិបៃតង" ដោយដកផលខូចខាតសេដ្ឋកិច្ចដោយសារជាតុបំពុលចេញពីផលិតផលជាតិ និងប្រព័ន្ធគណនេយ្យដែលបញ្ចូលទំហំនៃការបំពុល ការបំផ្លាញ និងទិន្នន័យផ្សេងៗទៀត តាមបែបមិនមែនរូបិយវត្ថុ។

**គម្របព្រៃស្រទាប់លើ Canopy cover**

ភាគរយនៃចន្លោះពីផ្ទៃដីទៅចុងឈើដែលគ្របដណ្តប់ដោយចំណោលខ្សែកែងឈរនៃបរិវេណស្រទាប់លើបង្អស់ដែលរុក្ខជាតិបែកមែក ធាង ស្លឹក សាខា តាមធម្មជាតិ។

**គម្លាតសីតុណ្ហភាពពេលថ្ងៃ Diurnal temperature range**

ភាពខុសគ្នារវាងសីតុណ្ហភាពអតិបរមានិងអប្បបរមានៅពេលថ្ងៃ។

**គោលការណ៍ប្រុងប្រយ័ត្នជាមុន Precautionary principle**

វិធានការប្រុងប្រយ័ត្នជាមុនដើម្បីប្រមើលមើល ទប់ស្កាត់ ឬបង្រួមមូលហេតុនៃ *ការប្រែប្រួលអាកាសធាតុ* និងកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងររបស់វា ដូចមានចែងក្នុងមាត្រា៣នៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ*។

នៅប្រទេសដែលមានការគំរាមកំហែងខ្លាំង ឬមានការបំផ្លិចបំផ្លាញមិនអាចស្រោចស្រង់បាន ប្រទេសនោះមិនត្រូវប្រើប្រាស់កង្វះខាតភាពប្រាកដប្រជាផ្នែកវិទ្យាសាស្ត្រ ដើម្បីជាមូលហេតុក្នុងការពន្យារពេលចាត់វិធានការឡើយ ប៉ុន្តែត្រូវពិចារណាថាគោលនយោបាយនិងវិធានការដោះស្រាយការប្រែប្រួលអាកាសធាតុ គួរតែមានប្រសិទ្ធភាពចំណាយដោយប្រើថ្លៃចំណាយទាបបំផុតដើម្បីធានានូវអត្ថប្រយោជន៍ជាសកល។

**គោលគំនិតគម្រោង Project Idea Note (PIN)**

ការពិពណ៌នាខ្លីអំពីគម្រោង(ប្រមាណ៦ទំព័រ) ដែលផ្តល់ព័ត៌មានជាមូលដ្ឋានអំពីគម្រោង ដូចជា ប្រភេទ ទំហំ ទីតាំងគម្រោង និងការប៉ាន់ប្រមាណបរិមាណកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ធៀបនឹងចំហាក*តាមទម្លាប់ធម្មតា* ។

**គោលនយោបាយសោកស្តាយតិចតួច Low regrets policy**

គោលនយោបាយដែលអាចបង្កើតអត្ថប្រយោជន៍សង្គម និង/ឬសេដ្ឋកិច្ចពិតនៅក្រោមលក្ខខណ្ឌអាកាសធាតុបច្ចុប្បន្ន និងរបាយចំហាកនៃការប្រែប្រួលអាកាសធាតុនាពេលអនាគត។

**គ្រោះមហន្តរាយ Disaster**

ការផ្លាស់ប្តូរធ្ងន់ធ្ងរនៃដំណើរការជាធម្មតារបស់សហគមន៍ឬសង្គមមួយដោយសារទទួលរងព្រឹត្តិការណ៍រូបវន្តប្រកបដោយគ្រោះថ្នាក់ ដែលមានអន្តរកម្មជាមួយលក្ខខណ្ឌសង្គមដែលងាយរងគ្រោះ ហើយនាំទៅរកឥទ្ធិពលអវិជ្ជមានដ៏ធំធេងមកលើមនុស្ស សម្ភារៈ សេដ្ឋកិច្ច ឬបរិស្ថាន ដែលកត្តាទាំងនេះតម្រូវឱ្យមានវិធានការឆ្លើយតបជាបន្ទាន់ ដើម្បីបំពេញតម្រូវការសំខាន់ៗរបស់មនុស្ស ហើយទាមទារឱ្យមានការគាំទ្របន្ថែមពីខាងក្រៅដើម្បីស្តារស្ថានភាពនេះឡើងវិញ។

# ច

**ចរន្តទឹកកក Ice stream**

លំហូរខ្លាំងនៃទឹកកក ដែលជាផ្នែកនៃ*ស្រទាប់ទឹកកក* មួយ ដែលភាគច្រើនដាច់ចេញពីទឹកកកដែលនៅជុំវិញដោយសារស្នាមប្រេះយ៉ាងជ្រៅ។

**ចរន្តទូទៅ General circulation**

ចលនាទ្រង់ទ្រាយធំរបស់*បរិយាកាស* និងមហាសមុទ្រ ដែលជាផលវិបាកនៃកំណើនកម្ដៅខុសៗគ្នាមកលើផែនដីដែលវិល ហើយបណ្ដាលឱ្យមានឡើងវិញនូវតុល្យភាពថាមពលនៃ*ប្រព័ន្ធអាកាសធាតុ* តាមរយៈការបញ្ជូនកម្ដៅនិងកម្លាំងជំរុញ។

**ចរន្តទៅមកពហុទសវត្សរ៍អាត្លង់ទិក Atlantic Multi-decadal Oscillation (AMO)**

ការផ្លាស់ប្ដូរជាច្រើនទសវត្សរ៍(៦៥ដល់៧៥ឆ្នាំ) ក្នុងមហាសមុទ្រអាត្លង់ទិកខាងជើង ដែលសីតុណ្ហភាពផ្ទៃសមុទ្រមានដំណាក់កាលក្ដៅចន្លោះឆ្នាំ១៨៦០-១៨៨០និង១៩៣០-១៩៦០ហើយក្នុងដំណាក់កាលត្រជាក់ចន្លោះឆ្នាំ១៩០៥-១៩៥២ និង ១៩៧០-១៩៩០ ដែលការប្រែប្រួលនេះក្នុងកម្រិតឡើងចុះនៅក្នុងរង្វង់០,៤អង្សាសេ។

**ចលនាទាំងផ្ទាំង Mass movement**

បាតុភូតផ្សេងៗគ្នានៃដំណើរការរំកិលទ្រង់ទ្រាយធំ រួមមាន*រំកិលដី* រអិលព្រីលការធ្លាក់ផ្ទាំងថ្ម ឬលំហូរកម្ទេចកម្ទី។

**ចុណ្ណភាគ Fine particle**

សមាសធាតុតូចៗអណ្តែតនៅក្នុង *បរិយាកាស* ហើយមានទំហំតូចជាង២,៥ មីក្រូម៉ែត្រ(μm)ដែលតាងដោយ $PM_{2.5}$។

**ចំណុចខ្មៅនៃព្រះអាទិត្យ Sunspots**

ផ្ទៃងងឹតតូចៗនៅលើផ្ទៃព្រះអាទិត្យដែលមានដែនម៉ាញេទិកខ្លាំង អាចកាត់បន្ថយ *បន្ទេរកម្តៅតាមខ្សែឈរ* ជាហេតុធ្វើឱ្យសីតុណ្ហភាពថយចុះប្រមាណ ១ ៥០០កែលវិន(ស្មើនឹង១ ២២៦,៨៥អង្សាសេ) ធៀបនឹងតំបន់ដែលនៅជុំវិញ។

ចំនួនចំណុចខ្មៅនៃព្រះអាទិត្យមានការកើនឡើងច្រើនក្នុងអំឡុងពេលមាន *សកម្មភាពពន្លឺព្រះអាទិត្យ* ខ្លាំង ហើយប្រែប្រួលទៅតាមវដ្តពន្លឺព្រះអាទិត្យ។

**ចំណុចភ្លឺ Faculae**

បំណែកភ្លឺនៅលើព្រះអាទិត្យ។

កន្លែងដែលគ្របដណ្តប់ដោយចំណុចភ្លឺនេះ មានទំហំកាន់តែធំនៅពេលមាន *សកម្មភាពពន្លឺព្រះអាទិត្យ* កាន់តែខ្លាំង។

**ចំណុចរបត់ Tipping point**

ចំណុចសន្ទតមួយដែលតំណាងឱ្យរបត់នៃការប្រែប្រួលអាកាសធាតុក្នុងកម្រិតសកលឬកម្រិតតំបន់ពីកម្រិតស្ថិរភាពមួយទៅកម្រិតស្ថិរភាពមួយផ្សេងទៀត។

ព្រឹត្តិការណ៍ចំណុចរបត់អាចមិនវិលត្រឡប់មកស្ថានភាពដើមវិញបានទេ។

**ចំហាក Scenario**

សេចក្តីអធិប្បាយដ៏សាមញ្ញនិងដែលគួរឱ្យជឿជាក់បាន ថាតើ នាពេលអនាគតប្រហែលវាអាចនឹងកើតឡើងយ៉ាងដូចម្តេច ដោយផ្អែកលើភាពប្រទាក់គ្នានិងសង្គតិភាពផ្ទៃក្នុងនៃការសន្មតពីកម្លាំងជំរុញនិងទំនាក់ទំនងសំខាន់ៗ។

ចំហាក(Scenario)អាចកើតចេញពីការព្យាករ ប៉ុន្តែជាញឹកញាប់ច្រើនតែផ្អែកលើព័ត៌មានបន្ថែមពីប្រភពដទៃទៀត ហើយជួនកាលរួមផ្សំនឹងការពណ៌នាសាច់រឿង។

**ចំហាកកម្លាំងរំភាយរស្មី Radiative forcing scenario**

ការឱ្យសញ្ញាដែលគួរឱ្យជឿជាក់នៃការកើតមាននាពេលអនាគតនៃកម្លាំងរំភាយរស្មីដែលពាក់ព័ន្ធ ដូចក្នុងករណីមានការប្រែប្រួលសមាសភាពនៅក្នុងបរិយាកាស ឬការប្រែប្រួលការប្រើប្រាស់ដី ឬកត្តាខាងក្រៅ ដូចជា ភាពខុសគ្នានៃ *សកម្មភាពពន្លឺព្រះអាទិត្យ* ។ ចំហាកកម្លាំងរំភាយរស្មីអាចយកទៅប្រើប្រាស់ជាធាតុចូលសម្រាប់ *ម៉ូដែលអាកាសធាតុ* សាមញ្ញដើម្បីគណនា *ការព្យាករអាកាសធាតុ* ។

**ចំហាកបញ្ចេញឧស្ម័ន Emission scenario**

ការឱ្យសញ្ញាដែលគួរឱ្យទុកចិត្តបានមួយនៃការកើតមានឡើងនូវការបញ្ចេញសារធាតុនានា នាពេលអនាគត ដែលអាចមានសកម្មភាពចំណាំងរស្មីដូចជា *ឧស្ម័នផ្ទះកញ្ចក់ អាអេរ៉ូសូល* ដោយផ្អែកលើភាពប្រទាក់គ្នានិងសង្គតិភាពផ្ទៃក្នុងនៃការសន្មតពីកម្លាំងជំរុញដូចជា ប្រជាសាស្ត្រនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការផ្លាស់ប្តូរបច្ចេកវិទ្យា និងទំនាក់ទំនងគន្លឹះរបស់វា។ ចំហាកកំហាប់ដែលបានមកពីចំហាកបញ្ចេញឧស្ម័ន ត្រូវបានប្រើប្រាស់ជាធាតុចូលសម្រាប់ *ម៉ូដែលអាកាសធាតុ* ដើម្បី *ព្យាករអាកាសធាតុ* ។

នៅក្នុងរបាយការណ៍ *ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ* ឆ្នាំ១៩៩២ សំណុំចំហាកការបញ្ចេញឧស្ម័នមួយត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ព្យាករណ៍អាកាសធាតុនៅក្នុង IPCC ឆ្នាំ១៩៩៦។ ចំហាកការបញ្ចេញទាំងនេះ ត្រូវបានចាត់ទុកជាចំហាក IS92។ នៅក្នុងរបាយការណ៍ពិសេសរបស់ IPCC ស្តីពីចំហាកការបញ្ចេញ ចំហាកការបញ្ចេញថ្មីៗដែលហៅថាចំហាក SRESS ត្រូវបានបោះពុម្ពផ្សាយ ក្នុងនោះចំហាកខ្លះត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ព្យាករណ៍ មានបង្ហាញនៅក្នុងជំពូកទី៩ដល់១១នៃរបាយការណ៍ IPCC ឆ្នាំ២០០១ និងជំពូកទី១០និង១១នៃរបាយការណ៍នេះ។

**ចំហាយទឹក Water vapor**

ទឹកនៅក្នុង *បរិយាកាស* ក្នុងសណ្ឋានជាឧស្ម័ន និងជាប្រភេទ *ឧស្ម័នផ្ទះកញ្ចក់* មួយសំបូរជាងគេ ហើយដែលជាផ្នែកសំខាន់មួយនៃផលផ្ទះកញ្ចក់ធម្មជាតិ។

ទោះបីជាមនុស្សមិនមែនជាអ្នកបង្កើនកំហាប់ចំហាយទឹកតាមរយៈការបញ្ចេញផ្ទាល់ក៏ដោយ ក៏ប៉ុន្តែចំហាយទឹក រួមចំណែកក្នុងការបង្កើន *ផលផ្ទះកញ្ចក់* ដោយសារឥទ្ធិពលកម្តៅឧស្ម័នផ្ទះកញ្ចក់នាំឱ្យផលតបចំហាយទឹកវិជ្ជមាន។ បន្ថែមពីលើតួនាទីជាឧស្ម័នផ្ទះកញ្ចក់ធម្មជាតិ ចំហាយទឹកក៏មានឥទ្ធិពលមកលើសីតុណ្ហភាពផែនដីផងដែរ ពីព្រោះចំហាយទឹកច្រើនលើសលប់ក្នុងបរិយាកាស បង្កទៅជាពពក បង្កើតបានជាទឹកកក តំណក់ទឹក និងទឹកភ្លៀង។

# ជ

**ជញ្ជាំងសមុទ្រ Seawall**

សំណង់ការពារទឹកសមុទ្រដែលសាងឡើងដោយមនុស្សនៅតាមតំបន់ឆ្នេរសមុទ្រ ដើម្បីការពារសំណឹកដែលបណ្ដាលមកពីរលក។

**ជម្រាបទឹក Infiltration**

ដំណើរការដែលទឹកលើផ្ទៃដីជ្រាបចូលទៅក្នុងដី។

**ជម្រាលទឹកភ្លៀង Watershed**

ផ្ទៃដីទាំងអស់ដែលទទួលទឹកភ្លៀង រួមបញ្ចូលទាំងបណ្ដាញផ្លូវទឹកទាំងមូលដែលហូរចាក់ទៅក្នុងទន្លេ ស្ទឹង ឬបឹងណាមួយ។

ជម្រាលទឹកភ្លៀងរបស់ទន្លេនីមួយៗ ចែកដាច់ពីជម្រាលទឹកភ្លៀងរបស់ទន្លេដែលនៅជិតខាងដោយខ្សែចែកទឹក។

**ជម្រើសមិនសោកស្ដាយ No regret options**

ការសម្រេចចិត្តជ្រើសរើសយកវិធីសាស្ត្រឬវិធានការដែលមានសុពលភាពទោះជា*ការប្រែប្រួលអាកាសធាតុ* នឹងកើតឡើងដូចការរំពឹងទុក ឬក៏មិនកើតឡើងក៏ដោយ។

ជាទូទៅ ខ្លឹមសារនេះមានគោលបំណងបង្កើនភាពធន់របស់ប្រជាជនជនបទនិងកាត់បន្ថយ*ភាពងាយរងគ្រោះ*របស់ប្រជាជន ចំពោះហានិភ័យទាក់ទងនឹងទឹក។

**ជម្រើសសោកស្ដាយខ្លាំង High regret options**

ការសម្រេចចិត្តជ្រើសរើសយកវិធីសាស្ត្រឬវិធានការដែលមានសុពលភាពសម្រាប់អាកាសធាតុនាពេលអនាគតប៉ុន្តែមិនចាំបាច់សម្រាប់ស្ថានភាពអាកាសធាតុបច្ចុប្បន្ន។

វាអាចតំណាងឱ្យថ្លៃដើម និងផ្តល់ផលអវិជ្ជមានសម្រាប់ស្ថានភាពអាកាសធាតុបច្ចុប្បន្ន ដែលទាមទារឱ្យមានការគិតពិចារណាវិភាគហានិភ័យយ៉ាងហ្មត់ចត់។

**ជលវិទ្យា Hydrology**

វិទ្យាសាស្ត្រដែលសិក្សាអំពីទឹករបស់ផែនដី(ទឹកសាបនិងទឹកប្រៃ) រួមបញ្ចូលទាំងវដ្តទឹកលក្ខណៈរូបនិងលក្ខណៈគីមីរបស់ទឹក ទំនាក់ទំនងជាមួយនឹងធនធានទឹក បរិយាកាស រំហួត កំណកអាកាស លំហូរទឹក និងទឹកក្រោមដី។

**ជលោតុវិទ្យា/ជលឧតុវិទ្យា Hydrometeorology**

ផ្នែកមួយនៃឧតុនិយមនិងជលសាស្ត្រ ដែលសិក្សាអំពីបន្ទេរទឹកនិងថាមពលរវាងផ្ទៃដីនិងបរិយាកាសសម្ពាធទាប។

**ជីវថាមពល Bioenergy**

ថាមពលដែលបំលែងចេញពីទម្រង់ណាមួយនៃ *ជីវម៉ាស* ដូចជា សារពាង្គកាយរស់ថ្មីៗឬសំណល់កកើតពីដំណើរការមេតាបូលីស។

**ជីវមណ្ឌល Biosphere**

ផ្នែកមួយនៃប្រព័ន្ធផែនដីដែលផ្សំដោយ *ប្រព័ន្ធអេកូឡូស៊ី* នានា និងសារពាង្គកាយរស់ទាំងអស់ដែលមាននៅក្នុង *បរិយាកាស* នៅលើដី(ជីវមណ្ឌលដីគោក) ឬក្នុងសមុទ្រ(ជីវមណ្ឌលសមុទ្រ) រួមមានសារធាតុសរីរាង្គងាប់ ដូចជា សំរាម កាកសំណល់បន្ទុះភ្នំភ្លើង សារធាតុសរីរាង្គក្នុងដី និងកម្ទេចកម្ទីក្នុងសមុទ្រ។

**ជីវធ្យូង Biochar**

អង្គធាតុរឹងដែលទទួលបានពីការដុត *ជីវម៉ាស* ឱ្យទៅជាធ្យូង ដែលអាចបន្ថែមទៅក្នុងដី ដើម្បីបង្កើនមុខងាររបស់ដីនិងកាត់បន្ថយការបញ្ចេញឧស្ម័នពី *ជីវម៉ាស* បើពុំនោះទេ *ជីវម៉ាស* នោះអាចពុកផុយតាមធម្មជាតិបង្កទៅជា *ឧស្ម័នផ្ទះកញ្ចក់*។ ជីវធ្យូងក៏អាចស្រូបយកកាបូនខ្ពស់ផងដែរ។

**ជីវម៉ាស Biomass**

បរិមាណសរុបរបស់សារពាង្គកាយរស់នៅទីកន្លែងណាមួយឬក្នុងបរិមាណណាមួយ។

បំណែករុក្ខជាតិដែលងាប់អាចចាត់ទុកជាជីវម៉ាសគ្មានជីវិត។

**ជីវម៉ាសក្រោមដីនៃរុក្ខជាតិ Belowground biomass**

ជីវម៉ាសរស់ទាំងអស់នៃឫសរុក្ខជាតិរស់ ដែលពេលខ្លះមិនរាប់បញ្ចូលឫសល្អិតៗដែលមានអង្កត់ផ្ចិតតូចជាង២មិល្លីម៉ែត្រឡើយ ព្រោះតាមការពិសោធ ឫសល្អិតៗទាំងនោះភាគច្រើនមិនអាចញែកចេញពីដីសរីរាង្គឬកម្ទេចឈើឡើយ។

**ជីវសហគមន៍ Biome**

ផ្នែកចម្បងនិងប្លែកពីគេនៃ*ជីវមណ្ឌល*ដែលជាទូទៅ ផ្សំដោយ*ប្រព័ន្ធអេកូឡូស៊ី*មួយចំនួនដូចជា ព្រៃឈើ ទន្លេ ស្រះ វាលភក់ នៅក្នុងរង្វង់នៃតំបន់ណាមួយដែលមានអាកាសធាតុប្រហាក់ប្រហែល។

លក្ខណៈជីវសហគមន៍ ស្ដែងឡើងតាមរយៈសហគមន៍សត្វនិងរុក្ខជាតិដែលមានលក្ខណៈដាច់ដោយឡែកមួយបែប។

**ជីវឥន្ធនៈ Biofuel**

ឥន្ធនៈរាវផលិតចេញពីសារធាតុសរីរាង្គឬប្រេងរុក្ខជាតិដែលអាចដុតឆេះបាន។

ឧទាហរណ៍ : ជីវឥន្ធនៈមានដូចជា អាល់កុល(ជីវអេតាណុល) ជ័រខ្មៅម្យ៉ាងបានពីដំណើរការផលិតក្រដាស ប្រេង សណ្ដែកសៀង... ។

**ជីវឧស្ម័ន Biogas**

ល្បាយ *ឧស្ម័នមេតាន ឧស្ម័នកាបូនិក* និង *ឧស្ម័នកម្រ* ផ្សេងៗទៀត ដែលបានមកពីការបំបែកសារធាតុសរីរាង្គ ដូចជា លាមកសត្វ សំណល់កសិកម្ម ជាដើម ដោយគ្មានវត្តមានអុកស៊ីសែន។

**ជីវៈចម្រុះ Biodiversity**

នានាភាពនៃសារពាង្គកាយរស់នៅលើដី ក្នុងទឹក និងក្នុង*ប្រព័ន្ធអេកូឡូស៊ី*ផ្សេងៗទៀត ដែលរួមមាននានាភាពសេនេទិច នានាភាពប្រភេទ និងនានាភាព*ប្រព័ន្ធអេកូឡូស៊ី*។

**ជំងឺឆ្លងតាមចំណីអាហារ Food born disease**

ជំងឺដែលបង្កឡើងតាមរយៈការបរិភោគចំណីអាហារឬទឹក ដែលមានភ្នាក់ងារបង្កជំងឺ។

**ជំងឺឆ្លងតាមទឹក Water-borne disease**

ជំងឺដែលកើតឡើងដោយសារទឹកមានភ្នាក់ងារបង្កជំងឺ តាមរយៈការងូត ការលាងសម្អាត ការបរិភោគ ការរៀបចំម្ហូបអាហារនិងការបរិភោគម្ហូបអាហារនោះ។

**ជំងឺឆ្លងតាមភ្នាក់ងារចម្លង Vector-borne disease**

ជំងឺឆ្លង(ជំងឺគ្រុនចាញ់ គ្រុនឈាម...)ពីសារពាង្គកាយមួយទៅសារពាង្គកាយមួយទៀតតាមរយៈភ្នាក់ងារចម្លងដូចជា មូស ចៃ ជាដើម។

**ជំនន់គំហុក Flash flood**

ទឹកជំនន់ដែលកើនឡើងយ៉ាងឆាប់រហ័ស ដោយគ្មានឬមានតិចតួចនូវសញ្ញាឱ្យដឹងជាមុន ដែលជាធម្មតា ជាលទ្ធផលនៃភ្លៀងធ្លាក់ខ្លាំងនៅតំបន់តូចមួយ ឬបណ្តាលមកពីការកកស្ទះទឹកកក ការបាក់ទំនប់ និងស្ថានភាពភូមិសាស្ត្រ។

# ដ

**ដានកាបូន Carbon footprint**

បរិមាណសរុបនៃ *ឧស្ម័នផ្ទះកញ្ចក់* ដែលបញ្ចេញទៅក្នុង *បរិយាកាស* ជារៀងរាល់ឆ្នាំដោយមនុស្សម្នាក់ គ្រួសារមួយ អគារមួយ ស្ថាប័នមួយ ឬក្រុមហ៊ុនមួយ។

ដានកាបូនរបស់មនុស្សម្នាក់ៗមានជាអាទិ៍ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីប្រេងឥន្ធនៈប្រើប្រាស់ផ្ទាល់ដោយបុគ្គលម្នាក់ៗ ដូចជា តាមរយៈការប្រើប្រាស់ឧបករណ៍អគ្គិសនីក្នុងផ្ទះ ឬយានយន្ត។ បរិមាណនេះរួមបញ្ចូលផងដែរនូវឧស្ម័នផ្ទះកញ្ចក់ពីការផលិតទំនិញ ឬសេវាកម្មដែលបុគ្គលនោះប្រើប្រាស់ ស្ថានីយផលិតថាមពលអគ្គិសនី រោងចក្រផលិតផលនានា និងទីលានចាក់សំរាម។

**ដានព្យុះ Storm tracks**

- ដានព្យុះស៊ីក្លូននីមួយៗក្នុងប្រព័ន្ធធាតុអាកាស។

- តំបន់ដែលមានដានព្យុះធំៗនៅក្រៅតំបន់ត្រូពិកដោយសារប្រព័ន្ធសម្ពាធទាប(ព្យុះស៊ីក្លូន) និងប្រព័ន្ធសម្ពាធខ្ពស់(ព្យុះអង់ទីស៊ីក្លូន) កើតឡើងញឹកញាប់។

**ដោយសកម្មភាពមនុស្ស Anthropogenic**

ដែលបណ្តាលមកពីមនុស្សឬដែលកើតឡើងដោយសារសកម្មភាពរបស់មនុស្ស។

**ដំណកស្ពាន់ធ័រពីផ្សែង Flue gas desulphurization**

បច្ចេកវិទ្យាមួយដែលប្រើប្រាស់អង្គធាតុស្រូប ដូចជា កំបោរ ថ្មកំបោរ ដើម្បីដកស្ពាន់ធ័រឌីអុកស៊ីតចេញពីឧស្ម័ន ដែលបង្កដោយចំហេះ*ឥន្ធនៈហ្វូស៊ីល*។

ដំណើរការដកស្ពាន់ធ័រឌីអុកស៊ីតពីផ្សែង គឺជាបច្ចេកទេសទំនើបប្រើប្រាស់សម្រាប់ដកស្ពាន់ធ័រឌីអុកស៊ីតពីប្រភពបញ្ចេញចម្បងៗ ដូចជា រោងចក្រផលិតថាមពល ដែលប្រើចំហេះ*ឥន្ធនៈហ្វូស៊ីល*។

**ដំណើរកម្ដៅរួស Sensible heat flux**

ដំណើរកម្ដៅភាយចេញពីផ្ទៃផែនដីទៅក្នុងបរិយាកាស ដោយមិនពាក់ព័ន្ធនឹងការប្រែប្រួលសភាពទឹក ហើយជាសមាសភាគនៃថាមពលសរុបលើផ្ទៃដី។

**ដំណើរកម្ដៅឡាតង់ Latent heat flux**

ដំណើរកម្ដៅភាយចេញពីផ្ទៃផែនដីទៅក្នុង*បរិយាកាស* ដោយពាក់ព័ន្ធនឹង*រំហួត* ឬកំណក*ចំហាយទឹក* នៅលើផ្ទៃដី ដែលជាសមាសភាគមួយនៃថាមពលសរុបលើផ្ទៃផែនដី។

**ដំណើរខ្យល់ចេញចូល Ventilation**

ការផ្លាស់ប្ដូរសំណុំលក្ខណៈនៃមហាសមុទ្រជាមួយនឹងស្រទាប់ផ្ទៃបរិយាកាស ដែលកំហាប់នៃការផ្លាស់ប្ដូរនេះ ឈានទៅរកស្ថានភាពក្បែរលំនឹងបរិយាកាស ហើយសំណុំលក្ខណៈនេះនឹងចូលក្នុងមហាសមុទ្រវិញ។

**ដំណើររំភាយចំហាយទឹកពីរុក្ខជាតិ Transpiration**

ដំណើររំហួតចំហាយទឹកដែលភាយចេញពីផ្ទៃលើនៃស្លឹករុក្ខជាតិ តាមរយៈស្តូម៉ាតា(រន្ធធម្មជាតិតូចៗនៃស្លឹក ឬទងរុក្ខជាតិ)។

**ដ្យាតូម Diatoms**

សារាយឯកកោសិកាមួយប្រភេទរស់នៅក្នុងផ្ទៃទឹកបឹង ទន្លេ និងមហាសមុទ្រ ហើយមានសំបកក្រៅរឹង ដែលរបាយរបស់វាទាក់ទងទៅនឹងសីតុណ្ហភាពផ្ទៃសមុទ្រពីអតីតកាល។

# ឱ

**ឱអាសូតម៉ូណូអុកស៊ីត ($N_2O$) Nitrous oxide ($N_2O$)**

ឧស្ម័នផ្ទះកញ្ចក់មួយប្រភេទក្នុងចំណោម ***ឧស្ម័នផ្ទះកញ្ចក់*** ទាំង៦ ដែលត្រូវកាត់បន្ថយក្រោម ***ពិធីសារក្យូតូ*** ដែលមានប្រភពសំខាន់ពីសកម្មភាពមនុស្ស គឺពីវិស័យកសិកម្ម (ការគ្រប់គ្រងដីនិងលាមកសត្វ)ការធ្វើប្រព្រឹត្តិកម្មសំណល់ រាវ ចំហេះឥន្ធនៈហ្វូស៊ីល និងដំណើរការឧស្សាហកម្មគីមី។

ឱអាសូតម៉ូណូអុកស៊ីត($N_2O$)ក៏ត្រូវបានបង្កើតឡើងដោយធម្មជាតិពីប្រភពជីវសាស្ត្រជាច្រើនផ្សេងទៀតនៅក្នុងដីនិងទឹក ជាពិសេស សកម្មភាពមីក្រូជីវសាស្ត្រនៅព្រៃត្រូពិកសើម។

# ត

## តម្លៃបង្វិលមកវិញ Return value

តួលេខខ្ពស់បំផុតឬទាបបំផុតនៃអថេរណាមួយដែលកើតឡើងជាមធ្យមចំនួនមួយលើកក្នុងរយៈពេលកំណត់មួយ (ឧទាហរណ៍ : ក្នុងរយៈពេល១០ឆ្នាំ)។

## តុល្យភាពថាមពល Energy balance

ផលដករវាងថាមពលចូលសរុបនិងថាមពលចេញសរុបនៅក្នុង*ប្រព័ន្ធអាកាសធាតុ*។ ប្រសិនបើតុល្យភាពនេះវិជ្ជមានកម្តៅនឹងកើនឡើង។ ប្រសិនបើតុល្យភាពនេះអវិជ្ជមាននឹងមានការចុះត្រជាក់។ នៅពេលមានការគណនាតុល្យភាពនេះជាមធ្យមភាគសម្រាប់ទូទាំងពិភពលោកនិងក្នុងរយៈពេលវែង តុល្យភាពនេះត្រូវតែស្មើសូន្យ។ ដោយសារប្រព័ន្ធអាកាសធាតុទទួលថាមពលស្ទើរតែទាំងស្រុងពីព្រះអាទិត្យ តុល្យភាពស្មើសូន្យមានន័យថា បរិមាណកាំរស្មីព្រះអាទិត្យដែលចាំងចូលជាមធ្យមនៅទូទាំងពិភពលោកត្រូវតែស្មើនឹងផលបូកនៃ*វិកាយរស្មីពន្លឺព្រះអាទិត្យ* ចំណាំងផ្លាតបូកនឹង*វិកាយរស្មីអាំងហ្វ្រាក្រហមកម្តៅ* ភាយចេញពីប្រព័ន្ធអាកាសធាតុ។

## តំបន់ខ្សត់អុកស៊ីសែន Dead zone

តំបន់ក្នុងមហាសមុទ្រនិងបឹងដែលអុកស៊ីសែនមានកម្រិតទាបបំផុតដោយសារវត្តមានសារធាតុចិញ្ចឹមច្រើនហួសកម្រិត បណ្តាលមកពីសកម្មភាពមនុស្សនិងកត្តាដទៃទៀតដែលនាំឱ្យបាត់បង់អុកស៊ីសែនចាំបាច់សម្រាប់ទ្រទ្រង់ជីវិតសារពាង្គកាយនៅជិតបាតសមុទ្រឬបឹងនិងនៅបាតសមុទ្រឬបឹង។

**តំបន់គម្រោង Project zone**

តំបន់ដែលរួមបញ្ចូលនូវតំបន់អនុវត្តគម្រោង ដែលក្នុងនោះសកម្មភាពគម្រោងដូចជា ការអភិវឌ្ឍសហគមន៍ និងជម្រើសនៃការចិញ្ចឹមជីវិតរបស់ប្រជាជនមានឥទ្ធិពលដោយផ្ទាល់ទៅលើដីនិងធនធានដែលពាក់ព័ន្ធ។

ប្រសិនបើមានការប្រើប្រាស់វិធីសាស្ត្រតាមកម្មវិធី តំបន់គម្រោងត្រូវរួមបញ្ចូលតំបន់អនុវត្តគម្រោងប្រកបដោយសក្តានុពលទាំងអស់ដូចជា តំបន់ដីថ្មីដែលមានសក្តានុពលទាំងអស់ដែលក្នុងនោះសកម្មភាពគម្រោងត្រូវបានអនុវត្តនៅពេលអនាគត បន្ទាប់ពីមានការផ្តល់សុពលភាពដំបូង ក្នុងគោលបំណងបង្កើតអត្ថប្រយោជន៍អាកាសធាតុពិត។

**តំបន់ជំនួបអន្តរត្រូពិក Inter-Tropical Convergence Zone (ITCZ)**

តំបន់សម្ពាធទាបនៅក្បែរខ្សែអេក្វាទ័រ ជាទីកន្លែងដែលខ្យល់ពីភាគឦសានជួបនឹងខ្យល់ពីភាគអាគ្នេយ៍។ នៅពេលខ្យល់ទាំងនេះជួបគ្នា ខ្យល់សើមត្រូវបានរុញច្រានឡើងលើជាហេតុនាំឱ្យមានកំណកអាកាសធ្លាក់ខ្លាំងនិងប្រែប្រួលទៅតាមរដូវកាល។

**តំបន់ពាក់កណ្តាលស្ងួតហែង Semi-arid zone**

តំបន់ដែលរារាំងការលូតលាស់របស់រុក្ខជាតិ ដោយសារបរិមាណទឹកនៅមានកម្រិត បណ្តាលឱ្យរដូវដាំដុះនៅតំបន់នោះមានរយៈពេលខ្លី ឯផលិតកម្មបឋមរវាងឆ្នាំនីមួយៗមានការប្រែប្រួលខ្លាំង។ តំបន់នេះមានរបាយកំណកអាកាស (ទឹក ភ្លៀង ព្រឹល ...) ប្រចាំឆ្នាំពី៣០០ទៅ៨០០មិល្លីម៉ែត្រ អាស្រ័យលើភ្លៀងធ្លាក់នៅសរទរដូវ និងសិសិររដូវ។

**តំបន់ស្ងួតហែង Arid zone**

តំបន់ដែលរារាំងការដុះលូតលាស់របស់រុក្ខជាតិយ៉ាងខ្លាំងដោយសារកង្វះទឹក ហើយដែលនៅក្នុងភាគច្រើននៃតំបន់ស្ងួតហែងនេះ រុក្ខជាតិដើមកំណើតមានលក្ខណៈរង្វើល។ របបទឹកភ្លៀងមានការប្រែប្រួលខ្លាំង ហើយកម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំតិចជាង៣០០មិល្លីម៉ែត្រ។

# ថ

**ថាមពលកកើតឡើងវិញ Renewable energy**

ថាមពលកើតពីធនធានដែលត្រូវបានបំពេញឡើងវិញដោយធម្មជាតិដូចជា *ជីវម៉ាស ភារីអគ្គិសនី* កម្ដៅចេញពីផែនដី *ពន្លឺព្រះអាទិត្យ* ខ្យល់កម្ដៅមហាសមុទ្រ ចលនាទឹករលក និងចលនាទឹកជោរនាច។

**ថាមពលបញ្ចេញកាបូនទាប Low-carbon power**

ថាមពលផលិតដោយដំណើរការឬបច្ចេកវិទ្យាដែលបញ្ចេញឧស្ម័នកាបូនិកទាបធៀបនឹងផលិតកម្មថាមពលដើរដោយចំហេះឥន្ធនៈហ្វូស៊ីលនាពេលបច្ចុប្បន្ន។

ប្រភពនៃការផលិតថាមពលបញ្ចេញកាបូនទាប មានដូចជា ខ្យល់ *ពន្លឺព្រះអាទិត្យ* វារីអគ្គិសនី និងនុយក្លេអ៊ែរ ។

**ថាមពលប៉ូតង់ស្យែល Potential energy**

ផ្នែកមួយនៃថាមពលប៉ូតង់ស្យែលសរុបដែលអាចបំប្លែងទៅជាថាមពលស៊ីណេទិកនៅក្នុងប្រព័ន្ធកម្ដៅបិទជិត។

**ថាមពលបៃតង Green energy**

ប្រសិទ្ធផលថាមពល ជាពិសេស ការផលិតនិងការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញដូចជា កម្លាំងខ្យល់ ពន្លឺព្រះអាទិត្យ កម្លាំងទឹករលក *ជីវឧស្ម័ន ជីវម៉ាស* ជីវឥន្ធនៈ និង*វារីអគ្គិសនី*។

**ថាមពលពន្លឺព្រះអាទិត្យ Solar energy**

ថាមពលដែលបញ្ចេញពីព្រះអាទិត្យមកដល់ផ្ទៃផែនដី ក្នុងទម្រង់ជាពន្លឺមើលឃើញ កាំរស្មីជំហានរលកខ្លី និងពន្លឺក្បែរកាំរស្មីស្វាយអ៊ុលត្រា។

ថាមពលពន្លឺព្រះអាទិត្យមានសារៈសំខាន់ណាស់សម្រាប់រុក្ខជាតិធ្វើរស្មីសំយោគ និងបំប្លែងទឹកក្នុងទម្រង់ពីរាវ ទៅជាចំហាយ ដែលជាផ្នែកមួយនៃ*វដ្តទឹក* ។ល។ គេប្រើកោសិកាផូតូអគ្គិសនីដើម្បីបំប្លែងថាមពលពន្លឺព្រះអាទិត្យឱ្យទៅជាថាមពលអគ្គិសនី សម្រាប់ប្រើប្រាស់ក្នុងផ្កាយរណបនិងនៅតំបន់ដាច់ស្រយាល។ គេក៏ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យសម្រាប់កម្តៅទឹក ប្រើប្រាស់ក្នុងផ្ទះនៅប្រទេសត្រជាក់ និងនៅក្នុងម៉ាស៊ីនចំហាយខ្លះសម្រាប់បង្វិលជនិតាអគ្គិសនី។

**ថាមពលមហាសមុទ្រ Ocean energy**

ថាមពលបានពីមហាសមុទ្រតាមរយៈកម្លាំងទឹករលក កម្លាំងទឹកជោរនាច ចរន្តទឹកជោរនាច ឬកម្តៅនិងកម្រិតជាតិប្រៃនៃមហាសមុទ្រ។

**ថ្លៃបន្សាំ Adaptation costs**

ថ្លៃចំណាយសម្រាប់ការធ្វើផែនការ រៀបចំ សម្របសម្រួល និងអនុវត្តវិធានការបន្សាំដោយរួមបញ្ចូលទាំងថ្លៃចំណាយអន្តរកាល។

# ទ

**ទម្រង់ជារង្វង់ខាងជើង Northern Annular Mode (NAM)**

ការប្រែប្រួលយ៉ាងគំហុកនារដូវត្រជាក់នូវទម្រង់ដែលកំណត់ដោយសម្ពាធទាបនៅលើផ្ទៃផែនដីក្នុងមហាសមុទ្រអាកទិកនិងរយៈទទឹងមធ្យមទៅកាន់ទិសខាងលិច។

ទម្រង់ជារង្វង់ខាងជើង មានទំនាក់ទំនងជាមួយចរន្តទៅមកនៃខ្យល់ប៉ូលខាងជើង ដែលគួចឡើងទៅក្នុង*មណ្ឌលអាកាសស្ងប់*។ ទម្រង់នេះមាននិន្នាការទៅរកអាត្លង់ទិកខាងជើង ហើយមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយចរន្តទៅមកនៃអាត្លង់ទិកខាងជើង។

**ទម្រង់ជារង្វង់ខាងត្បូង Southern Annular Mode (SAM)**

គំរូនាំមុខនៃវិសមរូបកម្ពស់ប៉ូតង់ស្យែលធរណីនៅអឌ្ឍគោលខាងត្បូង ដែលជាប់ទាក់ទងនឹងការប្រែប្រួលចរន្តទៅមកនៃខ្យល់នៅរយៈទទឹងមធ្យម។

**ទម្រង់វិសមរូបអាកាសធាតុ Modes of climate variability**

*វិសមរូបធម្មជាតិ* នៃប្រព័ន្ធអាកាសធាតុ ជាពិសេស តាមរដូវកាលនិងក្នុងរយៈពេលវែង ដែលច្រើនតែកើតឡើង ដោយមានទម្រង់ទីតាំងនិងមាត្រដ្ឋានពេលវេលាសមស្រប តាមរយៈដំណើរការ(dynamic)នៃចរន្តបរិយាកាសនិងតាមរយៈអន្តរកម្មរវាងផ្ទៃដីនិងមហាសមុទ្រ។

ទម្រង់ទាំងនេះច្រើនត្រូវបានគេហៅថា របបម៉ូតឬទំនាក់ទំនងពីចម្ងាយ។ ឧទាហរណ៍ ចរន្តអាត្លង់ទិកខាងជើង(NAO) ទម្រង់ប៉ាស៊ីហ្វិកអាម៉េរិកខាងជើង (PNA) ចរន្តអែលនីញ៉ូខាងត្បូង(ENSO) ***ទម្រង់ជារង្វង់ខាងជើង*** និង ***ទម្រង់ជារង្វង់ខាងត្បូង*** ជាទម្រង់វិសមរូបអាកាសធាតុ។

**ទីកំណក Frozen ground**

ដីឬថ្មដែលក្នុងនោះទឹកនៅតាមចន្លោះខ្លះៗឬទាំងអស់ត្រូវកក រួមបញ្ចូលទាំងកំណកអចិន្ត្រៃយ៍។

ទីដែលកកនិងរលាយរៀងរាល់ឆ្នាំ ហៅថាទីកំណកប្រចាំរដូវ។

**ទីផ្សារកាបូន Carbon market**

ប្រព័ន្ធពាណិជ្ជកម្មមួយដែលក្នុងនោះ ប្រទេសនានាអាចទិញឬលក់បរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងកិច្ចប្រឹងប្រែងមួយ ដើម្បីឆ្លើយតបទៅនឹងការកំណត់ថ្នាក់ជាតិស្តីពីការបញ្ចេញឧស្ម័ននៅក្រោម *ពិធីសារក្យូតូ* ឬនៅក្រោមកិច្ចព្រមព្រៀងដទៃទៀត ដូចជាកិច្ចព្រមព្រៀងបណ្តារដ្ឋជាសមាជិកសហភាពអឺរ៉ុប។

ពាក្យនេះត្រូវបានប្រើប្រាស់ដោយសារតែ *ឧស្ម័នកាបូនិក* គឺជាប្រភេទឧស្ម័នមានច្រើនជាងគេក្នុងចំណោម *ឧស្ម័នផ្ទះកញ្ចក់* ហើយឧស្ម័នដទៃទៀតត្រូវបានវាស់ជាឯកតា *សមមូលឧស្ម័នកាបូនិក* ។

**ទីផ្សារកាបូនស្ម័គ្រចិត្ត Voluntary market**

ទីផ្សារកាបូនដែលនៅក្រៅក្របខណ្ឌទីផ្សារកាបូនជាប់កាតព្វកិច្ច ហើយមិនពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងអន្តរជាតិ។ ទីផ្សារទាំងនេះត្រូវបានជំរុញដោយការប្តេជ្ញាស្ម័គ្រចិត្តពីស្ថាប័នផ្សេងៗ(ក្រុមហ៊ុនថាមពល ក្រុមហ៊ុនអាកាសចរណ៍) និងបុគ្គលពាក់ព័ន្ធ។

**ទឹកកកលើផ្ទៃដី Ground ice**

ទឹកកកគ្រប់ប្រភេទដែលស្ថិតក្នុងសណ្ឋានដាកំណក ក្នុងទីកំណកតាមរដូវកាល និងក្នុង *កំណកអចិន្ត្រៃយ៍* ។

**ទឹកកកសមុទ្រ Sea ice**

ទឹកកកក្នុងសមុទ្រដែលកើតចេញពីកំណកទឹកសមុទ្រ ដែលអាចជាបំណែកនៅដាច់ៗពីគ្នា( ផ្ទាំងទឹកកកអណ្តែត ) រសាត់នៅលើផ្ទៃមហាសមុទ្រឬសមុទ្រ

ដោយសារចរន្តខ្យល់និងទឹកដែលបង្កើតបានជាបណ្តុំទឹកកក ឬជា *ផ្ទាំងទឹកកក* ដែលគ្មានចលនានៅជាប់នឹងឆ្នេរ( *ផ្ទាំងទឹកកក* លើផ្ទៃសមុទ្រ )។

កំហាប់ទឹកកកសមុទ្រគឺជាប្រភាគនៃផ្ទៃមហាសមុទ្រឬសមុទ្រដែលគ្របដណ្តប់ដោយទឹកកក។ ទឹកកកសមុទ្រដែលមានអាយុតិចជាងមួយឆ្នាំមានឈ្មោះថា ទឹកកកឆ្នាំទីមួយ។ ទឹកកកសមុទ្រដែលមានអាយុច្រើនឆ្នាំ គឺទឹកកកសមុទ្រដែលមិនរលាយយ៉ាងហោចណាស់ក្នុងមួយរដូវក្តៅ។ គេអាចបន្តចែកឈ្មោះទឹកកក ដែលមានអាយុច្រើនឆ្នាំ ទៅជាទឹកកកឆ្នាំទីពីរនិងទឹកកកពហុឆ្នាំ ហើយទឹកកកពហុឆ្នាំនេះជាទឹកកកដែលមិនរលាយយ៉ាងហោចណាស់រយៈពេលពីររដូវក្តៅ។

**ទឹកជំនន់ Flood**

លំហៀរទឹកខុសពីកម្រិតកំណត់នៃច្រាំងទន្លេ ឬច្រាំងអាងបង្ខាំងទឹកដទៃទៀត ឬកំណើនជាបន្តបន្ទាប់នូវបរិមាណទឹកលិចនៅតំបន់ដែលធម្មតាមិនមានទឹកជន់លិច។ ទឹកជំនន់ រាប់បញ្ចូលទាំងជំនន់ទន្លេ *ជំនន់គំហុក* ជំនន់ទីក្រុង ជំនន់ទឹកភ្លៀង ជំនន់ទឹកលូ ជំនន់តាមតំបន់ឆ្នេរ និងជំនន់ពីការរលាយទឹកកក។

**ទឹកសមុទ្រខ្ពស់បំផុតនៅតំបន់ឆ្នេរ Extreme coastal high water**

នីវ៉ូទឹកសមុទ្រកើនឡើងខ្ពស់ខុសប្រក្រតី អាស្រ័យលើនីវ៉ូទឹកសមុទ្រមធ្យម ទឹកជោរ និង *ប្រព័ន្ធជាតុអាកាស* ថ្នាក់តំបន់។

ព្រឹត្តិការណ៍នីវ៉ូទឹកខ្ពស់ខុសប្រក្រតីនៅតំបន់ឆ្នេរត្រូវបានកំណត់ដោយលំដាប់ភាគរយខ្ពស់(ដូចជាភាគរយទី៩០ដល់៩៩ )នៃរបាយតួលេខប្រចាំម៉ោងរបស់នីវ៉ូទឹកសមុទ្រដែលបានសង្កេតឃើញនៅស្ថានីយណាមួយក្នុងអំឡុងពេលសង្កេតជាក់លាក់។

**ទូរសន្និកម្ម Teleconnection**

ទំនាក់ទំនងតាមបែបស្ថិតិរវាង *វិសម្យបអាកាសធាតុ* ក្នុងភូមិសាស្ត្រជាក់លាក់មួយដែលមានទីតាំងឆ្ងាយដាច់ពីគ្នា។

ទំនាក់ទំនងពីចម្ងាយត្រូវបានបង្កើតឡើងដោយរចនាសម្ព័ន្ធរូបវន្តយ៉ាងច្រើន ដូចជា វិសាលភាពនៃអថេរបរិយាកាសក្នុងមហាសមុទ្រ វិសមរូបបរិយាកាសតំបន់រយៈទទឹងមធ្យម ព្រមទាំង*ផានព្យុះ* ។ល។

**ទំនប់តូច Dyke**

សំណង់តូចៗសម្រាប់ទប់ទឹក។

**ទែម៉ូក្លាញ Thermocline**

ស្រទាប់សីតុណ្ហភាពខ្ពស់បំផុតតាមខ្សែឈរនៅក្នុងមហាសមុទ្រ ដែលស្ថិតនៅចន្លោះផ្ទៃលើនៃមហាសមុទ្រ(ពី០ចុះទៅ២០០ម៉ែត្រ)និងស្រទាប់ក្រោមនៃមហាសមុទ្រ(ចាប់ពី១ ០០០ម៉ែត្រចុះទៅ)។

នៅតំបន់ក្បែរត្រូពិក ប្រភពទឹកបែបនេះគឺជាប្រភេទទឹកលើផ្ទៃដីនៅរយៈកម្ពស់ខ្ពស់ដែលបានស្រូបចុះក្រោមនិងហូរចាក់ទៅរកអេក្វាទ័រ។ នៅរយៈកម្ពស់ខ្ពស់ ជួនកាលពុំមានបាតុភូតបែបនេះទេ ប៉ុន្តែជំនួសដោយហាឡូក្លាញដែលជាស្រទាប់ទឹកមានកំហាប់អំបិលអតិបរមាតាមខ្សែឈរ។

**ឌីប៉ូលមហាសមុទ្រឥណ្ឌា Indian Ocean Dipole (IOD)**

វិសមរូបសីតុណ្ហភាពនៃផ្ទៃទឹកសមុទ្រដែលមានទ្រង់ទ្រាយធំនៅមហាសមុទ្រឥណ្ឌារវាងឆ្នាំនានា ហើយទម្រង់បែបនេះស្តែងឡើងតាមរយៈសីតុណ្ហភាពខុសគ្នានៃផ្ទៃទឹកសមុទ្រនៅតំបន់ត្រូពិកក្នុងដំណាក់កាលមិនប្រក្រតីមួយនៅរដូវស្លឹកឈើជ្រុះក្នុងតំបន់អាកាសធាតុត្រជាក់ភាគខាងជើង ដោយបង្ហាញពីការចុះត្រជាក់នៅស៊ូម៉ាត្រា និងឡើងក្តៅនៅសូម៉ាលីភាគខាងលិច រួមផ្សំជាមួយចរន្តខ្យល់មិនប្រក្រតីបក់ទៅទិសខាងកើតស្របជាមួយខ្សែអេក្វាទ័រ។

# ធ

**ធាតុអាកាស Weather**

ស្ថានភាពនៃបរិយាកាសនៅពេលណាមួយឬនៅក្នុងរយៈពេលខ្លីនិងនៅកន្លែងណាមួយ ដែលបញ្ជាក់ដោយបាតុភូតឧតុភូតនានាដូចជា សម្ពាធបរិយាកាស សូរ្យការ សីតុណ្ហភាព សំណើម ទឹកភ្លៀង ពពក ខ្យល់ ជាដើម។ នៅកន្លែងភាគច្រើន ធាតុអាកាសអាចប្រែប្រួលតាមម៉ោង ថ្ងៃ និងរដូវកាល។ ឧទាហរណ៍ ប្រទេសកម្ពុជានាខែមេសា ពេលថ្ងៃមានសភាពពេល/ធាតុអាកាស ក្តៅខ្លាំង។

# ន

**និយ័តកម្មផ្អែកលើទីផ្សារ Market-based regulation**

វិធីសាស្ត្រនិយ័តដោយប្រើប្រាស់យន្តការតម្លៃ (ការយកពន្ធនិងការអនុញ្ញាតឱ្យដេញថ្លៃពាណិជ្ជកម្មកាបូន) ក្នុងចំណោមវិធានការដទៃទៀត ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

**នីវ៉ូទឹកសមុទ្រធៀប Relative sea level**

នីវ៉ូផ្ទៃទឹកសមុទ្រដែលត្រូវបានកំណត់ដោយឧបករណ៍វាស់ទឹកជោរនាចដោយធៀបទៅនឹងដីដែលនីវ៉ូផ្ទៃទឹកសមុទ្រនោះតាំងនៅ។

**នីវ៉ូទឹកសមុទ្រមធ្យម Mean sea level**

នីវ៉ូនៃផ្ទៃទឹកសមុទ្រនៅត្រង់ចំណុចជាក់លាក់មួយគិតជាមធ្យមក្នុងអំឡុងពេលវែងមួយ ដូចជា មួយខែឬមួយឆ្នាំ។

ជាញឹកញាប់ នីវ៉ូទឹកសមុទ្រមធ្យមត្រូវបានប្រើប្រាស់ជាតម្រុយរបស់ជាតិសម្រាប់វាស់កម្ពស់ផ្ទៃដី។

# ន

**បច្ចេកវិទ្យា Technology**

ការអនុវត្តជាក់ស្តែងនូវចំណេះដឹងវិទ្យាសាស្ត្រដើម្បីសម្រេចការងារណាមួយតាមគោលការណ៍និងនីតិវិធី ដោយប្រើទាំងផ្នែករឹង(ឧបករណ៍) ទាំងផ្នែកទន់(ព័ត៌មាន សង្គម កម្មវិធីកុំព្យូទ័រ ជំនាញផលិត របៀបប្រើប្រាស់ជាដើម)។

**បច្ចេកវិទ្យាបញ្ចេញកាបូនទាប Low-carbon technology**

បច្ចេកវិទ្យាដែលក្នុងមួយវដ្តដំណើរការរបស់វា បញ្ចេញ*សមមូលឧស្ម័នកាបូនិក*ទាបជាងបច្ចេកវិទ្យាផ្សេងៗទៀត។

**បច្ចេកវិទ្យាបៃតង Green technology**

បច្ចេកវិទ្យានិងប្រព័ន្ធបច្ចេកទេសដែលមិនបង្កការខូចខាតដល់បរិស្ថាន ដូចជាបច្ចេកវិទ្យាកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ បច្ចេកវិទ្យាកាត់បន្ថយការសាយភាយសារធាតុបំពុលបរិស្ថាន បច្ចេកវិទ្យាដែលប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព បច្ចេកវិទ្យាអភិវឌ្ឍន៍ស្អាតសម្រាប់ការកែច្នៃឡើងវិញនិងប្រើប្រាស់ឡើងវិញនូវធនធានដែលបានប្រើប្រាស់រួចហើយ។

**បច្ចេកវិទ្យាល្អបរិស្ថាន Environmentally sound technologies**

បច្ចេកវិទ្យានិងបច្ចេកទេសដែលមានសមត្ថភាពកាត់បន្ថយការបំផ្លាញបរិស្ថានតាមរយៈដំណើរការនិងសម្ភារៈនានា ដែលបញ្ចេញសារធាតុបំផ្លាញតិចតួច កាត់បន្ថយសារធាតុពុលមុននឹងបញ្ចេញមកក្នុងបរិយាកាស ឬប្រើប្រាស់ និងកែច្នៃសំណល់ឡើងវិញ។

**បញ្ជីសារពើភណ្ឌការបញ្ចេញឧស្ម័ន Emission inventory**

របាយការណ៍ដែលផ្តល់ព័ត៌មានលម្អិតស្តីពីប្រភេទនិងបរិមាណសារធាតុបំពុលដែលបញ្ចេញទៅក្នុងបរិស្ថាន។

**បញ្ហាបរិស្ថានទូទៅ Conventional environmental problems**

បញ្ហាបរិស្ថានដែលកើតចេញពីប្រភពច្បាស់លាស់និងត្រូវបានដឹងយ៉ាងច្បាស់លាស់ ដោយមានទំនាក់ទំនងរវាងហេតុនិងផល ដែលជាទូទៅទទួលបានព័ត៌មានពីប្រភពតែមួយ ហើយជនរងគ្រោះច្រើនតែជាអ្នកដែលស្ថិតនៅក្បែរប្រភពបញ្ហានោះ ចំណែកទំហំនៃបញ្ហាតែងតែកើតមាននៅកម្រិតមូលដ្ឋានឬថ្នាក់ជាតិ។

ឧទាហរណ៍ល្អៗជាច្រើនអំពីដំណោះស្រាយបញ្ហាទូទៅ ដូចជា ភាពកខ្វក់ដោយសារមីក្រុប ការលូតលាស់ខ្លាំងនៃសារាយដែលបង្កមហន្តរាយនៅតាមកន្លែងណាមួយ ការបញ្ចេញឧស្ម័នស្ពាន់ធ័រ អាសូត និងភាគល្អិត ការកំពប់ប្រេង តំហយគុណភាពដីនៅមូលដ្ឋាន ការបំផ្លាញទីជម្រកក្នុងតំបន់ណាមួយ បំណែកដីធ្លី និងការធ្វើអាជីវកម្មធនធានទឹកសាបហួសកម្រិត។

**បញ្ហាអន្តរវិស័យ Cross-cutting issue**

បញ្ហានានាដែលកើតឡើងនៅក្នុងវិស័យជាច្រើន ដូចមាននៅក្នុងគោលការណ៍ណែនាំអនុវត្តល្អ។

ការកំណត់និងបរិមាណកម្មនៃ*ភាពមិនប្រាកដប្រជា* ជម្រើសភាគសំណាក ជម្រើសវិធីសាស្ត្រ ដូចជា ការកំណត់អត្តសញ្ញាណផ្នែកសំខាន់ៗ ការធានានិងត្រួតពិនិត្យគុណភាពឱ្យមានសង្គតិភាពទៅតាមពេលវេលានិងការគណនាឡើងវិញ និងការផ្ទៀងផ្ទាត់ ត្រូវបានលើកយកមកដោះស្រាយនៅក្នុងជំពូកដាច់ដោយឡែកដែលគេហៅថា "បញ្ហាអន្តរវិស័យ"។

**បដិវត្តន៍ឧស្សាហកម្ម Industrial revolution**

ដំណាក់កាលមួយដែលឧស្សាហកម្មបានលូតលាស់យ៉ាងឆាប់រហ័ស ដោយរកឃើញគ្រឿងចក្រដើរដោយចំហាយទឹក ដែលផ្លាស់ប្តូរការផលិតដោយដៃទៅគ្រឿងចក្រ នាំឱ្យមានផលវិបាកផ្នែកសង្គមនិងសេដ្ឋកិច្ចយ៉ាងខ្លាំង ដែលចាប់ផ្តើមដំបូងនៅប្រទេសអង់គ្លេសនៅពាក់កណ្តាលទីពីរនៃសតវត្សរ៍ទី១៨ ដល់ជិតពាក់កណ្តាលសតវត្សរ៍ទី១៩ ហើយរាលដាលដល់ទ្វីបអឺរ៉ុបនិងបន្ទាប់មកនៅប្រទេសផ្សេងៗរួមទាំងសហរដ្ឋអាម៉េរិក។

មុនបដិវត្តន៍ឧស្សាហកម្មសំដៅលើការផលិតដោយដៃក្នុងរយៈពេលមុនឆ្នាំ១៧៥០។

**បណ្តាប្រទេសក្នុងឧបសម្ព័ន្ធ១ Annex I countries**

បណ្តាប្រទេសជាសមាជិកអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD)និង*បណ្តាប្រទេសសេដ្ឋកិច្ចអន្តរកាល* ទាំងអស់ ដែលស្ថិតក្នុងឧបសម្ព័ន្ធ១ (ដូចវិសោធនកម្មក្នុងឆ្នាំ១៩៩៨)នៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ*។

**បណ្តាប្រទេសក្នុងឧបសម្ព័ន្ធ២ Annex II countries**

បណ្តាប្រទេសជាសមាជិកអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD)ទាំងអស់ដែលស្ថិតក្នុងឧបសម្ព័ន្ធ២នៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ*។

នៅក្នុងមាត្រា៤.២(g)នៃអនុសញ្ញានេះ បណ្តាប្រទេសទាំងនេះនឹងផ្តល់ធនធានហិរញ្ញវត្ថុដើម្បីជួយបណ្តាប្រទេសកំពុងអភិវឌ្ឍឱ្យអនុវត្តកាតព្វកិច្ចរបស់ពួកគេ ដូចជាការរៀបចំរបាយការណ៍ជាតិជាដើម។ បណ្តាប្រទេសក្នុងឧបសម្ព័ន្ធ២ ក៏នឹងត្រូវជំរុញការផ្ទេរបច្ចេកវិទ្យាបរិស្ថានប្រកបដោយសុវត្ថិភាពដល់បណ្តាប្រទេសកំពុងអភិវឌ្ឍផងដែរ។

**បណ្ដាប្រទេសក្នុងឧបសម្ព័ន្ធ B Annex B countries**

បណ្ដាប្រទេសស្ថិតក្នុងឧបសម្ព័ន្ធ B នៃ *ពិធីសារក្យូតូ* ដែលបានឯកភាពទៅនឹងការកំណត់គោលដៅបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ពួកគេ (ដោយរួមទាំង *បណ្ដាប្រទេសស្ថិតក្នុងឧបសម្ព័ន្ធ១* ទាំងអស់)។

**បណ្ដាប្រទេសសេដ្ឋកិច្ចអន្តរកាល Countries with Economies in Transition (EIT)**

បណ្ដាប្រទេសអឺរ៉ុបកណ្ដាល អឺរ៉ុបខាងកើត និងអតីតសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ដែលស្ថិតក្នុងដំណាក់កាលផ្លាស់ប្ដូរពីសេដ្ឋកិច្ចគ្រប់គ្រងដោយរដ្ឋទៅជាសេដ្ឋកិច្ចទីផ្សារ។

**បណ្ដុំ Bundling**

ការដាក់បញ្ចូលគ្នានៃសកម្មភាពគម្រោងខ្នាតតូចជាច្រើន ដើម្បីបង្កើតបានជាសកម្មភាពគម្រោងធំតែមួយ ឬបញ្ជីគម្រោងស្ថិតក្រោម *យន្តការអភិវឌ្ឍន៍ស្អាត* ក្នុងគោលបំណងកាត់បន្ថយថ្លៃចំណាយប្រតិបត្តិការនានាក្នុងមួយឯកតានៃការកាត់បន្ថយការបញ្ចេញឧស្ម័ន។

**បន្ទេរកម្ដៅតាមខ្សែឈរ Convection**

ចលនាកម្ដៅតាមខ្សែឈរក្រោមឥទ្ធិពលនៃកម្លាំងអណ្ដែត បណ្ដាលមកពីអស្ថិរភាពស្ដាទិក ដោយសារការចុះត្រជាក់នៅជិតផ្ទៃស្រទាប់ខាងលើនៃទឹក ឬកំណើនដាតិប្រៃសម្រាប់ករណីមហាសមុទ្រ និងកំណើនកម្ដៅនៅជិតផ្ទៃខាងលើសម្រាប់ករណីបរិយាកាស។

នៅក្នុង *បរិយាកាស* បន្ទេរកម្ដៅតាមខ្សែឈរជួយបង្កើនពពកនិងកំណាកអាកាស ព្រមទាំងមានប្រសិទ្ធភាពសម្រាប់ប្រភេទគីមីដែលបញ្ជូនទាំងតាមខ្សែឈរនិងរាយប៉ាយ។ នៅក្នុងមហាសមុទ្រ ចលនាតាមខ្សែឈរអាចនាំផ្ទៃទឹកខាងលើទៅកាន់ទីជ្រៅក្នុងមហាសមុទ្របាន។

**បន្ទេរកម្តៅតាមខ្សែដេក Advection**

បន្លាស់ទីនៃទឹកឬខ្យល់រួមជាមួយលក្ខណៈរបស់វា(ដូចជា សីតុណ្ហភាពនិងលក្ខណៈគីមី) តាមរយៈចលនានៃសារធាតុនោះ។ បន្ទេរកម្តៅតាមខ្សែដេក គឺជាការផ្លាស់ទីតាមខ្សែដេកនៃចលនាបរិយាកាសឬមហាសមុទ្រក្នុងទ្រង់ទ្រាយធំ។

**បន្លាស់ទីអែកមេន Ekman transport**

ចលនានៃផ្ទៃទឹកតាមទិសដៅនៃសកម្មភាពខ្យល់បក់នៅលើផ្ទៃទឹក(សមុទ្រ) ដែលកើតចេញពីតុល្យភាពរវាងកម្លាំងសម្ពាធកកិតនិងកូរីយ៉ូលីស(Coriolis)។

**បន្សាំ Adaptation**

ដំណើរការសម្របខ្លួនទៅនឹងអាកាសធាតុបច្ចុប្បន្នឬរំពឹងទុកទៅនឹងឥទ្ធិពលនៃអាកាសធាតុនោះ។

មនុស្សបន្សាំដើម្បីកាត់បន្ថយ*ផលប៉ះពាល់* ឬស្វែងរកឱកាសដែលមានអត្ថប្រយោជន៍។ នៅក្នុងប្រព័ន្ធធម្មជាតិ អន្តរាគមន៍របស់មនុស្សអាចជួយឱ្យមានការសម្របទៅនឹងអាកាសធាតុដែលនឹងកើតឡើងនិងឆ្លើយតបនឹងឥទ្ធិពលរបស់វា។

**បន្សាំគ្រោងទុកជាមុន Anticipatory adaptation**

សកម្មភាពបន្សាំដែលធ្វើឡើងនៅមុនពេលកើតមាន*ផលប៉ះពាល់* បណ្តាលមកពី*ការប្រែប្រួលអាកាសធាតុ*។

**បន្សាំជាបន្ទាន់ Reactive adaptation**

*បន្សាំ*ធ្វើឡើងភ្លាមៗបន្ទាប់ពីកើតមានផលប៉ះពាល់នៃ*ការប្រែប្រួលអាកាសធាតុ*។

**បន្សាំស្វយ័ត Autonomous adaptation**

បន្សាំក្នុងការឆ្លើយតបទៅនឹងអាកាសធាតុដែលធ្លាប់ជួបប្រទះនិងផលប៉ះពាល់របស់វា ដោយគ្មានការរៀបចំផែនការច្បាស់លាស់ឬដឹងជាមុន ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ។

**បន្សុំាសាធារណៈ Public adaptation**

*បន្សុំា* ដែលផ្តួចផ្តើមនិងអនុវត្តដោយរដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់ ដែលជាទូទៅ ដើម្បីបំពេញតម្រូវការសមូហភាព។

**បន្សុំាតាមផែនការ Planned adaptation**

*បន្សុំា* ដែលជាលទ្ធផលនៃការធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយ ដោយផ្អែកលើការយល់ដឹងអំពីលក្ខខណ្ឌដែលបានប្រែប្រួលឬអាចនឹងប្រែប្រួល ហើយសកម្មភាពបន្សុំានេះតម្រូវឱ្យរក្សានិងសម្រេចបាននូវលក្ខខណ្ឌដែលចង់បាន។

**បន្សុំាផ្អែកលើសហគមន៍ Community-based adaptation**

បន្សុំានៅមូលដ្ឋានដែលផ្តោតការយកចិត្តទុកដាក់លើការពង្រឹងអំណាចនិងការលើកកម្ពស់សមត្ថភាពបន្សុំារបស់សហគមន៍។

នេះជាវិធានដែលត្រូវធ្វើឡើងដោយផ្អែកលើបរិបទវប្បធម៌ ចំណេះដឹង ស្ថាប័ន និងការនិយមរបស់សហគមន៍ ដែលចាត់ទុកថាជាចំណុចខ្លាំងនៃ *បន្សុំា* ។

**បន្សុំាលក្ខណៈឯកជន Private adaptation**

*បន្សុំា* ដែលផ្តួចផ្តើមនិងអនុវត្តជាលក្ខណៈបុគ្គល គ្រួសារ ឬក្រុមហ៊ុនឯកជន ដែលជាទូទៅ ធ្វើឡើងដោយការចាប់អារម្មណ៍របស់បុគ្គលខ្លួនឯង។

**បរិធានមាត្រ Allometry**

ការសិក្សាអំពីទំនាក់ទំនងរវាងទំហំនិងរូបរាងរបស់សារពាង្គកាយ ហើយក្នុងវិស័យព្រៃឈើ បរិធានមាត្រ សំដៅលើទំនាក់ទំនងរវាងអង្កត់ផ្ចិតដើមឈើ កម្ពស់គម្របព្រៃ និងជីវម៉ាស។

**បរិយាកាស Atmosphere**

ស្រទាប់ឧស្ម័នច្រើនជាន់ដែលគ្របដណ្តប់ជុំវិញផែនដី។

បរិយាកាសស្ងួតផ្សំស្ទើរទាំងស្រុងពីល្បាយនៃឧស្ម័នអាសូត៧៨,១%នៃល្បាយគិតជាមាឌ អុកស៊ីសែន២០,៩%នៃល្បាយគិតជាមាឌ និង *ឧស្ម័នកម្រ* មួយចំនួនទៀត ដូចជា អាកុង០,៩៣%នៃល្បាយគិតជាមាឌ អេល្យូម និងឧស្ម័នផ្ទះកញ្ចក់ ដូចជា *ឧស្ម័នកាបូនិក* ០,០៣៥%នៃល្បាយគិតជាមាឌ និងអូសូន។ល។ លើសពីនេះ

បរិយាកាសក៏ផ្សំឡើងពី*ចំហាយទឹក* ដែលជាឧស្ម័នផ្ទះកញ្ចក់មួយប្រភេទមានបរិមាណប្រែប្រួលខ្លាំង ប៉ុន្តែមានប្រមាណ១%ប៉ុណ្ណោះ។

បរិយាកាសក៏ផ្សំឡើងពីពពកនិង*អាអេរ៉ូសូល* ផងដែរ។

**បរិយាកាសសេរី Free atmosphere**

ស្រទាប់បរិយាកាសដែលរងឥទ្ធិពលតិចតួចបំផុតពីកម្លាំងកកិតជាមួយផ្ទៃផែនដី ហើយដែលមានរយៈកម្ពស់ ចន្លោះពី១ ០០០ម៉ែត្រទៅ១១ ០០០ម៉ែត្រ។

**ប៉ារ៉ាម៉ែត្រផលតបអាកាសធាតុ Climate feedback parameter**

តម្លៃរបស់អថេរដែលបានមកពីការគណនាផលតបវិកាយរស្មីនៃប្រព័ន្ធអាកាសធាតុទៅនឹងការប្រែប្រួលសីតុណ្ហភាពផ្ទៃផែនដីដែលបង្កឡើងដោយកម្លាំងវិកាយរស្មី( ឯកតា$Wm^{-2}\ ^0C^{-1}$ )។

ប៉ារ៉ាម៉ែត្រផលតបអាកាសធាតុ($\Lambda$) កំណត់ដោយរូបមន្ត $\Lambda=(\Delta Q-\Delta F)/\Delta T$ ដែល Q ជាឥទ្ធិពលកម្លាំងវិកាយរស្មីមធ្យមផែនដី, T ជាសីតុណ្ហភាពមធ្យមនៃខ្យល់នៅលើផ្ទៃផែនដី, F ជាចំណាំងចូលនៃភ្លចកម្ដៅទៅក្នុងមហាសមុទ្រ និង Δ តំណាងឱ្យការប្រែប្រួលជាមួយអាកាសធាតុដែលមានលំនឹង។

**បុរេករ Precursors**

សមាសធាតុ*បរិយាកាស* ដែលមិនមែនជាឧស្ម័នផ្ទះកញ្ចក់ឬ*អាអេរ៉ូសូល* ប៉ុន្តែមានឥទ្ធិពលទៅលើកំហាប់ឧស្ម័នផ្ទះកញ្ចក់ឬ*អាអេរ៉ូសូល* ដោយការចូលរួមនៅក្នុងដំណើរការរូបសាស្ត្រឬគីមី ដើម្បីកំណត់អត្រាបង្កើតឬបំផ្លាញឬកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ឬ*អាអេរ៉ូសូល*។

**ប៉េហាស់ pH**

រង្វាស់គ្មានខ្នាតសម្រាប់បង្ហាញពីកម្រិតអាស៊ីតឬបាសរបស់សូលុយស្យុង ដែលស្ដែងចេញជាកំហាប់អ៊ីយ៉ុងអ៊ីដ្រូសែន( $H^+$ )។

ប៉េហាស់ត្រូវបានវាស់វែងលើមាត្រដ្ឋានឡូការីត $pH=-\log_{10}(H^+)$។ ដូច្នេះ ការថយចុះប៉េហាស់មួយឯកតាស្មើនឹងកំណើន១០ដងនៃកំហាប់$H^+$ ឬកម្រិតអាស៊ីត។ បើ pH = ៧,០ គឺជាសូលុយស្យុងណឺត។

**ប្រព័ន្ធចាប់យកព័ត៌មានពីលំហអាកាស Remote sensing**

ការចាប់យកតាមបែបវិទ្យាសាស្ត្រនូវព័ត៌មានអំពីវត្ថុឬបាតុភូតមួយពីលំហអាកាសដោយប្រើយន្តហោះឬផ្កាយរណប ដោយមិនចាំបាច់ទាក់ទងផ្ទាល់ជារូបវន្តទៅនឹងវត្ថុនោះ ដែលផ្ទុយពីការអង្កេតផ្ទាល់។

**ប្រព័ន្ធឌីណាមិក Dynamical system**

ដំណើរការមួយឬបង្គុំដំណើរការដែលវិវត្តទៅតាមពេលវេលានិងស្ថិតនៅក្រោមឥទ្ធិពលនៃច្បាប់រូបវិទ្យាជាក់លាក់។

*ប្រព័ន្ធអាកាសធាតុ* គឺជាប្រព័ន្ធឌីណាមិកមួយ។

**ប្រព័ន្ធប្រកាសអាសន្ន Early warning system**

បណ្តុំសមត្ថភាពដែលត្រូវការជាចាំបាច់សម្រាប់បង្កើតនិងផ្សព្វផ្សាយព័ត៌មានប្រកាសអាសន្នឱ្យបានទាន់ពេលវេលា និងមានអត្ថន័យច្បាស់លាស់ ដើម្បីឱ្យបុគ្គលម្នាក់ សហគមន៍ និងអង្គការនានា ដែលធ្លាប់ទទួលរងការគំរាមកំហែងដោយ*មុខសញ្ញាគ្រោះថ្នាក់* អាចត្រៀមលក្ខណៈនិងធ្វើសកម្មភាពសមស្រប ព្រមទាំងមានពេលវេលាគ្រប់គ្រាន់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ឬការបាត់បង់ដែលអាចកើតមាន។

**ប្រព័ន្ធអាកាសធាតុ Climate system**

ប្រព័ន្ធស្មុគស្មាញខ្លាំងដែលមានសមាសភាគចម្បងចំនួនប្រាំ គឺ *បរិយាកាស មណ្ឌលទឹក មណ្ឌលកំណក* ផ្ទៃដី និង*ជីវមណ្ឌល* ដែលមានអន្តរកម្មរវាងគ្នាទៅវិញទៅមក។

ប្រព័ន្ធអាកាសធាតុវិវត្តទៅតាមពេលវេលានៅក្រោមឥទ្ធិពលឌីណាមិកផ្ទៃក្នុងរបស់ខ្លួន និងវិវត្តដោយសារកម្លាំងពីខាងក្រៅដូចជា បន្ទុះភ្នំភ្លើង ការប្រែប្រួលពន្លឺព្រះអាទិត្យ និងដោយសកម្មភាពមនុស្សដែលបណ្តាលឱ្យមានការប្រែប្រួលសមាសធាតុក្នុងបរិយាកាស ការប្រែប្រួលការប្រើប្រាស់ដី ជាដើម។

**ប្រភព Source**

ដំណើរការ សកម្មភាព ឬយន្តការណាមួយដែលបញ្ចេញ *ឧស្ម័នផ្ទះកញ្ចក់* *អាអេរ៉ូស៊ូល* ឬ*បុរេកនៃឧស្ម័នផ្ទះកញ្ចក់* ឬនៃ*អាអេរ៉ូស៊ូល*ទៅក្នុងបរិយាកាស។

**ប្រភាគម៉ូល Mole fraction**

អនុបាត(ratio) នៃចំនួនម៉ូលនៃសមាសភាគមួយក្នុងបរិមាណកំណត់ធៀបទៅនឹងចំនួនម៉ូលសរុបនៃសមាសភាគទាំងអស់ក្នុងបរិមាណនោះ។

តាមធម្មតា គេប្រើបំណែកជាម៉ូលសម្រាប់រាយការណ៍អំពីខ្យល់ស្ងួត។ ចំពោះ *ឧស្ម័នផ្ទះកញ្ចក់* ដែលមានអាយុកាលវែងមានខ្នាតតាមលំដាប់ដូចជា mmol/mol (មួយភាគលាន : ppm), nmol/mol (មួយភាគប៊ីលាន : ppb), និង fmol/mol (មួយភាគទ្រីលាន : ppt)។ បំណែកជាម៉ូលខុសពីសមាមាត្រល្បាយជាមាឌ ដែលគិតជា ppmv ។ល។ ដោយការកែតម្រូវឧស្ម័នទៅក្នុងលក្ខខណ្ឌធម្មតា។ កំណែតម្រូវនេះមានសារៈសំខាន់ណាស់ពាក់ព័ន្ធនឹងសុក្រឹតភាពនៃការវាស់វែង *ឧស្ម័នផ្ទះកញ្ចក់* ជាច្រើន។

**ប្រសិទ្ធផលថាមពល Energy efficiency**

អនុបាត(ratio)ថាមពលចេញដែលមានអត្ថប្រយោជន៍របស់ប្រព័ន្ធមួយដែលបានមកពី ដំណើរការឬសកម្មភាព បំប្លែងធៀបទៅនឹងថាមពលចូលរបស់ប្រព័ន្ធនោះ។

**ប្រហោងអូសូន Ozone hole**

ការធ្លាក់ចុះយ៉ាងខ្លាំងនៃកំហាប់អូសូនក្នុង *មណ្ឌលអាកាសស្ងប់* ដែលកើតឡើងនៅទ្វីបអង់តាកទិក ជាទូទៅ នៅចន្លោះខែសីហានិងវិច្ឆិកា។

ប្រហោងអូសូនត្រូវបានរកឃើញដំបូងនៅចុងទសវត្សរ៍ទី៨នៃសតវត្សរ៍ទី២០ ហើយប្រហោងនេះបានបន្តកើតមានជារៀងរាល់ឆ្នាំ។

**ប្លង់តុង Plankton**

មីក្រូសារពាង្គកាយដែលរស់នៅក្នុងស្រទាប់លើនៃប្រព័ន្ធទឹក ហើយមិនអាចធ្វើចលនាបញ្ច្រាសចរន្តទឹកបានទេ។

**ប្លង់តុងសត្វ Zooplankton**

ប្លង់តុងក្នុងទម្រង់ជាសត្វដែលស៊ីប្លង់តុងរុក្ខជាតិឬប្លង់តុងសត្វដទៃទៀតជាអាហារ។

# ផ

**ផលតបពពក Cloud feedback**

ផលតបអាកាសធាតុពាក់ព័ន្ធនឹងការប្រែប្រួលផ្នែកខ្លះនៃគុណភាពពពកដែលឆ្លើយតបទៅនឹងការប្រែប្រួលបរិយាកាសផ្សេងៗ។ ការស្វែងយល់អំពីផលតបពពក និងការកំណត់ទំហំនិងសញ្ញារបស់វា ទាមទារឱ្យមានការយល់ដឹង ថាតើការប្រែប្រួលអាកាសធាតុប្រហែលប៉ះពាល់ដល់វិសាលគមន៍នៃប្រភេទពពក បំណែក និងកម្ពស់គុណភាពនៃចំណាំង រស្មីរបស់វា ហើយការប៉ាន់ប្រមាណអំពីឥទ្ធិពលនៃការប្រែប្រួលទាំងនេះទៅលើលំនឹងថាមពលដែលបញ្ចេញរំភាយរស្មីរបស់ផែនដីយ៉ាងដូចម្តេច នាពេលបច្ចុប្បន្ននេះ ផលតបពពកក៏នៅតែជាប្រភពដ៏ធំមួយនៃភាពមិនប្រាកដប្រជាទៅនឹងភាពរួសនៃអាកាសធាតុដែលបានប្រមើលឃើញ។

**ផលតបអាកាសធាតុ Climate feedback**

ដំណើរការដែលអាចបង្កើនឬបន្ថយឥទ្ធិពលនៃកម្លាំងអាកាសធាតុ។

ផលតបដែលបង្កើនកម្តៅដំបូងត្រូវបានហៅថា "ផលតបវិជ្ជមាន" ហើយផលតបដែលបន្ថយកម្តៅដំបូងត្រូវបាន ហៅថា "ផលតបអវិជ្ជមាន"។

**ផលតបអាល់បេដូ Albedo feedback**

ផលតបអាកាសធាតុដែលជាប់ពាក់ព័ន្ធនឹងការប្រែប្រួលអាល់បេដូរបស់ផែនដី ហើយជាទូទៅ ជាការប្រែប្រួលរបស់*មណ្ឌលកំណក* ដែលមានកម្រិតអាល់បេដូខ្ពស់(≈0,៨) ធៀបនឹងកម្រិតអាល់បេដូមធ្យមនៃផ្ទៃផែនដី(≈0,៣)។

ក្នុងលក្ខខណ្ឌអាកាសធាតុក្តៅជាងមុន *មណ្ឌលកំណក* ត្រូវបានប្រមើលមើលឃើញថានឹងរួមតូច ហើយអាល់បេដូទាំងមូលរបស់ផែនដីនឹងថយចុះឬរួម

តូច ហើយធ្វើឱ្យផ្ទៃផែនដីនឹងស្រូបយក*វិកាយរស្មីព្រះអាទិត្យ* កាន់តែច្រើនឡើង នាំឱ្យមានកំណើនកម្ដៅក្នុងផែនដីកាន់តែខ្លាំង។

**ផលបន្ថែម Additionality**

ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពី *ប្រភពបញ្ចេញ* ឬការបង្កើនការស្រូបយកឧស្ម័នផ្ទះកញ្ចក់ដោយ*អាងបង្ខាំង* ដែលជាការបន្ថែមទៅនឹងអ្វីដែលអាចកើតឡើង ក្នុងករណីអវត្តមានសកម្មភាពគម្រោង*ការអនុវត្តរួមគ្នា* ឬ*យន្តការអភិវឌ្ឍន៍ស្អាត* ដូចដែលបានចែងក្នុងមាត្រានៃពិធីសារក្យូតូស្ដីពី*ការអនុវត្តរួមគ្នា* និងក្នុង *យន្តការអភិវឌ្ឍន៍ស្អាត*។

ពាក្យនេះអាចត្រូវបានប្រើប្រាស់ទូលំទូលាយដោយគ្របដណ្ដប់លើផ្នែកហិរញ្ញ-វត្ថុ វិនិយោគ និងបច្ចេកវិទ្យា។

**ផលប៉ះពាល់(នៃការប្រែប្រួលអាកាសធាតុ) (Climate Change) Impact**

ឥទ្ធិពលនៃ*ការប្រែប្រួលអាកាសធាតុ* មកលើប្រព័ន្ធធម្មជាតិនិងមនុស្ស។

ដោយផ្អែកលើការពិចារណាពី*បន្សាំ* គេអាចបង្ហាញភាពខុសគ្នារវាងផលប៉ះពាល់ជាសក្ដានុពលនិងផលប៉ះពាល់ដែលនៅសេសសល់ ដូចខាងក្រោម៖

- ផលប៉ះពាល់ជាសក្ដានុពល : ផលប៉ះពាល់ទាំងអស់ដែលអាចកើតឡើងនៅក្នុងការព្យាករការប្រែប្រួលអាកាសធាតុដោយមិនគិតពី*បន្សាំ*។
- ផលប៉ះពាល់ដែលនៅសេសសល់ : ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលអាចកើតឡើងបន្ទាប់ពី*បន្សាំ*។

**ផលប៉ះពាល់ផ្គួន Cumulative impacts**

ផលប៉ះពាល់បរិស្ថាននិង/ឬផលប៉ះពាល់ដែលពាក់ព័ន្ធនឹងអាកាសធាតុ កើតចេញពីគម្រោងអភិវឌ្ឍន៍ផ្សេងគ្នា ដែលបន្ថែមទៅលើផលប៉ះពាល់នៃការអភិវឌ្ឍដែលមានស្រាប់។

ផលប៉ះពាល់នីមួយៗអាចនឹងមិនបង្កបញ្ហាធំដុំទេ ប៉ុន្តែបើសរុបផលប៉ះពាល់នីមួយៗបញ្ចូលគ្នាអាចបង្កជាបញ្ហាធ្ងន់ធ្ងរ។

**ផលប៉ះពាល់សរុប Aggregate impacts**

ផលប៉ះពាល់ដែលរួមបញ្ចូលផលប៉ះពាល់គ្រប់វិស័យនិង/ឬតំបន់នានា។

ដើម្បីវាយតម្លៃផលប៉ះពាល់នេះបានទាមទារឱ្យមានចំណេះដឹង(ឬការសន្មត) អំពីសារៈសំខាន់ធៀបនៃផលប៉ះពាល់ផ្សេងៗគ្នា។ ឧទាហរណ៍ : ចំនួនប្រជាជនសរុបដែលទទួលរងផលប៉ះពាល់ឬតម្លៃសេដ្ឋកិច្ចសរុប ហើយជាទូទៅអាស្រ័យនឹងពេលវេលា ទីកន្លែង និង/ឬទៅតាមវិស័យ។

**ផលប្រយោលអាអេរ៉ូសូល Indirect aerosol effect**

*កម្លាំងវិកាយរស្មី* ប្រយោលបង្កឡើងដោយអាអេរ៉ូសូលក្នុង*ប្រព័ន្ធអាកាសធាតុ* តាមរយៈការដើរតួជា*ស្នូលកំណកពពក* ឬតាមរយៈការកែប្រែគុណភាពអុបទិក និងអាយុកាលពពក។ ផលប្រយោលមានពីរខុសគ្នាគឺ៖

- ផលប្រយោលទី១ ឥទ្ធិពលបញ្ចេញថាមពលនៃកម្លាំងវិកាយរស្មីដែលកើតឡើងដោយសារកំណើន *អាអេរ៉ូសូល* ពីសកម្មភាពមនុស្ស និងបង្កឱ្យមានកំណើនកំហាប់តំណក់ទឹកដំបូង ហើយថយចុះទំហំតំណក់ទឹកនៅតាមសមាសភាពទឹករាវ ដែលនាំឱ្យមានកំណើនអាល់បេដូពពក។ បាតុភូតនេះហៅថា ផលប្រយោលទី១ ឬផលថូមី (Twomey)។
- ផលប្រយោលទី២ ឥទ្ធិពលបញ្ចេញថាមពលនៃកម្លាំងវិកាយរស្មីមួយកើតឡើងពីអាអេរ៉ូសូលដោយសារមនុស្សដែលនាំឱ្យមានការថយចុះតំណក់ទឹកនិងប្រសិទ្ធភាពភ្លៀង ជាហេតុធ្វើឱ្យមានកំណែប្រែសមាសធាតុទឹករាវ កម្រាស់ពពក និងអាយុកាលពពក។ ឥទ្ធិពលនេះហៅថា ផលប្រយោលទីពីរ ឬផលអាយុកាលពពក ឬផលអាលប្រិច(Albrecht)។

**ផលផ្ទះកញ្ចក់ Greenhouse effect**

បាតុភូតនៃកំណើនសីតុណ្ហភាពខ្យល់នៅក្នុងលំហបិទជិតដោយកញ្ចក់ ឬកៅស៊ូប្លាស្ទិកថ្លា ដែលអនុញ្ញាតឱ្យ*វិកាយរស្មីព្រះអាទិត្យ* ឆ្លងកាត់ចូល តែមិនអាចឱ្យវិកាយរស្មីដែលមានជំហានរលកវែង ឆ្លងកាត់ចេញវិញបាន។

ពាក្យនេះត្រូវបានយកមកប្រើ ដើម្បីសម្គាល់បាតុភូតស្រដៀងគ្នានេះ ដែលកើតមាននៅក្នុង *បរិយាកាស* ផែនដី។ អ្នកប្រាជ្ញភាគច្រើនអះអាងថា កំណើនកម្ដៅគួរឱ្យកត់សម្គាល់ចាប់ពីដើមសតវត្សរ៍នេះ បណ្ដាលមកពីកំណើននៃ *ឧស្ម័នកាបូនិក ឧស្ម័នក្លរ៉ូភ្លុយអរ៉ូកាបូ មេតាន ឌីអាសូតម៉ូណូអុកស៊ីត*។ល។ ដែលប្រៀបដូចផ្ទះកញ្ចក់ មានប្រភពពីសកម្មភាពមនុស្ស ពិសេសពីការដុត *ឥន្ធនៈហ្វូស៊ីល* ។ នៅពេលដែលស្រទាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសកើនលើសពីកម្រិតធម្មជាតិ កម្ដៅដែលចាំងផ្លាតពីផែនដីទៅ ពុំអាចចេញទៅក្នុងបរិយាកាសស្រទាប់លើបាន ហើយចាំងខ្ទាតមកផែនដីវិញ ដែលជាមូលហេតុនៃកំណើនសីតុណ្ហភាពខ្យល់នៅក្នុងបរិយាកាសស្រទាប់ក្រោម។

**ផលលាក់កំបាំង Lock-in effect**

ការចែកបន្តបច្ចេកវិទ្យាដែលគ្របដណ្ដប់ចំណែកទីផ្សារធំៗនិងបានមកពីការស្រាវជ្រាវយ៉ាងលំបាក ត្រូវបន្តប្រើប្រាស់ដោយសារកត្តាមួយចំនួន ដូចជា ថ្លៃចំណាយវិនិយោគដែលបានកប់បាត់ ការស្រូបកាបូន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ការប្រើប្រាស់បច្ចេកវិទ្យាបន្ថែមនិងរចនាសម្ព័ន្ធ និងទម្លាប់ក្នុងសង្គមនិងស្ថាប័នពាក់ព័ន្ធ។

**ផលិតកម្មបឋមសុទ្ធ Net Primary Production (NPP)**

កំណើន *ជីវម៉ាស* ពីរុក្ខជាតិឬកាបូនក្នុងមួយឯកតានៃទេសភាពមួយ។

ផលិតកម្មបឋមសុទ្ធស្មើនឹងផលិតកម្មបឋមដុល ដកបរិមាណកាបូនដែលបាត់បង់តាមរយៈ *ដំណកដង្ហើមភាវៈស្វ័យជីព* ។

**ផលិតកម្មប្រព័ន្ធអេកូឡូស៊ីសុទ្ធ Net Ecosystem Production (NEP)**

ការកើនឡើងសុទ្ធឬការថយចុះសុទ្ធនៃកាបូនពី *ប្រព័ន្ធអេកូឡូស៊ី* មួយ។

ផលិតកម្មអេកូឡូស៊ីសុទ្ធស្មើនឹង *ផលិតកម្មបឋមសុទ្ធ* ដកបរិមាណកាបូនដែលបាត់បង់តាមរយៈ *ដំណកដង្ហើមភាវៈបរជីព* ។

**ផ្ទាំងទឹកកក Ice shelf**

បំណែកទឹកកកអណ្តែតយ៉ាងធំ មានកម្រាស់ក្រាស់ លាតសន្ធឹងចេញពីឆ្នេរសមុទ្រ (តាមធម្មតាមានវិសាលភាពធំតាមខ្សែដេកដោយមានចំណោតឬផ្ទៃទេរតិចៗ) ហើយភាគច្រើនមាននៅពេញឆកសមុទ្រដែលមានស្រទាប់ទឹកកក។

ផ្ទាំងទឹកកកស្ទើរតែទាំងអស់ស្ថិតនៅទ្វីបអង់តាកទិច ដាកន្លែងដែលផ្ទាំងទឹកកកភាគច្រើនហូរចូលក្នុងសមុទ្រ។

**ផែនការជាតិបន្សាំ National Adaptation Plans (NAPs)**

ផែនការដែលរៀបចំឡើងដោយជាតិនីមួយៗ (ប្រទេសក្រោម *អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ*) ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដោយកំណត់នូវតម្រូវការបន្សាំរយៈពេលវែងនិងមធ្យម ព្រមទាំងការអភិវឌ្ឍយុទ្ធសាស្ត្រនិងកម្មវិធីនានា សំដៅដោះស្រាយតម្រូវការទាំងនោះ ក្នុងដំណើរការដែលមានលក្ខណៈរីកចម្រើននិងសាចុះសាឡើង ស្របនឹងអតិក្រមនៃប្រទេសនីមួយៗ ដោយគិតដល់យេនឌ័រ ការចូលរួម និងតម្លាភាពពេញលេញ ហើយដោយផ្អែកលើក្របខណ្ឌបន្សាំទីក្រុងកាន់គុន ប្រទេសម៉ិកស៊ិក។

**ផែនការសកម្មភាពជាតិ National Action Plans (NAPs)**

ផ្នែកមួយនៃ *សេចក្តីជូនដំណឹងជាតិ* រួមបញ្ចូលទាំងសារពើភណ្ឌប្រភពនិង *អាងស្រូប* ឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ។

ផែនការនេះត្រូវដាក់ជូន *សន្និសីទបណ្តាភាគី* ដើម្បីបង្ហាញអំពីជំហាននៃការដាក់កម្រិតលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពមនុស្ស។ ភាគីត្រូវបញ្ជូនផែនការទាំងនេះជាលក្ខខណ្ឌក្នុងការចូលរួម *អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ* ហើយបន្ទាប់មក ភាគីត្រូវរាយការណ៍អំពីវឌ្ឍនភាពរបស់ខ្លួនជាប្រចាំទៅកាន់ *សន្និសីទបណ្តាភាគី* ។

**ផែនទឹកកក Glacier**

គំនរផ្ទាំងដែនទឹកកកមាននៅគ្រប់រដូវនិងកើតពីលំណែនព្រឹល ដែលបង្ហាញពីភស្តុតាងនៃលំហូរអតីតកាល ឬបច្ចុប្បន្នកាល(តាមរយៈការប្រែរូបរាងខាងក្នុងនិង/ឬការរអិលនៅផ្នែកខាងក្រោម) ហើយការជាប់ក្នុងស្ថានភាពបែបនេះ គឺដោយសារការសង្កត់និងកម្លាំងកកិតនៃផ្ទៃបាត។

ផែនទឹកកកមួយអាចនៅស្ថិតស្ថេរបានដោយសារកំណើនគំនរនៃព្រឹលនៅរយៈកម្ពស់ខ្ពស់ និងអាចមានតុល្យភាពរវាងការរលាយទឹកកកនៅរយៈកម្ពស់ទាបនិង/ឬការហូរចូលមហាសមុទ្រ។ គំនរផ្ទាំងទឹកកកមានប្រភពជាមួយផែនទឹកកកដែលមានទំហំប៉ុនទ្វីបណាមួយ ត្រូវបានហៅថា *ស្រទាប់ទឹកកក*។ គ្រប់គំនរផ្ទាំងទឹកកកទាំងអស់ក្រៅពីស្រទាប់ទឹកកកត្រូវបានហៅថា ផែនទឹកកក។

# ឝ

**ពន្ធលើការបញ្ចេញឧស្ម័ន Emission tax**

ពន្ធដែលរដ្ឋាភិបាលកំណត់សម្រាប់មួយឯកតានៃការបញ្ចេញ*សមមូលឧស្ម័នកាបូនិក*ពីប្រភពដែលជាប់ពន្ធ។ ពន្ធដែលទាក់ទងនឹងពន្ធលើការបញ្ចេញឧស្ម័នមានដូចតទៅ៖ ដោយសារកាបូនទាំងអស់នៅក្នុងឥន្ទនៈហ្វូស៊ីលបញ្ចេញឧស្ម័នកាបូនិក ដូច្នេះពន្ធលើឥន្ទនៈហ្វូស៊ីលផ្ទុកកាបូន ត្រូវបានគេហៅថា ពន្ធកាបូនដែលសមមូលនឹងពន្ធលើការបញ្ចេញចំហេះឥន្ទនៈហ្វូស៊ីល។ ពន្ធលើថាមពលជាពន្ធលើបរិមាណថាមពលដែលបានប្រើប្រាស់ឥន្ទនៈ ដើម្បីជួយកាត់បន្ថយតម្រូវការថាមពល ទើបអាចជួយកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិកពីការប្រើប្រាស់ឥន្ទនៈហ្វូស៊ីល។ ពន្ធបៃតង(ecotax) ត្រូវបានបង្កើតឡើងក្នុងគោលដៅកែប្រែឥរិយាបថរបស់មនុស្ស(ជាពិសេស ឥរិយាបថផ្នែកសេដ្ឋកិច្ច) ដើម្បីឱ្យគោរពតាមគោលការណ៍ដែលមានមេត្រីភាពជាមួយបរិស្ថាន។ ពន្ធអន្តរជាតិទៅលើការបញ្ចេញ/កាបូន/ថាមពល គឺជាពន្ធដែលរឹតបន្តឹងដោយទីភ្នាក់ងារអន្តរជាតិទៅលើប្រភពបញ្ចេញជាក់លាក់សម្រាប់ប្រទេសជាភាគីចូលរួម។

**ពិធីសារក្យូតូ Kyoto Protocol**

កិច្ចព្រមព្រៀងអន្តរជាតិដែលបានអនុម័តនៅទីក្រុងក្យូតូ(ប្រទេសជប៉ុន) ក្នុងខែធ្នូ ឆ្នាំ១៩៩៧ បន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ ហើយដែលតម្រូវឱ្យប្រទេសជឿនលឿននិងប្រទេសសេដ្ឋកិច្ចអន្តរកាលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់( *ឧស្ម័នកាបូនិក មេតាន ឌីអាសូតម៉ូណូអុកស៊ីត អ៊ីដ្រូភ្លុយអរ៉ូកាបួ ពែភ្លុយអរ៉ូកាបួ* និងស៊ុលភួអ៊ិចសាភ្លុយអរីត)

យ៉ាងហោចណាស់ឱ្យបាន៥% ក្រោមកម្រិតគោលឆ្នាំ១៩៩០ នៅក្នុងរយៈពេលពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២។

ពិធីសារក្យូតូនេះចូលជាធរមាននៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥។

**ពិធីសារម៉ុងរ៉េអាល់ Montreal Protocol**

កិច្ចព្រមព្រៀងអន្តរជាតិស្តីពីការការពារស្រទាប់អូសូន ដោយតម្រូវឱ្យមានការគ្រប់គ្រងការប្រើប្រាស់និងការផលិតសារធាតុគីមីផ្ទុកពពួកក្លរនិងប្រូម ដែលបំផ្លាញ *ស្រទាប់អូសូន* នៅ*មណ្ឌលអាកាសស្ងប់* ដូចជា *ក្លរ៉ូភ្លុយអរ៉ូកាបួ* មេទីលក្លរ៉ូហ្វម កាបូនតេត្រាក្លរួ និងសារធាតុផ្សេងទៀតជាច្រើន ហើយត្រូវបានអនុម័តនៅទីក្រុងម៉ុងរ៉េអាល់នៃប្រទេសកាណាដាក្នុងឆ្នាំ១៩៨៧។

ពិធីសារម៉ុងរ៉េអាល់ស្តីពី*សារធាតុបំផ្លាញស្រទាប់អូសូន* ត្រូវបានកែសម្រួលនិងធ្វើវិសោធនកម្មជាបន្តបន្ទាប់នៅទីក្រុងឡុងដ៍(១៩៩០) ទីក្រុងកូប៉ិនហាក(១៩៩២) ទីក្រុងវីយែន(១៩៩៥) ទីក្រុងម៉ុងរ៉េអាល់(១៩៩៧) និងទីក្រុងប៉េកាំង(១៩៩៩)។ល។

**ពែរភ្លុយអរ៉ូកាបួ Perfluorocarbons (PFCs)**

ឧស្ម័នផ្ទះកញ្ចក់មួយប្រភេទក្នុងចំណោម *ឧស្ម័នផ្ទះកញ្ចក់* ទាំង៦ដែលត្រូវកាត់បន្ថយក្រោម*ពិធីសារក្យូតូ* ហើយជាផលិតផលបន្ទាប់បន្សំដែលត្រូវកើតឡើងដោយការរំលាយអាលុយមីញ៉ូមនិងការបន្សុទ្ធអ៊ុយរ៉ាញ៉ូម។

ពែរភ្លុយអរ៉ូកាបួ ក៏ត្រូវបានប្រើជំនួស*ក្លរ៉ូភ្លុយអរ៉ូកាបួ* ក្នុងការផលិតសារធាតុអឌ្ឍចម្លង(សឺមីកុងឌុចទ័រ semiconductors)។

**ព្យុះស៊ីក្លូនក្រៅតំបន់ត្រូពិក Extratropical cyclone**

ខ្យល់ព្យុះមានទ្រង់ទ្រាយធំ(ក្នុងរង្វង់អង្កត់ផ្ចិត១ ០០០គ.ម.) នៅតំបន់ដែលមានរយៈទទឹងមធ្យមឬខ្ពស់ ដែលព្យុះនេះមានសម្ពាធខ្សោយនៅចំណុចកណ្តាលចំណែកខាងមុខមានសីតុណ្ហភាពនិងសំណើមខ្ពស់តាមខ្សែដេក។

ព្យុះនេះគឺជាមូលហេតុចម្បងដែលនាំឱ្យមានល្បឿនខ្យល់ខ្លាំងខុសប្រក្រតី និងការធ្លាក់កំណកអាកាសខ្លាំង ជាពិសេស នៅសិសិររដូវ។

**ព្រឹត្តិការណ៍ដានហ្គាតអូហ្គី Dansgaard-Oeschger events**

ហេតុការណ៍អាកាសធាតុភ្លាមៗដែលបានសង្កេតឃើញដំបូងនៅក្នុង *ស្នូលទឹកកក* នៃតំបន់ហ្គ្រីនលែននិងក្នុងកំណត់ត្រា*អាកាសធាតុកាលបុរាណ* ចាប់ពីតំបន់ក្បែរអាត្លង់ទិកខាងជើង ដោយមានស្ថានភាពត្រជាក់ពី*ផែនទឹកកក* បន្ទាប់មកប្រែទៅជាក្ដៅយ៉ាងលឿន ហើយបែរជាចុះត្រជាក់សន្សឹមៗមកស្ថានភាពផែនទឹកកកវិញ។

ព្រឹត្តិការណ៍ដានហ្គាតអូហ្គី ក៏ត្រូវបានសង្កេតឃើញកើតមាននៅតំបន់ផ្សេងៗទៀតដែរ។

**ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ Extreme weather event**

ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីមួយដែលកម្រកើតមានឡើងនៅទីកន្លែង និងពេលណាមួយ ដូចជា ភាពរាំងស្ងួតខ្លាំង ភ្លៀងធ្លាក់ខ្លាំង ជាដើម ហើយដែលតាមធម្មតាកើតឡើងតិចជាង១០ភាគរយនៃអនុគមន៍ប្រូបាប៊ីលីតេដង់ស៊ីតេដែលបានសង្កេត។

លក្ខណៈរបស់ធាតុអាកាសធ្ងន់ធ្ងរអាចខុសគ្នាយ៉ាងខ្លាំងពីកន្លែងមួយទៅកន្លែងមួយ។ ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរមួយមិនអាចចាត់ទុកថាជាប់ទាក់ទងដោយផ្ទាល់ជាមួយការប្រែប្រួលអាកាសធាតុពីសកម្មភាពមនុស្សនោះទេ ព្រោះវាក៏អាចកើតឡើងដោយធម្មជាតិដែរ។ នៅពេលលំនាំធាតុអាកាសធ្ងន់ធ្ងរបន្តកើតឡើងក្នុងពេលខ្លះ ដូចជាក្នុងរដូវមួយ គេអាចចាត់ថ្នាក់ជាព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ជាពិសេសប្រសិនបើបង្កើតបានជាព្រឹត្តិការណ៍ដែលមានកម្លាំងមធ្យម ឬកម្លាំងសរុបក្នុងកម្រិតធ្ងន់ធ្ងរ។

**ព្រៃឈើ Forest**

នៅក្រោមកម្មវិធីរេដបូក ព្រៃឈើសំដៅលើឯកតាមួយនៃប្រព័ន្ធអេកូឡូស៊ីក្នុងរូបភាពជាតំបន់ដីសើមនិងដីស្ងួត ដែលគ្របដណ្តប់ដោយព្រៃធម្មជាតិឬព្រៃដាំ ដែលមានកម្ពស់ចាប់ពី៥ម៉ែត្រឡើងទៅ នៅលើផ្ទៃដីដែលមានទំហំយ៉ាងហោចណាស់០,៥ហិកតា និងមានគម្របកន្សោមស្លឹកច្រើនជាង១០%។

**ព្រៃបៃតងជានិច្ច Evergreen Forest**

បណ្តុំរុក្ខជាតិដែលមានស្លឹកដុះនៅគ្រប់រដូវ ហើយមានពណ៌បៃតងជានិច្ច។

**ព្រំអាកាសរចល់ Tropopause**

ព្រំប្រទល់រវាង*មណ្ឌលអាកាសរចល់* និង*មណ្ឌលអាកាសស្ងប់*។

# ភ

## ភវនីយភាព Likelihood

ឱកាសនៃលទ្ធផលជាក់លាក់ណាមួយដែលអាចកើតឡើងនិងប៉ាន់ប្រមាណបានតាមវិធីសាស្ត្រប្រូបាប៊ីលីតេ។

## ភាពជាដៃគូរេដបូក REDD+ Partnership

យន្តការស្ម័គ្រចិត្តនិងបណ្តោះអាសន្នសម្រាប់ប្រទេសដៃគូ ដោយមានគោលបំណងសំខាន់ក្នុងការរួមចំណែកដល់ការប្រយុទ្ធប្រឆាំងជាសកលទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ដើម្បីបង្កើនសកម្មភាពនិងហិរញ្ញវត្ថុសម្រាប់អនុវត្តរេដបូក និងចាត់វិធានការបន្ទាន់ ដោយរួមបញ្ចូលទាំងការលើកកម្ពស់ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងការសម្របសម្រួលកិច្ចផ្តួចផ្តើមរេដបូក និងយន្តការហិរញ្ញវត្ថុ ដើម្បីជួយសម្រួលដល់ការផ្ទេរចំណេះដឹង ពង្រឹងសមត្ថភាព សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងការអភិវឌ្ឍនិងផ្ទេរបច្ចេកវិទ្យា។

## ភាពត្រៀមបង្ការ Preparedness

ភាពចេះដឹងនិងសមត្ថភាពទាំងឡាយដែលអភិវឌ្ឍដោយរដ្ឋាភិបាល ស្ថាប័នជំនាញ សហគមន៍ និងបុគ្គល ដើម្បីប្រមើលមើល ឆ្លើយតប និងស្តារឡើងវិញប្រកបដោយប្រសិទ្ធភាពនូវស្ថានភាពបន្ទាប់ពីទទួលរងផលប៉ះពាល់ ពីគ្រោះអន្តរាយ ឬស្ថានការណ៍ទាំងឡាយដែលទំនងនឹងកើតឡើង រៀបនឹងកើតឡើង ឬកំពុងកើតឡើង។

### ភាពធន់/ភាពធន់ទ្រាំ Resilience

សមត្ថភាពនៃ*ប្រព័ន្ធសង្គម-អេកូឡូស៊ី* ដើម្បីទប់ទល់នឹងព្រឹត្តិការណ៍គ្រោះថ្នាក់ ឬការរំខានណាមួយ ដែលអាចឆ្លើយតបឬចាត់ចែងឡើងវិញតាមវិធីដែលអាចរក្សាបាននូវមុខងារសំខាន់ៗ អត្តសញ្ញាណ និងរចនាសម្ព័ន្ធ ហើយដែលអាចរក្សាបាននូវសមត្ថភាពបន្សុំ ការរៀនសូត្រ និងច្នៃប្រឌិត។

### ភាពធន់/ភាពធន់ទ្រាំប្រព័ន្ធអេកូឡូស៊ី Ecosystem resilience

សមត្ថភាពធន់ទ្រាំនៃ*ប្រព័ន្ធអេកូឡូស៊ី* ទៅនឹងការរំខានក្នុងកម្រិតមួយដែលមិនហួសពីសមត្ថភាពទ្រាំទ្រ ហើយមិនប្រែទៅជារចនាសម្ព័ន្ធឬធាតុចេញផ្សេងទៀតឡើយ។

ភាពធន់ទ្រាំអាស្រ័យលើឱណាមិកអេកូឡូស៊ី ក៏ដូចជាសមត្ថភាពចាត់ចែង និងសមត្ថភាពស្ថាប័នក្នុងការយល់ដឹងគ្រប់គ្រង និងឆ្លើយតបទៅនឹងឱណាមិកទាំងនេះ។

### ភាពប្រឈម Exposure

វត្តមានរបស់មនុស្ស ការចិញ្ចឹមជីវិត សេវាកម្មបរិស្ថាននិងធនធាន ហេដ្ឋារចនាសម្ព័ន្ធឬទ្រព្យ ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គម ឬផ្នែកវប្បធម៌ ដែលអាចនឹងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ។

### ភាពមិនប្រាកដប្រជា Uncertainty

ស្ថានភាពមួយនៃកង្វះចំណេះដឹងដែលបណ្តាលមកពីកង្វះព័ត៌មានឬការមិនឯកភាពគ្នានូវអ្វីដែលបានដឹងឬអាចដឹង។

ភាពមិនប្រាកដប្រជាអាចមានច្រើនប្រភេទ រាប់ចាប់ពីកំហុសដែលអាចគណនាបាននៅក្នុងទិន្នន័យ រហូតដល់ការកំណត់ទស្សនៈ ឬពាក្យបច្ចេកទេស ឬការព្យាករមិនច្បាស់លាស់អំពីឥរិយាបថរបស់មនុស្ស។ ដូច្នេះ ភាពមិនប្រាកដប្រជាអាចតំណាងដោយការវាស់វែងតាមបែបបរិមាណដូចជា របាយតួលេខដែល

គណនាដោយម៉ូដែលខុសៗគ្នា ឬដោយសេចក្តីអធិប្បាយតាមបែបគុណភាព ដូចជា ការឆ្លុះបញ្ចាំងអំពីការវិនិច្ឆ័យរបស់ក្រុមអ្នកជំនាញ។

**ភាពមិនលីនេអ៊ែ Nonlinearity**

ភាពគ្មានទំនាក់ទំនងសមាមាត្រងាយរវាងហេតុនិងផលនៃប្រព័ន្ធអាកាសធាតុ។ *ប្រព័ន្ធអាកាសធាតុ* ផ្សំឡើងដោយដំណើរការមិនលីនេអ៊ែបែបនេះជាច្រើន ធ្វើឱ្យប្រព័ន្ធមួយមានស្ថានភាពស្មុគស្មាញ ដែលអាចនាំទៅរកការប្រែប្រួលអាកាសធាតុភ្លាមៗយ៉ាងឆាប់រហ័ស។

**ភាពរួស/វេទយិតភាព Sensitivity**

កម្រិតដែលប្រព័ន្ធមួយទទួលរងឥទ្ធិពលវិជ្ជមានឬអវិជ្ជមាន ដោយសារ*វិសម្យបអាកាសធាតុឬការប្រែប្រួលអាកាសធាតុ*។

ឥទ្ធិពលអាចកើតឡើងដោយផ្ទាល់ដូចជា ការប្រែប្រួលទិន្នផលដំណាំ ដែលជាការឆ្លើយតបនឹងការប្រែប្រួលសីតុណ្ហភាពមធ្យម របាយ ឬវិសមរូបសីតុណ្ហភាព ឬដោយប្រយោលដូចជា ការខូចខាត ដែលបង្កដោយការកើនឡើងជាញឹកញាប់នៃទឹកជំនន់ក្នុងតំបន់ឆ្នេរ ដោយសារតែ*កំណើននីវ៉ូទឹកសមុទ្រ*។

**ភាពរួសអាកាសធាតុ Climate sensitivity**

ការប្រែប្រួលតម្លៃតុល្យភាពនៃសីតុណ្ហភាពមធ្យមប្រចាំឆ្នាំរបស់ផ្ទៃផែនដី បន្ទាប់ពីមានកំណើនទ្វេដងនៃតម្លៃសមមូលនៃកំហាប់ឧស្ម័នកាបូនិកនៅក្នុង*បរិយាកាស*។

ដោយសារឧបសគ្គនានាក្នុងការគណនា តម្លៃតុល្យភាពនៃភាពរួសអាកាសធាតុនៅក្នុង*ម៉ូដែលអាកាសធាតុ*មួយ ត្រូវបានប៉ាន់ប្រមាណតាមរយៈបង្គុំម៉ូដែលចរន្តទូទៅ(GCM) ក្នុងបរិយាកាសបន្ថែមពីលើម៉ូដែលចម្រុះស្រទាប់លើនៃមហាសមុទ្រ ព្រោះថាតម្លៃតុល្យភាពនៃភាពរួសអាកាសធាតុច្រើនតែកំណត់ដោយដំណើរការនៃ*បរិយាកាស*។ ម៉ូដែលមានប្រសិទ្ធភាពអាចគណនាលំនឹងឌីណាមិករបស់មហាសមុទ្រ។

## ភាពរាំងស្ងួត Drought

ដំណាក់កាលមួយនៃធាតុអាកាសស្ងួតខុសប្រក្រតីក្នុងរយៈពេលវែង ដែលបណ្តាលឱ្យមានអតុល្យភាពរបបជលសាស្ត្រធ្ងន់ធ្ងរ ដែលទាក់ទងនឹងឱនភាពរបបទឹកភ្លៀងទៅតាមបរិបទសកម្មភាពជាក់លាក់។

ឧទាហរណ៍ ៖ កង្វះកំណកអាកាសនៅរដូវដាំដុះប៉ះទង្គិចដល់ផលិតកម្មកសិកម្មឬមុខងារប្រព័ន្ធអេកូឡូស៊ីរួមដោយសារតែភាពស្ងួតហែងនៃសំណើមដី ដែលគេហៅថា ភាពរាំងស្ងួតកសិកម្ម ហើយកង្វះកំណកអាកាសនៅរដូវដែលមានលំហូរនិងការជ្រាបទឹកចូលទៅក្នុងស្រទាប់ដី មានឥទ្ធិពលបឋមមកលើការផ្គត់ផ្គង់ទឹក គេហៅថា ភាពរាំងស្ងួតជលសាស្ត្រ។ ការប្រែប្រួលសមត្ថភាពបង្ខាំងទឹកក្នុងសំណើមដីនិងទឹកក្រោមដី រងឥទ្ធិពលពីកំណើនរំហួតគួបផ្សំនឹងការថយចុះនៃកម្ពស់ទឹកភ្លៀង។ កំលុងពេលមានឱនភាពកំណកអាកាសមិនប្រក្រតីបែបនេះ គេហៅថា ភាពរាំងស្ងួតឧតុនិយម។ ភាពរាំងស្ងួតទ្រង់ទ្រាយធំ គឺជាគ្រោះរាំងស្ងួតដែលអូសបន្លាយយ៉ាងយូរ និងរីករាលដាលជាច្រើនកន្លែងក្នុងរយៈពេលវែងជាងធម្មតា ជាទូទៅមួយទសវត្សរ៍ឬវែងជាងនេះ។

## ភាពស្រអាប់របស់ផែនដី Global dimming

ភាពថយចុះនៃពន្លឺវិកាយរស្មីព្រះអាទិត្យសាយភាយនៅលើផ្ទៃផែនដីដែលបណ្តាល មកពីកំណើនខ្លាំងនៃឧស្ម័នកាបូនិកសមមូលនិងចុណ្ណភាគក្នុងអាកាស។

ឧទាហរណ៍ ៖ ភាពស្រអាប់របស់ផែនដីបានកើតមានរវាងពីឆ្នាំ១៩៦១ដល់ឆ្នាំ ១៩៩០។

## ភាពអាចទស្សន៍ទាយបាន Predictability

វិសាលភាពដែលអាចទស្សន៍ទាយបានពីស្ថានភាពរបស់ប្រព័ន្ធមួយសម្រាប់ពេលអនាគត ដោយផ្អែកលើចំណេះដឹងអំពីស្ថានភាពបច្ចុប្បន្ននិងអតីតកាលរបស់ប្រព័ន្ធនោះ។

ជាទូទៅ ដោយសារចំណេះដឹងអំពីស្ថានភាពអតីតកាលនិងអនាគតនៃ *ប្រព័ន្ធអាកាសធាតុ* មិនមានលក្ខណៈសុក្រឹត ក៏ដូចជាម៉ូដែលដែលប្រើប្រាស់ចំណេះដឹងនេះដើម្បីបង្កើតការទស្សន៍ទាយអាកាសធាតុ និងដោយប្រព័ន្ធអាកាសធាតុមិនលីនេអ៊ែ និងមានភាពស្មុគស្មាញ ដូច្នេះភាពអាចទស្សន៍ទាយបាននៃប្រព័ន្ធអាកាសធាតុនោះក៏មានកម្រិតដែរ។ សូម្បីម៉ូដែលនិងការសង្កេតដែលមានភាពសុក្រឹតក៏ដោយ ក៏ការទស្សន៍ទាយអំពីប្រព័ន្ធមិនលីនេអ៊ែនោះអាចនៅមានកម្រិតដែរ។

### ភាវៈបរជីព Heterotroph

សារពាង្គកាយមួយដែលមានសមត្ថភាពទាញយកថាមពលសម្រាប់ដំណើរការជីវិតពីការបំបែកនៃសមាសធាតុសរីរាង្គ ហើយមិនអាចប្រើប្រាស់សមាសធាតុអសរីរាង្គជាប្រភពថាមពលឬសម្រាប់សំយោគសរីរាង្គឡើយ។

សត្វភាគច្រើនជាភាវៈបរជីពនិងពឹងអាស្រ័យដោយផ្ទាល់ឬដោយប្រយោល (មំសាសី) លើការស៊ីរុក្ខជាតិដែលជាភាវៈស្វ័យជីព។

### ភេទនីយភាព/ភាពងាយរងគ្រោះ Vulnerability

ទំនោរឬដំណើរដែលងាយឬធាប់ទទួលរងផលប៉ះពាល់អវិជ្ជមាន ដោយរាប់បញ្ចូលនូវសញ្ញាណខុសៗគ្នាជាច្រើនរួមទាំងភាពរួសឬភាពងាយទទួលគ្រោះថ្នាក់និងកង្វះសមត្ថភាពដោះស្រាយនិងបន្សាំ។

### ភ្លុយអរ៉ូកាបួ Fluorocarbons

សមាសធាតុដែលផ្សំពីកាបូននិងភ្លុយអរ ដែលផ្ទុកនូវធាតុ អ៊ីដ្រូហ្សែននិងក្លរឬប្រូម ហើយដែលបំផ្លាញស្រទាប់អូសូន ($O_3$)។

ជាទូទៅ ភ្លុយអរ៉ូកាបួរួមមាន *ក្លរ៉ូភ្លុយអរ៉ូកាបួ (CFCs)* *អ៊ីដ្រូក្លរ៉ូភ្លុយអរ៉ូកាបួ (HCFCs)* *អ៊ីដ្រូភ្លុយអរ៉ូកាបួ (HFCs)* និង *ពែរភ្លុយអរ៉ូកាបួ (PFCs)*។

# ម

**មណ្ឌលកំណក Cryosphere**

តំបន់ទាំងអស់នៅលើនិងនៅជាប់ពីក្រោមផ្ទៃផែនដីនិងផ្ទៃមហាសមុទ្រ ជាទីដែលទឹកមានសណ្ឋានជាភាវៈរូបរឹង រួមទាំង *ទឹកកកសមុទ្រ* ទឹកកកបឹង ស្រទាប់ព្រឹល *ផែនទឹកកក ស្រទាប់ទឹកកក* និងទីកំណក(រួមទាំង *កំណកអចិន្ត្រៃយ៍* ផងដែរ)។

**មណ្ឌលទឹក Hydrosphere**

សមាសភាគនៃ *ប្រព័ន្ធអាកាសធាតុ* ដែលផ្សំដោយទឹក ទឹកលើផ្ទៃដី ទឹកក្នុងដី និងទឹកក្រោមដី ដូចជា ទឹកមហាសមុទ្រ ទឹកសមុទ្រ ទឹកទន្លេ ទឹកបឹង ទឹកក្រោមដី ។ល។

**មណ្ឌលអាកាសរចល់ Troposphere**

ស្រទាប់បរិយាកាសព័ទ្ធជុំវិញផែនដី មានកម្រាស់ពី៦ទៅ៨គ.ម.នៅតំបន់ប៉ូល ៩គ.ម.នៅកន្លែងដែលមានរយៈកម្ពស់ខ្ពស់១៦គ.ម.នៅតំបន់ត្រូពិក និងពី១៦ដល់១៧គ.ម.នៅតំបន់អេក្វាទ័រ។ មណ្ឌលនេះមានលក្ខណៈសម្គាល់ដោយសីតុណ្ហភាពនិងសម្ពាធបរិយាកាសចុះពីរយៈកម្ពស់ទាបទៅរយៈកម្ពស់ខ្ពស់ ហើយជាមណ្ឌលដែលកើតមានបាតុភូត ឧតុភូតច្រើនបំផុត។

**មណ្ឌលអាកាសស្ងប់ Stratosphere**

មណ្ឌលបរិយាកាសចន្លោះមណ្ឌលអាកាសរចល់និងមណ្ឌលអាកាសកណ្ដាល មានរយៈកម្ពស់ដល់៥០គ.ម.(មានកម្រាស់ប្រមាណ៤០គ.ម.)។

មណ្ឌលនេះខ្យល់ខ្យល់និងសំណើម។

**មមោកវប្បកម្ម Paludiculture**

ការកែប្រែដីឱ្យទៅជាដីសើមដូចជា វាលភក់ វាលល្បាប់លិចទឹកតាមរដូវកាល ឬវាលភក់មានរុក្ខជាតិស្មុយ រលួយ ដែលអាចឱ្យដាំដុះបាន។

**មាត្រដ្ឋានកាលាកាស Spatial and temporal scales**

មាត្រដ្ឋាននៃអាកាសធាតុដែលប្រែប្រួលក្នុងវិសាលភាពធំទៅតាមទីកន្លែង និងពេលវេលា។

មាត្រដ្ឋានទីកន្លែងអាចប្រែប្រួលពីកម្រិតប្រទេស(តិចជាង១០០ ០០០គ.ម.២) រហូតដល់កម្រិតតំបន់(១០០ ០០០ទៅ១០លានគ.ម.២) និងកម្រិតទ្វីប(១០ទៅ១០០លានគ.ម.២)។ មាត្រដ្ឋានពេលវេលាអាចប្រែប្រួលចាប់ពីរដូវកាលរហូតដល់ធរណីកាល(រហូតដល់រយលានឆ្នាំ)។

**ម៉ាសខ្យល់ Air mass**

មាឌខ្យល់ស្ថិតនៅក្នុងតំបន់ណាមួយលើផ្ទៃផែនដីដែលកំណត់ដោយសីតុណ្ហភាព និងចំហាយទឹក។ នៅពេលដែលមាឌខ្យល់មានម៉ាសប្រែប្រួល វាចល័តចេញពីតំបន់ប្រភពដើម។

បណ្តុំខ្យល់ដែលលក្ខណៈសមាសធាតុស្រដៀងគ្នារបស់វា : (១) បានកើតឡើងនៅពេលដែលខ្យល់នោះស្ថិតនៅក្នុងតំបន់ណាមួយលើផ្ទៃផែនដី និង(២) ទទួលរងការប្រែប្រួលជាក់លាក់នៅពេលដែលវាចល័តចេញពីតំបន់ប្រភពដើម។

**ម៉ាសទឹក Water mass**

មាឌទឹកមហាសមុទ្រដែលកើតឡើងដោយមានលក្ខណៈរូប(ដែលមានសីតុណ្ហភាពកម្រិតប្រៃ ដង់ស៊ីតេ និងបរិមាណរូបធាតុផ្សេងទៀត)និងលក្ខណៈគីមីដោយឡែកខុសពីលក្ខណៈរូបនៃទឹកនៅជុំវិញវា។

មាឌទឹកដែលមានម៉ាសប្រែប្រួលផ្លាស់ទីតាមទិសដេកនិងទិសឈរ។

**មុខងារកម្មប្រព័ន្ធអេកូឡូស៊ី Ecosystem functioning**

ការបង្កើតឡើងនូវដំណើរការនានាដែលកំណត់ដោយអន្តរកម្មផ្សេងៗក្នុងចំណោមសហគមន៍ជីវសាស្ត្រ ទាំងប្រភេទក្នុងស្រុក ទាំងប្រភេទក្រៅស្រុក ទាំងដំណើរការជីវរូបសាស្ត្រ ដូចជា និយតកម្មទឹកនិងការបង្កើតឡើងវិញនូវវដ្តសារជាតុចិញ្ចឹម។

**មុខសញ្ញាគ្រោះថ្នាក់ Hazard**

សក្តានុពលដែលអាចកើតឡើងនៃបាតុភូត និន្នាការ ឬផលប៉ះពាល់រូបវន្តដែលបង្កឡើងដោយធម្មជាតិឬដោយសកម្មភាពមនុស្សបង្កឱ្យបាត់បង់ជីវិត មានរបួស ប៉ះពាល់សុខភាព ក៏ដូចជាខូចខាតនិងបាត់បង់ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ របរចិញ្ចឹមជីវិត ការផ្តល់សេវាកម្ម និងធនធានបរិស្ថាន។ ឧទាហរណ៍ : គ្រោះទឹកជំនន់ ភាពរាំងស្ងួត ...។

ពាក្យថា មុខសញ្ញាគ្រោះថ្នាក់ ភាគច្រើនសំដៅលើបាតុភូតរូបឬនិន្នាការដែលទាក់ទងនឹងអាកាសធាតុ ឬផលប៉ះពាល់រូបវន្ត។

**មូលនិធិបរិស្ថានពិភពលោក Global Environment Facility (GEF)**

ស្ថាប័នដែលផ្តល់ជំនួយឥតសំណងដល់ប្រទេសកំពុងអភិវឌ្ឍ ដើម្បីទ្រទ្រង់ដល់គម្រោងដែលទាក់ទងនឹង *ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ* ដែនទឹកអន្តរជាតិ តំហយគុណភាពដី *ស្រទាប់អូសូន* និងសារជាតិពុលសរីរាង្គមិនងាយបំបែកធាតុ។

មូលនិធិបរិស្ថានពិភពលោក ត្រូវបានបង្កើតក្នុងឆ្នាំ១៩៩១ ដើម្បីជួយផ្តល់ថវិកាដល់ប្រទេសកំពុងអភិវឌ្ឍសម្រាប់គម្រោងនិងកម្មវិធីការពារបរិស្ថានពិភពលោក។

**មូលនិធិអាកាសធាតុបៃតង Green Climate Fund (GCF)**

ស្ថាប័នផ្តល់មូលនិធិដើម្បីទ្រទ្រង់គម្រោង កម្មវិធី គោលនយោបាយ និងសកម្មភាពផ្សេងៗរបស់ភាគីប្រទេសកំពុងអភិវឌ្ឍឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ មូលនិធិនេះ គ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតង។

នៅ*សន្និសីទបណ្តាភាគី*លើកទី១៦ នៅទីក្រុងកាន់គុន ឆ្នាំ២០១០ រដ្ឋាភិបាលនានាបានបង្កើតមូលនិធិអាកាសធាតុបៃតងមួយ ដែលដើរតួជាអង្គភាពប្រតិបត្តិការយន្តការហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា១១នៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ*។

**ម៉ូដែលអាកាសធាតុ Climate model**

គំរូតាងជាតួលេខនៃ*ប្រព័ន្ធអាកាសធាតុ* ដែលផ្អែកលើលក្ខណៈរូប គីមី និងជីវៈនៃសមាសភាគរបស់*ប្រព័ន្ធអាកាសធាតុ*អន្តរកម្មរបស់សមាសភាគទាំងនោះ និងដំណើរការឆ្លើយតប ដោយរួមបញ្ចូលលក្ខណៈដែលស្គាល់ទាំងអស់ឬខ្លះៗ។ ប្រព័ន្ធអាកាសធាតុនេះអាចតាងដោយម៉ូដែលមានលក្ខណៈស្មុគស្មាញខុសគ្នាពោលគឺ សម្រាប់សមាសភាគឬបង្គុំសមាសភាគណាមួយ ធ្វើឱ្យគេអាចកំណត់វិសាលគមន៍ឬលំដាប់នៃម៉ូដែលទៅតាមចំនួនកត្តារូប ដែលតំណាងឱ្យវិសាលភាពនៃដំណើរការរូបសាស្ត្រ គីមីសាស្ត្រ ជីវសាស្ត្រ ឬកម្រិតប៉ារ៉ាម៉ែត្រដាក់ស្តែង។ ម៉ូដែលអាកាសធាតុត្រូវបានប្រើប្រាស់ជាឧបករណ៍សិក្សាស្រាវជ្រាវ ដើម្បីធ្វើការបង្ហាញគ្រាប់ពីអាកាសធាតុ ហើយសម្រាប់គោលបំណងប្រតិបត្តិការ រួមទាំង*ការទស្សន៍ទាយអាកាសធាតុ*ប្រចាំខែ ប្រចាំរដូវ និងប្រចាំឆ្នាំ។

**មេគុណបញ្ចេញឧស្ម័ន Emission factor**

អត្រានៃការបញ្ចេញធាតុចេញឬធាតុចូលក្នុងមួយឯកតាសកម្មភាព។

**មេតាទិន្នន័យ Metadata**

ព័ត៌មានដែលពណ៌នាអំពីទិន្នន័យ *ឧតុនិយម* និង*អាកាសធាតុ* ទាក់ទងនឹងរបៀបនិងពេលវេលានៃការវាស់វែង ទិន្នន័យប្រកបដោយគុណភាព បញ្ហាដែលបានដឹង និងលក្ខណៈដោយឡែកផ្សេងទៀត។

**មេតាន Methane ($CH_4$)**

ឧស្ម័នផ្ទះកញ្ចក់មួយប្រភេទក្នុងចំណោម *ឧស្ម័នផ្ទះកញ្ចក់* ទាំង៦ ដែលត្រូវកាត់បន្ថយក្រោម *ពិធីសារក្យូតូ* និងជាផ្នែកសំខាន់មួយនៃឧស្ម័នធម្មជាតិ ហើយទាក់ទងនឹងឥន្ធនៈអ៊ីដ្រូកាបួទាំងអស់ ការចិញ្ចឹមសត្វ និងកសិកម្ម។

មេតានជា *អ៊ីដ្រូកាបួ* ឆ្អែត គ្មានពណ៌ គ្មានក្លិន ងាយឆាបឆេះ ជាសមាសធាតុគីមីទី១នៃក្រុមអាល់កាន។

**ម្រែងភ្លើង Soot**

ភាគល្អិតដែលកកើតឡើងនៅពេលមានចំហេះមិនសព្វនៃសមាសធាតុ *អ៊ីដ្រូកាបួ* ដែលភាគច្រើនសម្បូរកាបូន និងមានបរិមាណអុកស៊ីសែននិងអ៊ីដ្រូសែនតិចក្រោមរូបភាពជាក្រុមកាបុកស៊ីលនិងផេណុល ហើយបង្កជារចនាសម្ព័ន្ធក្រាហ្វិតមិនពេញលេញ។

# យ

**យន្តការក្យូតូ Kyoto Mechanisms (KM)**

យន្តការសេដ្ឋកិច្ចផ្អែកលើគោលការណ៍ទីផ្សារ ដែលបណ្ដាភាគីក្នុង *ពិធីសារក្យូតូ* អាចប្រើប្រាស់ក្នុងបំណងកាត់បន្ថយផលប៉ះពាល់នៃសក្ដានុពលសេដ្ឋកិច្ច ដែលតម្រូវឱ្យមានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

យន្តការទាំងនេះរួមមាន *ការអនុវត្តរួមគ្នា*( មាត្រា៦ ) *យន្តការអភិវឌ្ឍន៍ស្អាត* ( មាត្រា១២ ) និង *ពាណិជ្ជកម្មការបញ្ចេញឧស្ម័ន*( មាត្រា១៧ )។

**យន្តការអភិវឌ្ឍន៍ស្អាត Clean Development Mechanism (CDM)**

យន្តការមួយដែលបានកំណត់ក្នុងមាត្រា១២នៃ *ពិធីសារក្យូតូ* ដែលនៅក្នុងនោះវិនិយោគិន( រដ្ឋាភិបាលឬក្រុមហ៊ុននានា )របស់បណ្ដាប្រទេសអភិវឌ្ឍ( ក្នុងឧបសម្ព័ន្ធ B ) អាចផ្ដល់ហិរញ្ញវត្ថុដល់គម្រោងកាត់បន្ថយឬស្រូបយក *ឧស្ម័នផ្ទះកញ្ចក់* នៅក្នុងប្រទេសកំពុងអភិវឌ្ឍ( ប្រទេសមិនស្ថិតក្នុងឧបសម្ព័ន្ធ B ) និងទទួលបានបរិមាណ( គិតជាឯកតា )នៃការកាត់បន្ថយការបញ្ចេញឧស្ម័នដែលកំណត់ដោយលិខិតប្រកាសជាផ្លូវការ ហើយជាលទ្ធផល វាអាចគិតជាឥណទានសម្រាប់ទូទាត់ជាមួយនឹងការប្ដេជ្ញាចិត្តរបស់បណ្ដាប្រទេសអភិវឌ្ឍ។

យន្តការអភិវឌ្ឍន៍ស្អាត មានវត្ថុបំណង២ គឺជំរុញ *ការអភិវឌ្ឍប្រកបដោយចីរភាព* ក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍនិងជួយដល់បណ្ដាប្រទេសឧស្សាហកម្ម ដើម្បីសម្រេចបាននូវការប្ដេជ្ញាចិត្តការកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ពួកគេ ក្នុងមធ្យោបាយចំណាយប្រកបដោយប្រសិទ្ធភាព។

**យន្តការឥណទានកាបូនរួមគ្នា Joint Crediting Mechanism (JCM)**

យន្តការទ្វេភាគីរវាងប្រទេសជប៉ុននិងប្រទេសកំពុងអភិវឌ្ឍណាមួយ ហើយដែលមានជាតុ៣៖ ទី១ គឺដើម្បីជួយសម្រួលដល់ការផ្សព្វផ្សាយបច្ចេកវិទ្យាបញ្ចេញកាបូនតិចនាំមុខគេ ផលិតផល ប្រព័ន្ធ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការអនុវត្តសកម្មភាពកាត់បន្ថយនិងរួមចំណែកដល់*ការអភិវឌ្ឍប្រកបដោយចីរភាព*ដល់ប្រទេសកំពុងអភិវឌ្ឍ។ ទី២ គឺដើម្បីវាយតម្លៃសមស្របដល់ការកាត់បន្ថយឬការស្រូបឧស្ម័នផ្ទះកញ្ចក់ពីបណ្តាប្រទេសអភិវឌ្ឍតាមបែបបរិមាណ តាមរយៈសកម្មភាពកាត់បន្ថយដែលបានអនុវត្តក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍនិងប្រើប្រាស់ការកាត់បន្ថយឬការស្រូបឧស្ម័នទាំងនោះដើម្បីសម្រេចគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ប្រទេសអភិវឌ្ឍទាំងនោះ។ ទី៣ គឺដើម្បីរួមចំណែកដល់គោលបំណងចុងក្រោយនៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ* ដោយការសម្រួលឱ្យមានសកម្មភាពជាសកលក្នុងការកាត់បន្ថយការបញ្ចេញឬការស្រូបយកឧស្ម័ន។

**យុគទឹកកក Ice age**

រយៈកាលវែងក្នុងអតីតកាលដែលសីតុណ្ហភាពរបស់ភពផែនដី(ផ្ទៃផែនដីនិងបរិយាកាស)ធ្លាក់ចុះ នាំឱ្យមានកំណើន*ស្រទាប់ទឹកកក* និង *ផែនទឹកកក*។

ឧទាហរណ៍ : បណ្តាយុគទឹកកកក្នុងសម័យផ្លេអ៊ីស្តូសែន។

# រ

**រយៈពេលក្តៅនៃយុគកណ្តាល Medieval Warm Period (MWP)**

រយៈពេលចន្លោះពីឆ្នាំ១០០០ដល់ឆ្នាំ១៣០០ក្រោយគ្រិស្តសករាជ ដែលតំបន់មួយចំនួននៅអឌ្ឍគោលខាងជើងក្តៅ ជាងកូនយុគទឹកកកដែលកើតមានបន្ទាប់មក។

**រយៈពេលដំណើរការគម្រោង Project lifetime**

រយៈពេលដែលសកម្មភាពគម្រោងត្រូវបានអនុវត្ត។

**រយៈពេលឆ្លើយតប Response time**

ពេលវេលាចាំបាច់សម្រាប់*ប្រព័ន្ធអាកាសធាតុ* ឬផ្នែកផ្សេងៗរបស់វាក្នុងការធ្វើឱ្យស្ថានភាពថ្មីមួយមានលំនឹងឡើងវិញ បន្ទាប់ពីមាន*កម្លាំងជំរុញ* ដោយដំណើរការនិងផលតបពីខាងក្រៅនិងពីខាងក្នុង។

រយៈពេលឆ្លើយតបផ្នែកផ្សេងៗនៃប្រព័ន្ធអាកាសធាតុមានរយៈពេលខុសៗគ្នាយ៉ាងខ្លាំង។ ពេលឆ្លើយតបនៃ*មណ្ឌលអាកាសរចល់* មានរយៈពេលខ្លី ចាប់ពីច្រើនថ្ងៃរហូតដល់ច្រើនសប្តាហ៍ ចំណែក*មណ្ឌលអាកាសស្ងប់* វិញ អាចមានរហូតពីរឬបីខែ។ ដោយសារមានចំណុះកម្តៅខ្ពស់ មហាសមុទ្រមានរយៈពេលឆ្លើយតបវែង ចាប់ពីច្រើនទសវត្សរ៍រហូតដល់សតវត្សរ៍ឬច្រើនសហស្សវត្សរ៍។ ដូច្នេះប្រព័ន្ធផ្ទៃផែនដី-មណ្ឌលអាកាសរចល់មានពេលឆ្លើយតបយឺតបើធៀបនឹងពេលឆ្លើយតបរបស់*មណ្ឌលអាកាសស្ងប់* ហើយរយៈពេលនោះភាគច្រើនកំណត់ដោយមហាសមុទ្រ។ *ជីវមណ្ឌល* អាចឆ្លើយតបបានលឿន (ដូចជា ឆ្លើយតបនឹងភាពរាំងស្ងួត) ប៉ុន្តែក៏យឺតយ៉ាវខ្លាំងផងដែរ ចំពោះការប្រែប្រួលផ្សេងៗ។

**រយៈពេលអាចកើតឡើងវិញ Return period**

ការប៉ាន់ស្មានចន្លោះដែលមានរយៈពេលមធ្យមរវាងការកើតមានឡើងនៃព្រឹត្តិការណ៍មួយដែលបានកំណត់ទំហំឬ អាំងតង់ស៊ីតេនៃព្រឹត្តិការណ៍( ទាបជាងឬខ្ពស់ជាង )ដោយជាក់លាក់។

ឧទាហរណ៍ : ទឹកជំនន់ឬភ្លៀងធ្លាក់ខ្លាំង។

**រលកកម្ដៅ Heat wave**

កំលុងពេលដែលធាតុអាកាសក្ដៅខុសពីធម្មតា។

**រស្មីសំយោគ/ហ្វូតូសំយោគ Photosynthesis**

ដំណើរការក្រោមវត្តមានពន្លឺព្រះអាទិត្យដែលរុក្ខជាតិបៃតងស្រូបយក *ឧស្ម័នកាបូនិក* ពីខ្យល់និងទឹកពីក្នុងដីឬពីប្រភពទឹកនានា(ឬប៊ីកាបូណាតនៅក្នុងទឹក) ដើម្បីបង្កើតជាសារធាតុចិញ្ចឹមកាបូអ៊ីដ្រាតនិងបញ្ចេញអុកស៊ីសែននៅក្នុងដំណើរការនេះ។

រស្មីសំយោគមានវិធីច្រើនយ៉ាង ឆ្លើយតបខុសៗគ្នាចំពោះកំហាប់ឧស្ម័នកាបូនិកក្នុង *បរិយាកាស* ។

**រហោស្ថានកម្ម Desertification**

ការរេចរឹលគុណភាពដីក្នុង *តំបន់ស្ងួត តំបន់ពាក់កណ្ដាលស្ងួត* និងតំបន់ស្ងួតសើមបង្គួរដែលបណ្ដាលមកពីកត្តាផ្សេងៗគ្នា រួមបញ្ចូលទាំង *ការប្រែប្រួលអាកាសធាតុ* និងសកម្មភាពមនុស្ស។

ជាងនេះទៅទៀត តាមអនុសញ្ញាសហប្រជាជាតិស្ដីពីការប្រយុទ្ធប្រឆាំងរហោស្ថានកម្មបានកំណត់និយមន័យការរេចរឹលគុណភាពដី ថាជាការថយចុះឬបាត់បង់ផលិតភាពជីវសាស្ត្រ ឬសេដ្ឋកិច្ច និងភាពសាំញ៉ាំនៃដីដំណាំដែលពឹងផ្អែកទឹកភ្លៀង ដីដំណាំដែលមានប្រព័ន្ធស្រោចស្រពវាលស្មៅ *ព្រៃឈើ* និងគម្ពោធព្រៃនៅក្នុង *តំបន់ស្ងួត តំបន់ពាក់កណ្ដាលស្ងួត* និងតំបន់ស្ងួតសើមបង្គួរ ដោយសារការប្រើប្រាស់ដី ដំណើរការមួយឬបង្គុំដំណើរការច្រើនពីសកម្មភាពមនុស្ស និង

របៀបនៃការតាំងទីលំនៅ ដូចជា (i) *សំណឹក* ដីបង្កដោយខ្យល់ និង/ឬទឹក (ii) ការខូចខាតលក្ខណៈរូបគីមី និងជីវសាស្ត្រ ឬសេដ្ឋកិច្ចនៃដី និង(iii) ការបាត់បង់រុក្ខជាតិធម្មជាតិរយៈពេលវែង។

**រុក្ខជាតិកាបូន៣ C3 plant**

រុក្ខជាតិដែលបង្កើតសមាសធាតុកាបូនបី នៅក្នុងពេលធ្វើ*រស្មីសំយោគ* រួមមានរុក្ខជាតិនិងដំណាំកសិកម្មសំខាន់ៗ ដូចជា ស្រូវ ស្រូវសាឡី សណ្តែកសៀង ដំឡូងបារាំង និងបន្លែ។

**រុក្ខជាតិកាបូន៤ C4 plant**

រុក្ខជាតិដែលបង្កើតសមាសធាតុកាបូនបួននៅក្នុងពេលធ្វើ*រស្មីសំយោគ* ដែលភាគច្រើនជារុក្ខជាតិមានដើមកំណើតនៅតំបន់ត្រូពិក រួមមានស្មៅនិងដំណាំកសិកម្មសំខាន់ៗដូចជា ពោត អំពៅ ស្រូវមីយ៉េ ស្មៅ ជាដើម។

**រេដ (ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់និងរេចរឹលព្រៃឈើ)**
**REDD (Reducing Emissions from Deforestation and Forest Degradation)**

កិច្ចប្រឹងប្រែងដើម្បីបង្កើតតម្លៃហិរញ្ញវត្ថុសម្រាប់កាបូនដែលបង្ខាំងក្នុងវិស័យព្រៃឈើ ដោយផ្តល់ការលើកទឹកចិត្តដល់ប្រទេសកំពុងអភិវឌ្ឍចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័នពីដីដែលមានព្រៃឈើ និងធ្វើការវិនិយោគ សកម្មភាពដែលបញ្ចេញកាបូនតិចដើម្បី*ការអភិវឌ្ឍប្រកបដោយចីរភាព*។

រេដបូក(REDD+) មានន័យលើសពីការបាត់បង់និងរេចរឹលព្រៃឈើ ដោយរួមបញ្ចូលនូវតួនាទីនៃការអភិរក្ស ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងការបង្កើន*អាងបង្ខាំងកាបូន* ក្នុងវិស័យព្រៃឈើ។

**រំកិលដី Landslide**

ចលនាបាក់ធ្លាក់ ឬរអិលចុះក្រោមនៃផ្ទាំងដី ឬសិលាជាទ្រង់ទ្រាយធំ កើតឡើងនៅទីកន្លែងដែលស្រទាប់ដី ឬសិលាខាងលើលែងខាំជាប់ជាមួយផ្នែករឹងនៅខាងក្រោម ដោយសារមានបន្ទុះភ្នំភ្លើង រញ្ជួយដី ឬភ្លៀងខ្លាំង ជាដើម។

**វិកិរណ៍ Radiation**

បន្ទេរថាមពលក្រោមរូបភាពជារលកអេឡិចត្រូម៉ាញ៉េទិក ឬភាគល្អិតដែលបញ្ចេញថាមពលនៅពេលស្រូបដោយវត្ថុណាមួយ។

**វិកិរណ៍ក្រហមអាំងហ្វ្រាកម្ដៅ Thermal infrared radiation**

វិកិរណ៍ដែលភាយចេញពីផ្ទៃផែនដី *បរិយាកាស* និងពពក ហើយដែលគេអាចហៅផងដែរថា *វិកិរណ៍* ពីផែនដីគោកឬកាំរស្មីជំហានរលកវែង។

វិកិរណ៍នេះមានលក្ខណៈខុសពីវិកិរណ៍ក្បែរអាំងហ្វ្រាដែលជាផ្នែកមួយនៃជំហានរលកពន្លឺព្រះអាទិត្យ។ ជាទូទៅ*វិកិរណ៍ក្រហមអាំងហ្វ្រា* មានជំហានរលកវែងជាងជំហានរលកពណ៌ក្រហមនៅក្នុងផ្នែកនៃបាច់ពន្លឺមើលឃើញ។

ជំហានរលកវិកិរណ៍ក្រហមអាំងហ្វ្រាកម្ដៅខុសពីវិកិរណ៍ជំហានរលកខ្លី ឬ*វិកិរណ៍ព្រះអាទិត្យ* ដោយសារតែភាពខុសគ្នា នៃសីតុណ្ហភាពរវាងព្រះអាទិត្យ និង*ប្រព័ន្ធបរិយាកាស*ផែនដី ។

**វិកិរណ៍ព្រះអាទិត្យ Solar radiation**

វិកិរណ៍អេឡិចត្រូម៉ាញ៉េទិកដែលភាយចេញពីព្រះអាទិត្យ ដោយមានបាច់ពន្លឺជិតស្មើនឹងអង្គពណ៌ខ្មៅមួយមានសីតុណ្ហភាព៥៧៧០K(ស្មើនឹង៥៤៩៦,៨៥C)។

កាំរស្មីនេះឡើងដល់កម្រិតកំពូលក្នុងទម្រង់ជំហានរលកមើលឃើញ។ នៅពេលប្រៀបធៀបជាមួយវិកិរណ៍ដែលផ្លាតពីផែនដី ជាញឹកញយ គេហៅថាវិកិរណ៍ជំហានរលកខ្លី។

**រំហួត Evaporation**

ដំណើរការផ្លាស់ប្ដូរពីសភាពរាវទៅជាឧស្ម័ន។

**រំហួតវិកិរណ៍ចំហាយទឹក Evapotranspiration**

ដំណើរការរួមបញ្ចូលគ្នានៃ*រំហួត*ទឹកពីផ្ទៃផែនដីនិងវិកិរណ៍*ចំហាយទឹក*ចេញពីរុក្ខជាតិ។

# ល

**លិខិតអនុញ្ញាតឱ្យបញ្ចេញកាបូន Carbon permits**

ការអនុញ្ញាតឱ្យបំពុលឬបញ្ចេញឧស្ម័ន ដែលបានផ្តល់ជូនស្ថិតនៅក្រោមគម្រោងនៃ *ការកំណត់បរិមាណនិងពាណិជ្ជកម្មកាបូន* ។

ខុសពី *ឥណទានកាបូន* លិខិតអនុញ្ញាតនេះត្រូវបានផ្តល់ជូនទុកជាមុនក្នុងបរិមាណកំណត់ ( *"ការកំណត់បរិមាណ"* ) ដែលកំណត់ឡើងដោយរដ្ឋាភិបាល។

**លីតូស្វែ ឬមណ្ឌលថ្ម Lithosphere**

ស្រទាប់លើនៃផែនដីទាំងនៅក្នុងទ្វីប ទាំងនៅក្នុងមហាសមុទ្រ ផ្សំដោយស្រទាប់ថ្ម មានសីតុណ្ហភាពត្រជាក់ ភាគច្រើនជាផ្នែកយឺតនៃស្រទាប់ម៉ង់តូខាងលើបំផុត។

សកម្មភាពភ្នំភ្លើងមិនត្រូវបានចាត់ទុកជាផ្នែកមួយនៃ *ប្រព័ន្ធអាកាសធាតុ* ទេ បើទោះវាជាផ្នែកមួយនៃមណ្ឌលថ្មក៏ដោយ ប៉ុន្តែសកម្មភាពភ្នំភ្លើងមាននាទីជាកត្តា *កម្លាំងជំរុញពីខាងក្រៅ* ។

**លំហូរច្រោះ Runoff**

ផ្នែកមួយនៃកំណាកអាកាសដែលមិនហួតនិងមិនកជាញើស ហូរក្រោមដីឬលើផ្ទៃដី និងវិលត្រឡប់ទៅ *អាងបង្ហាំងទឹក* វិញ។

**លំហូរខ្សែទឹក Streamflow**

បរិមាណទឹកហូរនៅក្នុងផ្លូវទឹកមួយគិតជាម៉ែត្រគូបក្នុងមួយវិនាទី ( $m^3/s$ )។

លំហូរខ្សែទឹកមានន័យដូចគ្នានឹងធារទឹកដែរ។

# វ

**វដ្តកាបូន Carbon cycle**

លំហូរកាបូនក្នុងទម្រង់ខុសៗគ្នាដូចជា *ឧស្ម័នកាបូនិក* ម្រែងភ្លើង ជាដើម តាមបរិយាកាស សមុទ្រ ជីវមណ្ឌលជីគោក និង *មណ្ឌលថ្ម*។

**វដ្តជលសាស្ត្រឬវដ្តទឹក Hydrological cycle or water cycle**

វដ្តនៃទឹកដែលហួតចេញពីផ្ទៃលើនៃមហាសមុទ្រនិងផ្ទៃដីទៅកាន់ផែនដីតាមចរន្តបរិយាកាសក្នុងទម្រង់ជា *ចំហាយទឹក* កំណកពពក កំណកអាកាស( ទឹកភ្លៀងឬព្រិល ) និងត្រូវបានដើមឈើនិងរុក្ខជាតិស្រូបយក ហើយដែលបង្កើតជាលំហូរទឹកលើផ្ទៃដី ជ្រាបចូលទៅក្នុងដី បំពេញទឹកក្រោមដី ហូរចូលទៅក្នុងស្ទឹង ហូរចាក់ទៅមហាសមុទ្រ ហើយហួតចេញពីមហាសមុទ្រឬផ្ទៃដីឡើងទៅក្នុង *បរិយាកាស* វិញ។

ប្រព័ន្ធខុសៗគ្នាដែលពាក់ព័ន្ធនឹងវដ្តជលសាស្ត្រត្រូវគេហៅថា ប្រព័ន្ធជលសាស្ត្រ។

**វដ្តពន្លឺព្រះអាទិត្យ( ១១ឆ្នាំ ) Solar (11 year) cycle**

ដំណើរលោកឡើងចុះស្មើរតែទៀងទាត់នៃ *សកម្មភាពពន្លឺព្រះអាទិត្យ* ដែលមានទំហំកម្លាំងអតិបរមាខុសគ្នាក្នុង រយៈពេលពី៩ទៅ១៣ឆ្នាំ។

**វារីវប្បកម្ម Aquaculture**

ការចិញ្ចឹមត្រី សិប្បីសត្វ។ល។ និងការដាំរុក្ខជាតិទឹកក្នុងដែនទឹកសាបឬទឹកប្រៃក្រោមលក្ខខណ្ឌត្រួតពិនិត្យនិងការគ្រប់គ្រងកំណត់មួយ ដើម្បីបង្កើនផលិតកម្មនិងភាពជាម្ចាស់របស់បុគ្គលឬសាជីវកម្មនៃភាវៈបង្ខាំងដែលបានចិញ្ចឹមទុក។

**វារីអគ្គិសនី Hydroelectricity**

អគ្គិសនីដែលបានមកពីការផលិតតាមរយៈការបំប្លែងពីថាមពលនៃចរន្តទឹក។

**វិធីសាស្ត្របាយ៉េស Bayesian method**

វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់សម្រាប់វិភាគស្ថិតិបរិមាណមិនដឹងឬមិនប្រាកដប្រជា ដែលរួមមានពីរជំហាន។ ជំហានទីមួយ : ការបង្កើតរបាយប្រូបាប៊ីលីតេជាមុនសម្រាប់បរិមាណមិនប្រាកដប្រជា ដោយផ្អែកលើចំណេះដឹងដែលមានស្រាប់(ឬតាមរយៈការស្រង់យោបល់របស់អ្នកជំនាញឬដោយការប្រើប្រាស់ទិន្នន័យនិងការសិក្សាដែលមានស្រាប់)។ ក្នុងដំណាក់កាលដំបូងនេះ ជាតុនៃប្រធានបទមួយអាចមានឥទ្ធិពលមកលើការជ្រើសរើស ប៉ុន្តែក្នុងករណីជាច្រើនរបាយប្រូបាប៊ីលីតេត្រូវបានជ្រើសរើសដោយអព្យាក្រឹតតាមដែលអាចធ្វើបាន ដើម្បីបញ្ចៀសឥទ្ធិពលមកលើលទ្ធផលចុងក្រោយនៃការវិភាគ។ ជំហានទីពីរ : ទិន្នន័យទទួលបានថ្មីៗ ត្រូវណែនាំដោយប្រើប្រាស់ទ្រឹស្តីបទដែលបង្កើតនិងដាក់ឈ្មោះតាមគណិតវិទូអង់គ្លេសឈ្មោះ ថូម៉ាស បាយ៉េស (Thomas Bayes ១៧០២-១៧៦១) ដើម្បីផ្តល់នូវទិន្នន័យថ្មីបំផុតនៃរបាយទិន្នន័យមុន ទៅក្នុងរបាយទិន្នន័យក្រោយ។

**វិធីសាស្ត្រគ្រប់គ្រងតំបន់ទេសភាព Landscape approach**

ការគ្រប់គ្រងប្រព័ន្ធផលិតកម្មនិងធនធានធម្មជាតិក្នុងតំបន់ធំល្មម ដើម្បីបង្កើតសេវាកម្មអេកូឡូស៊ីដែលទ្រទ្រង់ជីវិតនិងនៅក្នុងតំបន់តូចល្មមដែលគ្រប់គ្រងដោយមនុស្សកំពុងប្រើប្រាស់ដីនិងផលិតសេវាកម្មទាំងនោះ។

**វិសមរូបធម្មជាតិ Natural variability**

ការប្រែប្រួលជុំវិញសភាពមធ្យមនិងស្ថិតិផ្សេងៗ(ដូចជា គម្លាតស្តង់ដាឬស្ថិតិនៃព្រឹត្តិការណ៍មិនប្រក្រតី)នៃអាកាសធាតុស្តីពីគ្រប់មាត្រដ្ឋាននៃលំហានិងពេលហួសពីព្រឹត្តិការណ៍ធាតុអាកាសនីមួយៗ។

វិសមរូបធម្មជាតិក្នុងអាកាសធាតុនៅពេលណាមួយ បង្កឡើងដោយដំណើរការខាងក្នុងប្រព័ន្ធអាកាសធាតុ ដូចជា អែលនីញ៉ូ ក៏ដូចជាការផ្លាស់ប្តូរឥទ្ធិពលពីខាងក្រៅដូចជា សកម្មភាពបន្ទុះភ្នំភ្លើងនិងភាពខុសគ្នានៃ*ថាមពលពន្លឺព្រះអាទិត្យ*។

**វិសមរូបអាកាសធាតុ Climate variability**

ការប្រែប្រួលជុំវិញសភាពមធ្យមនិងស្ថិតិផ្សេងៗ(ដូចជា គម្លាតស្តង់ដា ការកើតឡើងនៃស្ថានភាពធ្ងន់ធ្ងរ។ល។) នៃអាកាសធាតុស្តីពីគ្រប់មាត្រដ្ឋាននៃលំហ និងពេលវេលា ហួសពីព្រឹត្តិការណ៍អាកាសធាតុដែលមានលក្ខណៈដោយឡែកផ្សេងគ្នា។ វិសមរូបអាកាសធាតុនេះអាចកើតឡើងដោយសារដំណើរការធម្មជាតិខាងក្នុងនៃ*ប្រព័ន្ធអាកាសធាតុ* (វិសមរូបផ្ទៃក្នុង)ឬរហូតដល់ការប្រែប្រួល*កម្លាំងជុំវិញពីខាងក្រៅ* ដោយធម្មជាតិឬដោយសារមនុស្ស(វិសមរូបខាងក្រៅ)។

**វេទិកាជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ National platform for disaster risk reduction**

យន្តការថ្នាក់ជាតិសម្រាប់មគ្គុទ្ទេសក៍គោលនយោបាយនិងសម្របសម្រួលស្តីពីការ*កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ* ដែលមានចរិតជាពហុវិស័យនិងអន្តរជំនាញ ដោយមានការចូលរួមពីវិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល ដែលពាក់ព័ន្ធរបស់ប្រទេសមួយ។

# ស

## សកម្មភាពជាតិកាត់បន្ថយសមស្រប Nationally Appropriate Mitigation Actions (NAMAs)

គោលនយោបាយនិងសកម្មភាពទាំងឡាយដែលជាផ្នែកមួយនៃការប្តេជ្ញាចិត្តក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយស្ម័គ្រចិត្ត ហើយត្រូវការជាចាំបាច់នូវការគាំទ្រនិងជំរុញដោយគោលនយោបាយ បច្ចេកវិទ្យា ហិរញ្ញប្បទាន និងការកសាងសមត្ថភាព ដែល*អាចវាស់វែងបាន អាចរាយការណ៍បាន និងអាចផ្ទៀងផ្ទាត់បាន*។

ក្នុងបរិបទប្រទេសកំពុងអភិវឌ្ឍ NAMA ត្រូវឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងអាទិភាពនានា ដើម្បីឈានឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ។

## សកម្មភាពបន្សាំមិនត្រឹមត្រូវ ឬបន្សាំមិនត្រឹមត្រូវ Maladaptive actions or maladaptation

សកម្មភាពទាំងឡាយដែលអាចនាំឱ្យមានកំណើនហានិភ័យធ្ងន់ធ្ងរទាក់ទងនឹងអាកាសធាតុ កំណើនភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ ឬការថយចុះសុខុមាលភាពរបស់ប្រព័ន្ធធម្មជាតិនិងមនុស្ស នាពេលបច្ចុប្បន្ននិងអនាគត។

## សកម្មភាពពន្លឺព្រះអាទិត្យ Solar activity

បាតុភូតម៉ាញេទិកលើផ្ទៃព្រះអាទិត្យ ដូចជា ចំណុចខ្មៅ ចំណុចភ្លឺ(ផ្នែកភ្លឺខ្លាំង) និងការឆេះកញ្ជ្រោល(ការបំភាយ ភាគល្អិតដែលមានថាមពលខ្លាំង) ដែលសកម្មភាពនេះខុសគ្នាទៅតាមពេលវេលាចាប់ពីនាទីរហូតដល់រាប់លានឆ្នាំ។

### សក្តិសិទ្ធិភាព Efficacy

រង្វាស់ដើម្បីឱ្យដឹងថា *កម្លាំងវិកាយរស្មី* មួយដែលចេញពីយន្តការបង្កដោយសកម្មភាពមនុស្សឬធម្មជាតិ មានប្រសិទ្ធភាពបែបណាក្នុងការធ្វើឱ្យមានការប្រែប្រួលលំនឹងសីតុណ្ហភាពផ្ទៃមធ្យមពិភពលោក ធៀបនឹងសមមូល*កម្លាំងវិកាយរស្មី* ចេញពី *ឧស្ម័នកាបូនិក*។

តាមការកំណត់ កំណើនឧស្ម័នកាបូនិកមួយឯកតាមានសក្តិសិទ្ធិភាពមួយ។ វិសមរូបសក្តិសិទ្ធិភាពអាកាសធាតុ អាចបណ្តាលមកពីការកែសម្រួលរហ័សនៃកម្លាំងដែលបានប្រើខុសពីកម្លាំងផ្សេងៗទៀត។

### សក្តានុពលកម្តៅសកល Global Warming Potential (GWP)

សន្ទស្សន៍មួយ(ផ្អែកលើលក្ខណៈវិកាយរស្មីនៃ *ឧស្ម័នផ្ទះកញ្ចក់* ដែលលាយចូលគ្នាសព្វល្អ) ប្រើប្រាស់ដើម្បីវាស់វែងអំណាចវិកាយរស្មីនៃម៉ាសឧស្ម័នផ្ទះកញ្ចក់មួយឯកតាដែលលាយចូលគ្នាសព្វល្អក្នុងបរិយាកាសបច្ចុប្បន្នក្នុងរយៈពេលកំណត់ធៀបនឹងឧស្ម័នកាបូនិក និងជាឥទ្ធិពលបញ្ចូលគ្នាក្នុងពេលខុសៗគ្នានៃឧស្ម័នទាំងនេះក្នុងបរិយាកាស និងប្រសិទ្ធភាពធៀបក្នុងការស្រូបយក*វិកាយរស្មីក្រហមអាំងហ្វ្រាកម្តៅ*ដែលភាយចេញ។

*ពិធីសារក្យូតូ* បានផ្អែកលើសក្តានុពលកម្តៅសកលនៃការបញ្ចេញឧស្ម័នក្នុងរយៈពេល១០០ឆ្នាំ។

### សក្តានុពលកាត់បន្ថយ Mitigation potential

បរិមាណឧស្ម័នដែលនឹងអាចកាត់បន្ថយបានរហូតដល់ពេលណាមួយ តែមិនទាន់កើតមានឡើងនៅឡើយទេ។

### សន្តិសុខថាមពល Energy security

វិធានការជានាសន្តិសុខដែលប្រជាជាតិមួយឬសហគមន៍ពិភពលោកទាំងមូលត្រូវតែអនុវត្ត ដើម្បីរក្សាការផ្គត់ផ្គង់ថាមពលឱ្យបានគ្រប់គ្រាន់។

**សន្តិសុខមនុស្ស Human security**

សុវត្ថិភាពមនុស្សពីការគំរាមកំហែងរ៉ាំរ៉ៃ(ភាពអត់ឃ្លាន ជំងឺ ភាពរាំងស្ងួត ទឹកជំនន់ ការប្រែប្រួលអាកាសធាតុ ...) និងកិច្ចការពារពីការរំខានភ្លាមៗ ពីការខូចប្រយោជន៍នៅក្នុងជីវភាពប្រចាំថ្ងៃ ទោះបីនៅក្នុងផ្ទះ កន្លែងធ្វើការ ឬក្នុងសហគមន៍ក៏ដោយ។

**សន្តិសុខស្បៀង Food security**

ស្ថានភាពប្រសើរមួយដែលកើតមានឡើងនៅពេលដែលប្រជាជនទទួលសិទ្ធិការពារក្នុងការទទួលបាននូវបរិមាណចំណីអាហារគ្រប់គ្រាន់ដែលមានសារជាតុចិញ្ចឹមនិងសុវត្ថិភាពសម្រាប់ការលូតលាស់ប្រចាំថ្ងៃ ការអភិវឌ្ឍនិងជីវិតដែលមានសុខភាពល្អនិងភាពសកម្ម។

អសន្តិសុខស្បៀងអាចបណ្ដាលមកពីភាពមិនអាចទទួលបានសិទ្ធិការពារនូវចំណីអាហារ លទ្ធភាពនៃការទិញមិនគ្រប់គ្រាន់ ការបែងចែកមិនសមស្រប ឬការបរិភោគអាហារមិនគ្រប់គ្រាន់នៅតាមលំនៅឋាន។

**សន្ទស្សន៍ភាពងាយរងគ្រោះ Vulnerability index**

រង្វាស់សម្រាប់កំណត់លក្ខណៈភាពងាយរងគ្រោះនៃប្រព័ន្ធមួយ។

ជាធម្មតា សន្ទស្សន៍ភាពងាយរងគ្រោះដោយសារអាកាសធាតុ បានមកពីការរួមបញ្ចូលសូចនាករមួយចំនួនដោយគិតឬមិនគិតពីតម្លៃវាស់វែងរបស់សូចនាករទាំងនោះដែលសន្មតជាសញ្ញានៃភាពងាយរងគ្រោះ។

**សន្និសីទបណ្ដាភាគី Conference of the Parties (COP)**

ស្ថាប័នកំពូលនៃ*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ* ក្នុងនោះ រដ្ឋសមាជិកដែលមានសិទ្ធិបោះឆ្នោតបានផ្ដល់សច្ចាប័នឬអនុម័តអនុសញ្ញានេះ។

សម័យប្រជុំលើកទីមួយនៃ *សន្និសីទបណ្តាភាគី* លើកទី១ បានប្រារព្ធនៅទីក្រុងប៊ែរឡាំង(១៩៩៥)និងមានកិច្ចប្រជុំប្រចាំឆ្នាំជាបន្តបន្ទាប់នៅកន្លែងផ្សេងៗទៀត។

**សន្និសីទបណ្តាភាគីសម្រាប់ពិធីសារក្យូតូ Conference of the Parties serving as the meeting of the Parties to the Kyoto Protocol (CMP)**

រចនាសម្ព័ន្ធនេះត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយថ្លៃចំណាយនិងកែលម្អប្រព័ន្ធគ្រប់គ្រងនៃដំណើរការរបស់*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ/ពិធីសារក្យូតូ*។

សន្និសីទបណ្តាភាគីសម្រាប់ពិធីសារក្យូតូ មានសិទ្ធិអំណាចលើ *យន្តការអភិវឌ្ឍន៍ស្អាត* និងមានសិទ្ធិអំណាចបង្កើតវិធានសម្រាប់ *យន្តការអភិវឌ្ឍន៍ស្អាត* សម្រេចលើអនុសាសន៍ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាភិបាលនិងចាត់តាំងអង្គភាពប្រតិបត្តិដែលបានទទួលស្គាល់ដោយក្រុមប្រឹក្សាភិបាលនេះ។

**សមត្ថភាពកាត់បន្ថយ Mitigative capacity**

លទ្ធភាពរបស់ប្រទេសមួយក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយសកម្មភាពមនុស្សឬក្នុងការបង្កើន*អាងស្រូប* កាបូនធម្មជាតិ។

លទ្ធភាពសំដៅលើបំណិន សមត្ថភាព ភាពសមស្រប និងភាពស្ទាត់ជំនាញដែលប្រទេសមួយបានទទួលនិងផ្អែកលើបច្ចេកវិទ្យា ស្ថាប័ន ធនធាន ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ និងព័ត៌មាន។ សមត្ថភាពកាត់បន្ថយ គឺជាមូលដ្ឋានគ្រឹះនៃមាគ៌ា*អភិវឌ្ឍន៍ប្រកបដោយចីរភាព*។

**សមត្ថភាពដោះស្រាយបញ្ហា/សមត្ថភាពឆ្លើយតប Coping capacity**

លទ្ធភាពរបស់មនុស្ស ស្ថាប័ន និងប្រព័ន្ធនានាដែលប្រើប្រាស់ជំនាញ ធនធាន និងកាលានុវត្តភាពដែលមានស្រាប់ ដើម្បីដោះស្រាយ គ្រប់គ្រង និងជម្នះបញ្ហាអវិជ្ជមាននានានៅក្នុងរយៈពេលពីខ្លីទៅមធ្យម។

**សមត្ថភាពបន្សាំ Adaptive capacity**

លទ្ធភាពរបស់ប្រព័ន្ធ(អេកូឡូស៊ី សង្គម ...) ស្ថាប័ន មនុស្ស និងសារពាង្គកាយនានា ដើម្បីសម្របទៅនឹងការខូចខាតទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដែលអាចកើតមានឡើងនិងទាញយកផលប្រយោជន៍ពីកាលានុវត្តភាព ឬឆ្លើយតបទៅនឹងផលវិបាកនានា។

**សមត្ថភាពផ្ទុកកាបូន Carbon carrying capacity**

បរិមាណនៃសក្តានុពលកាបូនដែលបានបង្ខាំងទុកក្នុងប្រព័ន្ធអេកូឡូស៊ីព្រៃឈើក្រោមលក្ខខណ្ឌបរិស្ថានធម្មតានិងរបបរំខានបែបធម្មជាតិ(បន្ទុះភ្នំភ្លើង ទឹកជំនន់ ...) ប៉ុន្តែមិនរាប់បញ្ចូលការរំខានពីមនុស្សឡើយ។

**សមមូលឧស្ម័នកាបូនិក $CO_2$-equivalent**

រង្វាស់ផលគុណគិតជាតោននៃ *ឧស្ម័នផ្ទះកញ្ចក់* ណាមួយជាមួយនឹង *សក្តានុពលកម្តៅសកល* នៃឧស្ម័នផ្ទះកញ្ចក់នោះ។ រង្វាស់នេះប្រើប្រាស់ដើម្បីប្រៀបធៀបការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នានា ដោយផ្អែកលើ *សក្តានុពលកម្តៅសកល*។

**សម័យហូឡូសែន Holocene**

សម័យធរណីវិទ្យាចុងក្រោយនៃកាលសម័យក្វាទែណៃ ក្នុងស័កសេណូសូអ៊ិកនៃអនន្តកាលហ្វាណេរ៉ូសូអ៊ិក ដែលមាន រយៈពេលប្រមាណ១១ ៦០០ឆ្នាំ ដោយគិតរហូតមកដល់បច្ចុប្បន្ននេះ។

**សហប្រយោជន៍ Co-benefit**

ឥទ្ធិពលវិជ្ជមាននៃគោលនយោបាយឬវិធានការមួយដែលដៅទៅរកវត្ថុបំណងមួយ តែអាចមានឥទ្ធិពលមកលើវត្ថុបំណងផ្សេងទៀត ដោយមិនគិតពីតុល្យភាពនៃឥទ្ធិពលពិតមកលើសុខុមាលភាពសង្គម។

សហប្រយោជន៍ភាគច្រើនគ្មានភាពប្រាកដប្រជា និងអាចប្រែប្រួលទៅតាមកាលៈទេសៈនៅមូលដ្ឋាននិងទម្លាប់ក្នុងការអនុវត្ត។

**សារធាតុបំផ្លាញស្រទាប់អូសូន Ozone Depleting Substance (ODS)**

សមាសធាតុមួយក្រុមដែលផលិតដោយមនុស្ស រាប់បញ្ចូលទាំង *ក្លរ៉ូហ្វ្លុយអូរ៉ូកាបូ (CFCs)* ប្រូម៉ូហ្វ្លុយអូរ៉ូកាបូ(ហាឡុង) មេទីលក្លរ៉ូហ្វម កាបូនតេត្រាក្លរ មេទីលប្រូមួ និង *អ៊ីដ្រូក្លរ៉ូហ្វ្លុយអូរ៉ូកាបូ(HCFCs)* ជាដើម ដែលជាសមាសធាតុមានលទ្ធភាពបំផ្លាញអូសូនក្នុង *មណ្ឌលអាកាសស្ទប់*។

**ស៊ីក្លូនបញ្ច្រាសរាំងខ្ទប់ Blocking anticyclones**

អង់ទីស៊ីក្លូនមួយដែលវិលបញ្ច្រាសស្ទើរតែនៅនឹងមួយកន្លែងក្នុងរយៈពេលមួយសប្តាហ៍ឬយូរជាងនេះ ពីតំបន់ដែលមានរយៈទទឹងពីមធ្យមទៅខ្ពស់ ដែលអាចរារាំងដល់ការវិវត្តធម្មតានៃប្រព័ន្ធសម្ពាធខ្ពស់ និងសម្ពាធខ្យល់ទាបឆ្ពោះទៅទិសខាងកើត។

**សីតុណ្ហភាពខ្យល់លើផ្ទៃដី Land surface air temperature**

សីតុណ្ហភាពខ្យល់ដែលវាស់នៅក្នុងរបាំងខ្យល់ហ៊ុមព័ទ្ធ ដែលមានចរន្តខ្យល់ឆ្លងកាត់បានល្អនៅកម្ពស់១,៥ទៅ២ម៉ែត្រពីលើផ្ទៃដី។

**សីតុណ្ហភាពផ្ទៃទឹកសមុទ្រ Sea Surface Temperature (SST)**

សីតុណ្ហភាពស្រទាប់ផ្ទៃលើបំផុតនៃសមុទ្រប្រមាណពី២ទៅ៣ម៉ែត្រ ដែលវាស់ដោយនាវា ពោង ឬវត្ថុអណ្តែត។

តាមមធ្យោបាយនាវា ការវាស់សំណាកទឹកក្នុងធុង ភាគច្រើនត្រូវបានផ្លាស់ប្តូរទៅជាសំណាកទឹកបូមចូលក្នុងម៉ាស៊ីនដាក់វត្ថុរាវផ្ទុកកម្តៅនៅក្នុងទសវត្សរ៍ទី៥នៃសតវត្សរ៍ទី២០។ តាមរយៈផ្កាយរណប សីតុណ្ហភាពស្រទាប់លើ (ស្រទាប់លើបំផុតនិងបំណែកនៃកម្រាស់មួយមិល្លីម៉ែត្រ) ត្រូវបានវាស់វែងដោយ *វិកិរណរស្មីក្រហមអាំងហ្វ្រា* ឬកម្រិតសង់ទីម៉ែត្រខាងលើ ឬដោយរលកអេឡិចត្រូម៉ាញ៉េទិក និងរលកវិទ្យុខ្លី ប៉ុន្តែត្រូវកែតម្រូវឱ្យស្របនឹងសីតុណ្ហភាពទឹក។

**សីតុណ្ហភាពលើផ្ទៃផែនដី** **Global surface temperature**

សីតុណ្ហភាពមធ្យមរបស់ខ្យល់លើផ្ទៃផែនដី។

ចំពោះការផ្លាស់ប្តូរសីតុណ្ហភាពតាមកាលវេលា ការប៉ាន់ស្មានត្រូវគិតពីការប្រែប្រួលដោយផ្អែកលើភាពមិនប្រក្រតីនៃសីតុណ្ហភាពមធ្យមរបស់លើផ្ទៃសមុទ្រ និងសីតុណ្ហភាពខ្យល់លើផ្ទៃដី។

**សុខុមាកាស/មីក្រូអាកាសធាតុ** **Microclimate**

អាកាសធាតុកំណត់នៃទីតាំងតូចណាមួយ ដែលខុសពីអាកាសធាតុជុំវិញ។

**សុរិយការ** **Insolation**

បរិមាណថាមពលនៃ*វិកិរណ៍ព្រះអាទិត្យ* ដែលចាំងមកដល់ផែនដីតាមរយៈខ្សែទទឹងនិងតាមរដូវកាលខុសៗគ្នា ហើយដែលតាមធម្មតា ជា*វិកិរណ៍* ដែលចាំងមកដល់ស្រទាប់លើបំផុតនៃ*បរិយាកាស*។ ជួនកាល គេសំដៅលើ*វិកិរណ៍* ដែលចាំងមកដល់ផ្ទៃផែនដី។

**សូចនាគោល** **Benchmark**

អថេរដែលអាចវាស់វែងសម្រាប់ជាមូលដ្ឋានឬយោងក្នុងការវាយតម្លៃការបំពេញការងាររបស់ស្ថាប័នមួយ។

ចំណុចគោលអាចទាញចេញពីបទពិសោធផ្ទៃក្នុងរបស់ស្ថាប័នមួយឬច្រើន ដែលស្ថាប័នផ្សេងៗត្រូវការ ឬជាតម្រូវផ្នែកច្បាប់ ដើម្បីវាស់វែងភាពប្រែប្រួលនៃប្រតិបត្តិការក្នុងរយៈពេលមួយ។

**សេចក្តីជូនដំណឹងជាតិ** **National Communication**

ឯកសារជាតិដែលត្រូវបញ្ជូនដោយអនុលោមតាម*អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ* ( និង *ពិធីសារក្យូតូ*)ដោយប្រទេសជាភាគីមួយដើម្បីជូនដំណឹងអំពីនិងសកម្មភាពដែលបានអនុវត្តក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុទៅកាន់ភាគីផ្សេងទៀត។

**សេដ្ឋកិច្ចបៃតង Green economy**

ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធផលដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ធនធានធម្មជាតិ ចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ច ដោយគិតគូរបន្ថែមលើការលើកទឹកចិត្ត ដូចជា ពន្ធបៃតង ហិរញ្ញវត្ថុបៃតង ពិសេសឥណទាននិងមីក្រូហិរញ្ញវត្ថុបៃតង ជាដើម។

**សេវាកម្មប្រព័ន្ធអេកូឡូស៊ី Ecosystem services**

ដំណើរការប្រព័ន្ធអេកូឡូស៊ី មុខងារនានាដែលមានតម្លៃជារូបិយវត្ថុឬមិនមែនរូបិយវត្ថុ សម្រាប់បុគ្គលម្នាក់ៗ ឬសង្គមទាំងមូល ដែលមានចំនួន៤ប្រភេទគឺ ទី១ សេវាកម្មគាំទ្រ ដូចជាផលិតភាព ឬការថែទាំជីវៈចម្រុះ ទី២ សេវាកម្មផ្តល់ឱ្យ ដូចជាចំណីអាហារ សារជាតុសរសៃ ត្រី ទី៣ សេវាកម្មកំណត់ ដូចជានិយ័តកម្មអាកាសធាតុ ឬការស្រូបកាបូននិងទី៤ សេវាកម្មវប្បធម៌ ដូចជា ទេសចរណ៍ ជំនឿខាងព្រលឹងវិញ្ញាណ និងសោភណភាព។

**សំណល់ឡជីវឧស្ម័ន Bioslurry**

សំណល់ហូរចេញពីឡជីវឧស្ម័នដែលទទួលរងនូវការបំបែកជាតុក្នុងលក្ខខណ្ឌគ្មានអុកស៊ីសែន ហើយគ្មានក្លិនស្អុយ មិនទាក់ទាញសត្វល្អិត ដូចជាជីលាមកសត្វ ព្រោះគ្រាប់ស្មៅនិងសត្វល្អិតត្រូវបានសម្លាប់ក្នុងឡជីវឧស្ម័ន។

**សំណាញ់សុវត្ថិភាព Safety nets**

ផ្នែកមួយនៃប្រព័ន្ធការពារសង្គមដែលជាទូទៅរួមបញ្ចូលទាំងការចូលរួមមិនមែនជាវិភាគទាន ដូចជា ស្បៀង ថវិកា ប័ណ្ណទិញទំនិញ ជាដើម ដែលអាចផ្តល់ជូនដោយមានលក្ខខណ្ឌឬគ្មានលក្ខខណ្ឌ សម្រាប់គោលដៅជាក់លាក់ ឬជាលក្ខណៈសកល ទាំងអន្តរាគមន៍នានា ដើម្បីបង្កើនភាពអាចស្វែងរកអាហារ និងតម្រូវការមូលដ្ឋានសំខាន់ៗ ដូចជា ការផ្តល់ឧបត្ថម្ភធន។

ពាក្យ សំណាញ់សុវត្ថិភាព សំណាញ់សុវត្ថិភាពសង្គម ការចូលរួមរបស់សង្គម និងជំនួយសង្គម ជារឿយៗអាចប្រើប្រាស់ជំនួសគ្នាបាន។

**សំណើមខ្យល់ Humidity**

បរិមាណ*ចំហាយទឹក* នៅក្នុងខ្យល់ ដែលបញ្ជាក់ពីភវនីយភាពនៃកំណកអាកាសធាតុ(ទឹកភ្លៀង សន្សើម អ័ព្ទ ...)។

បើកាលណាកម្រិតសំណើមខ្យល់ខ្ពស់ នោះប្រសិទ្ធភាពនៃការបញ្ចេញញើសថយចុះនិងធ្វើឱ្យរាងកាយត្រជាក់ ដោយការកាត់បន្ថយអត្រារំហួតសំណើមពីស្បែក។ ឥទ្ធិពលនេះត្រូវបានគណនាដោយតារាងសន្ទស្សន៍ កម្ដៅឬសន្ទស្សន៍សំណើម។

**សំណើមដី Soil moisture**

បរិមាណទឹកដែលរក្សាទុកនៅក្នុងដីក្នុងសណ្ឋានរាវឬកក។

**ស្តង់ដាកាបូនស្ម័គ្រចិត្ត Voluntary Carbon Standard (VCS)**

ស្តង់ដារឹងមាំជាសកលនិងជាកម្មវិធីសម្រាប់អនុម័តការទូទាត់ឧស្ម័នផ្ទះកញ្ចក់ដែលគួរឱ្យទុកចិត្តបាន។

ស្តង់ដាកាបូនស្ម័គ្រចិត្ត ត្រូវបានបង្កើតឡើងដោយក្រុមការងារអាកាសធាតុ សមាគមពាណិជ្ជកម្មការបញ្ចេញឧស្ម័នអន្តរជាតិ វេទិកាសេដ្ឋកិច្ចពិភពលោក និងក្រុមប្រឹក្សាពាណិជ្ជកម្មពិភពលោកសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

**សន្និធិកាបូន Carbon stock**

បរិមាណកាបូននៅក្នុងអាងបង្ខាំងមួយដែលមានសមត្ថភាពប្រមូលផ្តុំឬបញ្ចេញកាបូន។

**ស្ថានប្រព័ន្ធឬប្រព័ន្ធអេកូឡូស៊ី Ecosystem**

បណ្តុំមុខងារនៃប្រព័ន្ធមួយដែលរួមផ្សំឡើងដោយភាវៈមានជីវិត និងបរិស្ថានគ្មានជីវិតដែលនៅជុំវិញភាវៈមានជីវិតទាំងនោះ ព្រមទាំងអន្តរកម្មទៅវិញទៅមក

(អន្តរកម្មរវាងភាវៈមានជីវិតនិងបរិស្ថានគ្មានជីវិត និងអន្តរកម្មរវាងភាវៈមានជីវិតទាំងនោះ)។

ប្រព័ន្ធអេកូឡូស៊ីទាំងឡាយអាចរស់ក្នុងប្រព័ន្ធអេកូឡូស៊ីផ្សេងទៀត ហើយមាត្រដ្ឋានវាអាចប្រែប្រួលចាប់ពីតូចបំផុតរហូតដល់ *ជីវមណ្ឌល* ទាំងមូល។ បច្ចុប្បន្ននេះ ប្រព័ន្ធអេកូឡូស៊ីភាគច្រើនអាចរួមផ្សំដោយមនុស្សដែលជាសារពាង្គកាយសំខាន់ ហើយទទួលរងឥទ្ធិពលពីសកម្មភាពមនុស្សនៅក្នុងប្រព័ន្ធអេកូឡូស៊ីនោះ។

### ស្នាមបន្សល់ទុក Fingerprint

លំនាំនៃផលតបអាកាសធាតុនៅទីកន្លែងនិង/ឬពេលវេលាណាមួយ ទៅនឹងកម្លាំងជំរុញជាក់លាក់។

ស្នាមបន្សល់ទុកត្រូវបានប្រើប្រាស់ដើម្បីស្វែងរកវត្តមានប្រតិកម្មតបតាមការសង្កេត ហើយត្រូវបានប៉ាន់ប្រមាណដោយប្រើប្រាស់ការវិភាគត្រាប់ *ម៉ូដែលអាកាសធាតុ* ដែលមានកម្លាំងជំរុញ។

### ស្នូលទឹកកក Ice core

សំណាកទឹកកកដែលមានរាងស៊ីឡាំងដែលបានមកពីការខួងយកចេញពីផែនទឹកកកឬ *ស្រទាប់ទឹកកក*។

### ស្រទាប់ទឹកកក Ice sheet

គំនរផ្ទាំងទឹកកកដែលមានកម្រាស់ក្រាស់អាចគ្របដណ្តប់ផ្ទៃដីនិងស្រទាប់ថ្មហើយជាធម្មតាមានវិសាលភាពធំជាង៥០ ០០០គីឡូម៉ែត្រក្រឡា(ម៉ែត្រការ៉េ)។

នៅក្នុងពិភពលោកសព្វថ្ងៃនេះ មានស្រទាប់ទឹកកកធំៗចំនួនបី គឺនៅហ្គ្រីនលែននិងពីរទៀតនៅទ្វីបអង់តាកទិកពោលគឺស្រទាប់ទឹកកក អង់តាកទិកខាងកើតនិងខាងលិច ដែលញែកដាច់គ្នាដោយជួរភ្នំអង់តាកទិក។

### ស្រទាប់សកម្ម Active layer

ស្រទាប់ដីខាងលើដែលមានទឹកកករលាយនិងកកតាមរដូវ ហើយស្ថិតនៅពីលើ *កំណកអចិន្ត្រៃយ៍*។

### ស្រទាប់ព្រំប្រទល់បរិយាកាស Atmospheric boundary layer

ស្រទាប់បរិយាកាសជាប់ផ្ទៃផែនដី ដែលរងឥទ្ធិពលដោយការកកិតជាមួយផ្ទៃប៉ះ និងដោយការបញ្ជូនកម្តៅនិងកត្តាផ្សេងៗដែលឆ្លងកាត់ផ្ទៃនោះ។

ស្រទាប់ទាបបំផុត១០០ម៉ែត្រពីផ្ទៃដី(ប្រមាណ១០%នៃកម្រាស់ស្រទាប់ព្រំប្រទល់បរិយាកាស) ដែលជាតំបន់កកើតចរន្តឬកំណួចមេកានិកខ្លាំង មានឈ្មោះថាស្រទាប់ព្រំប្រទល់ផ្ទៃដីឬស្រទាប់ផ្ទៃដី។

### ស្រទាប់អូសូន Ozone layer

ស្រទាប់មួយ ដែលមានកំហាប់អូសូនខ្ពស់បំផុតនៅក្នុង *មណ្ឌលអាកាសស្ងប់* ដែលលាតសន្ធឹងប្រមាណ១២ទៅ៤០គីឡូម៉ែត្រពីផ្ទៃផែនដី ហើយកំហាប់អូសូនកើនដល់កម្រិតអតិបរមាចន្លោះពី២០ទៅ២៥គីឡូម៉ែត្រ។

ស្រទាប់នេះកំពុងរងការខូចខាតដោយសារការបញ្ចេញឧស្ម័នដែលផ្សំដោយក្លរនិងប្រូមតាមរយៈសកម្មភាពមនុស្ស។ ជារៀងរាល់ឆ្នាំ ការបាត់បង់ខ្លាំងបំផុតនៃស្រទាប់អូសូនកើតឡើងនៅនិទាឃរដូវក្នុងតំបន់អង់តាកទិក ដែលបង្កឡើងដោយសមាសធាតុក្លរនិងប្រូមចេញពីសកម្មភាពមនុស្ស គួបផ្សំនឹងលក្ខខណ្ឌឧតុនិយមជាក់លាក់នៃតំបន់នោះ។ បាតុភូតនេះបង្កើតឱ្យមាន *ប្រហោងអូសូន* ។

### សូចនាករអាកាសធាតុជំនួស Proxy climate indicator

កំណត់ត្រាមូលដ្ឋានដែលត្រូវបានបកស្រាយដោយប្រើគោលការណ៍រូបសាស្ត្រ និងជីវរូបសាស្ត្រ ដើម្បីបង្ហាញពីសំណុំខ្លះៗនៃភាពផ្សេងគ្នារបស់អាកាសធាតុអតីតកាល ហើយទិន្នន័យទាក់ទងនឹងអាកាសធាតុដែលទទួលបានតាមរយៈវិធីនេះ ហៅថាទិន្នន័យជំនួសដែលអាចត្រូវបានក្រិតតាមខ្នាត ដើម្បីផ្តល់ព័ត៌មានអាកាសធាតុតាមបែបបរិមាណវិស័យ។ ឧទាហរណ៍ : កំណត់ត្រារង្វង់នៅលើមុខកាត់ដើមឈើ លក្ខណៈរបស់ផ្កាថ្ម និងទិន្នន័យនានាដែលបានមកពីស្នូលទឹកកក។

# ហ

**ហានិភ័យគ្រោះមហន្តរាយ Disaster risk**

សក្តានុពលនៃ *គ្រោះមហន្តរាយ* ដែលឈានទៅរកការប៉ះពាល់ដល់និងបាត់បង់អាយុជីវិត ស្ថានភាពសុខភាព ជីវភាព ទ្រព្យសម្បត្តិ និងសេវាកម្មដែលអាចកើតឡើងក្នុងសហគមន៍ឬសង្គមមួយក្នុងពេលវេលាជាក់លាក់នាពេលអនាគត។

**ហាឡូកាបូ Halocarbons**

ក្រុមសមាសធាតុសរីរាង្គដែលមួយផ្នែកផ្សំដោយហាឡូសែន រួមបញ្ចូលទាំង *ក្លរ៉ូភ្លុយអូរ៉ូកាបូ(CFCs)* *អ៊ីដ្រូក្លរ៉ូភ្លុយអូរ៉ូកាបូ(HCFCs)* *អ៊ីដ្រូភ្លុយអូរ៉ូកាបូ(HFCs)* *ហាឡុង* មេទីលក្លរ មេទីលប្រូម។ល។

សមាសធាតុហាឡូកាបូជាច្រើន មានសក្តានុពលកម្តៅសកលកម្រិតខ្ពស់ ហើយហាឡូកាបូដែលផ្សំដោយក្លរនិងប្រូមជាសមាសធាតុធ្វើឱ្យធ្លុះធ្លាយ *ស្រទាប់អូសូន*។

# ឡ

**ឡជីវឧស្ម័ន Biodigester**

សំណង់មូលមួយប្រភេទសង់ពីឥដ្ឋតាន់និងបេតុងកប់ក្នុងដី ផ្ទុកដោយលាមកសត្វដែលអាចបង្កើតឧស្ម័នមេតានឬជីវឧស្ម័ន ហើយអាចបន្សល់នូវជីធម្មជាតិដ៏ល្អប្រសើរ។

**ឧស្ម័នករ Gasifier**

ឡឬឧបករណ៍សម្រាប់ផលិតឧស្ម័ន ជាពិសេស ឧស្ម័នសំយោគដែលផលិតចេញពី ធ្យូងថ្ម ជីវម៉ាស។

# ដដ

**អង្គភាពទទួលបន្ទុកប្រតិបត្តិ Designated Operational Entity (DOE)**

អង្គភាពមួយដែលកំណត់ដោយ *សន្និសីទបណ្តាភាគីសម្រាប់ពិធីសារក្យូតូ* ថាជាអង្គភាពដែលមានគុណវុឌ្ឍិក្នុងការផ្តល់សុពលភាពដល់គម្រោង *យន្តការអភិវឌ្ឍន៍ស្អាត* ដែលបានស្នើសុំ ក៏ដូចជាក្នុងការ *ផ្ទៀងផ្ទាត់* និងការបញ្ជាក់អំពីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពមនុស្ស និងការស្រូបយកឧស្ម័នផ្ទះកញ្ចក់ពិតតាមរយៈ *អាងស្រូបកាបូន*។

**អត្ថប្រយោជន៍បន្សាំ Adaptation benefits**

តម្លៃនៃការខូចខាតដែលបានបញ្ចៀសឬអត្ថប្រយោជន៍បន្ថែម បន្ទាប់ពីមានការអនុម័តនិងអនុវត្តវិធានការបន្សាំ។

**អត្ថប្រយោជន៍កាបូន Carbon benefit**

បរិមាណនៃការបញ្ចេញ *ឧស្ម័នផ្ទះកញ្ចក់* ដែលត្រូវបានកាត់បន្ថយ ឬបរិមាណកាបូនដែលបានស្រូបលើសពីចំហាក *តាមទម្លាប់ធម្មតា* បន្ទាប់ពីការដកចេញដ៏សមស្របចំពោះ *ការធ្លាយចេញ* និងភាពមិនអចិន្ត្រៃយ៍។

អត្ថប្រយោជន៍កាបូន ត្រូវបានវាស់វែងដោយគិតជាតោននៃ *សមមូលឧស្ម័នកាបូនិក*។

**អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ United Nations Framework Convention on Climate Change (UNFCCC)**

អនុសញ្ញាដែលត្រូវបានធ្វើសេចក្តីព្រាងឡើងនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩២ នៅទីក្រុងញូវយ៉ក ហើយត្រូវបានចុះហត្ថលេខាដោយប្រទេសជាង១៥០និង

សហគមន៍អឺរ៉ុបនៅក្នុងកិច្ចប្រជុំកំពូលពិភពលោក នាថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៩២ នៅទីក្រុងរីយ៉ូដឺហ្សាណេរ៉ូ ហើយដែលបានចូលជាធរមាននៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៤។

គោលបំណងចម្បងនៃអនុសញ្ញានេះគឺ ធ្វើឱ្យមាន"ស្ថិរភាពកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសនៅត្រឹមកម្រិតមួយដែលអាចទប់ស្កាត់ការរំខានប្រកបដោយគ្រោះថ្នាក់ពីសកម្មភាពមនុស្សមកលើ*ប្រព័ន្ធអាកាសធាតុ*។"

អនុសញ្ញានេះចែងអំពីការប្តេជ្ញាចិត្តរបស់បណ្តាភាគីទាំងអស់។ ក្រោមអនុ-សញ្ញានេះ *បណ្តាភាគីក្នុងឧបសម្ព័ន្ធ១* (គ្រប់ប្រទេសជាសមាជិកអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ និងប្រទេសមានសេដ្ឋកិច្ចអន្តរកាល)មានគោលដៅបង្វែរការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលមិនស្ថិតនៅក្រោម*ពិធីសារម៉ុងរ៉េអាល់* មកនៅត្រឹមកម្រិតឆ្នាំគោល១៩៩០ ឱ្យបាននៅត្រឹមឆ្នាំ២០០០។ ឆ្នាំ១៩៩៧ អនុសញ្ញានេះបានអនុម័តឱ្យមានពិធីសារក្យូតូ។

**អត្រាតំហយកម្តៅ Lapse rate**

នៅរយៈកម្ពស់កាន់តែខ្ពស់ អត្រាសីតុណ្ហភាពបរិយាកាសកាន់តែត្រជាក់។

**អភិបាលកិច្ចអាកាសធាតុ Climate governance**

កិច្ចការទូត យន្តការ និងវិធានការនានាក្នុងគោលបំណងដឹកនាំប្រព័ន្ធសង្គមឆ្ពោះទៅរកការទប់ស្កាត់ កាត់បន្ថយ ឬបន្សាំទៅនឹងហានិភ័យទាំងឡាយដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។

**អភិរក្សថាមពល Energy conservation**

ការកាត់បន្ថយថាមពលតាមរយៈការប្រើប្រាស់សេវាកម្មថាមពលដែលមានបរិមាណតិចជាងមុន។

**អភិវឌ្ឍន៍បៃតង Green growth**

ការអភិវឌ្ឍដែលប្រើប្រាស់ធនធានប្រកបដោយចីរភាព រួមមាន ការងារបរិស្ថានបៃតងនិងធនធានធម្មជាតិ ទឹកនិងអនាម័យ សេដ្ឋកិច្ចនិងវិនិយោគ

ទូរគមនាគមន៍និងដឹកជញ្ជូន ឧស្សាហកម្មនិងថាមពល ទេសចរណ៍បៃតង *សន្តិសុខស្បៀង* និងសុវត្ថិភាពចំណីអាហារ និងការប្រើប្រាស់ដីធ្លី។

**អភិវឌ្ឍន៍ប្រកបដោយចីរភាព Sustainable development**

ការអភិវឌ្ឍដែលបំពេញសេចក្តីត្រូវការបច្ចុប្បន្ន ដោយមិនប៉ះពាល់ដល់លទ្ធភាពរបស់មនុស្សជំនាន់ក្រោយក្នុងការបំពេញសេចក្តីត្រូវការរបស់ពួកគេផ្ទាល់។

**អ្នកចូលរួមគម្រោង Project participant**

ភាគីពាក់ព័ន្ធមួយដែលមានបំណងចូលរួម ឬវិស័យឯកជននិង/ឬអង្គភាពសាធារណៈដែលទទួលការអនុញ្ញាតពី*អាជ្ញាធរជាតិទទួលបន្ទុក* ដែលអាចចូលរួមក្នុងសកម្មភាពគម្រោងឬសកម្មភាពតាមកម្មវិធីរបស់ *យន្តការអភិវឌ្ឍន៍ស្អាត* ដែលអាចអនុវត្តបាន។

**អាកាសធាតុ Climate**

លក្ខខណ្ឌបរិយាកាសនិងបាតុភូតឧតុភូតមធ្យមនៃរដូវទាំងអស់ គិតជាស្ថិតិមធ្យមភាគរបស់តំបន់ណាមួយ ដែលពិនិត្យឃើញរយៈពេលយូរឆ្នាំ/៣០ឆ្នាំ។ លក្ខខណ្ឌបរិយាកាស/វិសម្សបអាកាសធាតុមានសម្ពាធបរិយាកាស សីតុណ្ហភាព សូរ្យការ សំណើម ទឹកភ្លៀង ពពក ខ្យល់។

អ្នកជំនាញភូមិវិទ្យាបានបែងចែកអាកាសធាតុជាប្រាំក្រុមគឺៈ

១- អាកាសធាតុក្តៅ

២- អាកាសធាតុក្បែរត្រូពិក

៣- អាកាសធាតុត្រជាក់បង្គួរ

៤- អាកាសធាតុត្រជាក់

៥- អាកាសធាតុភ្នំ។

**អាកាសធាតុធ្ងន់ធ្ងរ Climate extreme**

ការកើតមានឡើងនៃតម្លៃអថេរធាតុអាកាសឬអាកាសធាតុនៅលើ(ឬខាងក្រោម)នៃតម្លៃកម្រិតក្បែរចុងខាងលើ(ឬចុងខាងក្រោម)នៃការកម្រិតអថេរដែលបានសង្កេត។

**អាកាសធាតុកាលបុរាណ Paleoclimate**

អាកាសធាតុនៅកាលសម័យដែលមិនទាន់មានឧបករណ៍សម្រាប់វាស់វែង រួមទាំងប្រវត្តិកាលនិងធរណីកាល ដែលនៅកាលសម័យនោះ មានតែកំណត់ត្រាអាកាសធាតុជំនួសមួយគត់(ក្រយៅឈើ លក្ខណៈរបស់ផ្កាថ្ម ...)ដែលអាចប្រើប្រាស់បាន។

**អាងបង្ខាំង Reservoir**

សមាសភាគមួយនៃ*ប្រព័ន្ធអាកាសធាតុ* ក្រៅពីបរិយាកាស ដែលមានសមត្ថភាពស្តុកទុក ប្រមូលផ្តុំ ឬបញ្ចេញសារធាតុដែលពាក់ព័ន្ធ ដូចជា កាបូន *ឧស្ម័នផ្ទះកញ្ចក់* ប្រភេទណាមួយ ឬ*បុរេករ* ប្រភេទណាមួយ។

ឧទាហរណ៍ មហាសមុទ្រ ដី និង*ព្រៃឈើ* គឺជា*អាងបង្ខាំង* នៃសារធាតុនានាដែលមានជាអាទិ៍*កាបូន* ។

អាង(Pool) មានន័យសមមូលគ្នានឹងអាងបង្ខាំង។ ប៉ុន្តែជាទូទៅ អាង រួមបញ្ចូលទាំងបរិយាកាស។

បរិមាណច្បាស់លាស់នៃសារធាតុពាក់ព័ន្ធនៅក្នុងអាងបង្ខាំងក្នុងពេលវេលាជាក់លាក់ណាមួយហៅថា បង្ខាំង(Stock)។

**អាងស្រូប Sink**

ដំណើរការ សកម្មភាព ឬយន្តការដែលស្រូបយក*ឧស្ម័នផ្ទះកញ្ចក់ អាអេរ៉ូសូល* ឬ*បុរេករ* នៃឧស្ម័នផ្ទះកញ្ចក់ ឬនៃ*អាអេរ៉ូសូល* ចេញពីបរិយាកាស។

**អាងស្រូបកាបូន** **Carbon sink**

ដំណើរការ សកម្មភាព ឬយន្តការណាមួយដែលនាំឱ្យមានការស្រូបយកពិតៗនូវ *ឧស្ម័នផ្ទះកញ្ចក់* ពី *បរិយាកាស*។

**អាជ្ញាធរជាតិទទួលបន្ទុក** **Designated National Authority (DNA)**

ស្ថាប័នដែលយល់ព្រមយកការទទួលខុសត្រូវពីភាគីមួយទៀត ដើម្បីចេញលិខិតអនុម័តសកម្មភាពគម្រោង *យន្តការអភិវឌ្ឍន៍ស្អាត* ឬកម្មវិធីនៃសកម្មភាពក្នុងនាមភាគីមួយនោះ ដោយអនុលោមតាមវិធាននិងតម្រូវការរបស់ *យន្តការអភិវឌ្ឍន៍ស្អាត*។

**អាល់បេដូ** **Albedo**

ចំណែកនៃ *រំកាយរស្មីព្រះអាទិត្យ* ដែលចាំងផ្លាតពីផ្ទៃផែនដីឬពីវត្ថុអ្វីមួយ ហើយដែលជាទូទៅ គិតជាភាគរយធៀបទៅនឹងរំកាយរស្មីព្រះអាទិត្យដែលបានទទួល។

ផ្ទៃដែលគ្របដណ្តប់ដោយព្រឹលមានកម្រិតអាល់បេដូខ្ពស់។ អាល់បេដូរបស់ដីមានកម្រិតពីខ្ពស់មកទាប។ គម្របព្រៃនិងផ្ទៃសមុទ្រមានកម្រិតអាល់បេដូទាប។ អាល់បេដូផ្ទៃផែនដីមានភាពខុសគ្នា ជាពិសេស ដោយសារការប្រែប្រួលពពក ព្រឹល ផ្ទៃស្លឹករុក្ខជាតិ និងគម្របដី។

**អាស៊ីតកម្មមហាសមុទ្រ** **Ocean acidification**

ការថយចុះ *ប៉េហាស់* នៃមហាសមុទ្រចាប់ពីកម្រិត៧ ក្នុងរយៈពេលវែងមួយ ដែលតាមធម្មតាមានរយៈពេលច្រើនទសវត្សរ៍ឬវែងជាងនេះ ដែលច្រើនតែបង្កដោយការស្រូបយក *ឧស្ម័នកាបូនិក* ចេញពីបរិយាកាស ប៉ុន្តែក៏អាចបណ្តាលមកពីកំណើនឬការថយចុះសារធាតុគីមីដទៃទៀតពីមហាសមុទ្រផងដែរ។

អាស៊ីតកម្មមហាសមុទ្រដោយសកម្មភាពមនុស្ស សំដៅលើការថយចុះនៃ *ប៉េហាស់* ដែលបង្កដោយសកម្មភាពមនុស្ស ដូចជា ការតាំងទីលំនៅក្បែរសមុទ្រ ហួសកម្រិត ការបង្ហូរកាកសំណល់រឹងរាវ សំណល់ប្លាស្ទិកចូលក្នុងសមុទ្រ ជាដើម។

**អាអេរ៉ូសូល Aerosol**

ក្រុមចុណ្ណភាគរឹងឬរាវនៅក្នុងខ្យល់ មានទំហំពី០,០១ទៅ១០មីក្រូម៉ែត្រ ដែលអណ្តែតវិលវល់ក្នុងបរិយាកាសជាច្រើនម៉ោង។ អាអេរ៉ូសូល អាចកើតមានឡើងដោយធម្មជាតិឬដោយសារសកម្មភាពមនុស្ស។ អាអេរ៉ូសូលអាចមានឥទ្ធិពលមកលើអាកាសធាតុតាមទម្រង់ច្រើនយ៉ាងដូចជា តាមរយៈការពង្រាយ និងការស្រូបយករំភាយរស្មីដោយផ្ទាល់និង ដោយប្រយោល តាមរយៈការដើរតួជា *ស្នូលកំណកពពក* ឬការផ្លាស់ប្តូរលក្ខណៈអុបទិក និងអាយុកាលរបស់ពពក។

**អាអេរ៉ូសូលកាបូន Carbonaceous aerosol**

អាអេរ៉ូសូលដែលភាគច្រើនផ្សំឡើងដោយសារធាតុសរីរាង្គជាច្រើននិងកាបូនខ្មៅក្នុងទម្រង់ខុសៗគ្នា។

**អាអេរ៉ូសូលសរីរាង្គ Organic aerosol**

ចុណ្ណភាគនានារបស់*អាអេរ៉ូសូល* ដែលសំបូរដោយសមាសធាតុសរីរាង្គភាគច្រើនជាកាបូន អ៊ីដ្រូសែន អុកស៊ីសែននិងសារធាតុផ្សេងទៀតតិចតួច។

**ឥទ្ធិពលហៀរចេញ Spill-over effect**

ឥទ្ធិពលនៃវិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងស្រុកឬតាមវិស័យ មកលើប្រទេសឬលើវិស័យដទៃទៀត។ ឥទ្ធិពលហៀរចេញអាចផ្តល់ផលវិជ្ជមានឬអវិជ្ជមាន និងរួមបញ្ចូលឥទ្ធិពលទៅលើពាណិជ្ជកម្ម*ការធ្លាយចេញកាបូន* ការផ្ទេរនវកម្មនិង ការផ្សព្វផ្សាយ*បច្ចេកវិទ្យាល្អបរិស្ថាន* និងទៅលើបញ្ហាដទៃទៀត។

**ឥណទានកាបូន Carbon credit**

ការទូទាត់កាបូន គិតជាឯកតាហិរញ្ញវត្ថុនៃការវាស់វែងដែលតាងការស្រូបយក *ឧស្ម័នផ្ទះកញ្ចក់* ដែល *សមមូលឧស្ម័នកាបូនិក* ចំនួន១តោនពីបរិយាកាស។

**ឥន្ធនៈហ្វូស៊ីល Fossil fuel**

ឥន្ធនៈផ្ទុកសារធាតុកាបូនដែលកើតចេញពីកំណអ៊ីដ្រូកាបូនហ្វូស៊ីល រួមមានធ្យូងថ្ម រុក្ខជាតិពុកផុយ ប្រេង និងឧស្ម័នធម្មជាតិ។

**អ៊ីដ្រូកាបួ Hydrocarbons**

សមាសធាតុដែលផ្សំតែពីអ៊ីដ្រូសែននិងកាបូន។

ឧទាហរណ៍ អ៊ីដ្រូកាបួជាសមាសធាតុមួយបង្កើតឥន្ធនៈហ្វូស៊ីល។

**អ៊ីដ្រូក្លរ៉ូភ្លុយអរ៉ូកាបួ Hydrochlorofluorocarbons (HCFCs)**

សមាសធាតុផ្សំដោយអាតូមអ៊ីដ្រូសែន ភ្លុយអរ ក្លរ និងអាតូមកាបូន។

ទោះបីវាជា *សារធាតុបំផ្លាញស្រទាប់អូសូន* ក៏ដោយ ក៏ឥទ្ធិពលរបស់វាក្នុងការបំផ្លាញអូសូនក្នុង *មណ្ឌលអាកាសស្ងប់* តិចជាង *ក្លរ៉ូភ្លុយអរ៉ូកាបួ(CFCs)* ។ ហេតុនេះហើយបានជាសារធាតុទាំងនេះត្រូវបានដាក់ឱ្យប្រើជំនួស *ក្លរ៉ូភ្លុយអរ៉ូកាបួ (CFCs)* ជាបណ្ដោះអាសន្ន ទោះបីវាជា *ឧស្ម័នផ្ទះកញ្ចក់* ក៏ដោយ។

**អ៊ីដ្រូភ្លុយអរ៉ូកាបួ Hydrofluorocarbons (HFCs)**

*ឧស្ម័នផ្ទះកញ្ចក់* មួយប្រភេទក្នុងចំណោម *ឧស្ម័នផ្ទះកញ្ចក់* ឬក្រុម *ឧស្ម័នផ្ទះកញ្ចក់* ទាំង៦ ដែលនឹងត្រូវទប់ស្កាត់ដូចមានចែងក្នុង *ពិធីសារក្យូតូ* ។

អ៊ីដ្រូភ្លុយអរ៉ូកាបួត្រូវបានផលិតជាលក្ខណៈពាណិជ្ជកម្ម ដើម្បីជំនួស *ក្លរ៉ូភ្លុយអរ៉ូកាបួ(CFCs)* ។ អ៊ីដ្រូភ្លុយអរ៉ូកាបួត្រូវបានប្រើប្រាស់ភាគច្រើនសម្រាប់សីតកម្ម(refrigeration)និងការផលិតអង្គធាតុអឌ្ឍចម្លង(សឺមីកុងឌុចទ័រ)។ *សក្ដានុពលកម្ដៅសកល* របស់វា គឺចាប់ពី១ ៣០០ ទៅ ១១ ៧០០។

**ឧបសគ្គបន្សាំ Adaptation constraint**

កត្តានានាដែលធ្វើឱ្យកាន់តែលំបាកដល់ការរៀបចំផែនការបន្សាំនិងការអនុវត្តសកម្មភាពបន្សាំ ឬកត្តាដែលកម្រិតជម្រើសបន្សាំនានា។

**ឧស្ម័នកម្រ Trace gas**

ឧស្ម័នដែលមានតិចជាង១%នៃមាឌបរិយាកាសរបស់ផែនដី ក្នុងនោះអាកុង (Ar) ដែលជាឧស្ម័នកម្រមានបរិមាណលើសលប់រហូតដល់០៩៣៤,%។

ឧស្ម័នកម្រមានដូចជា អេល្យូម(He) ណេអុង(Ne) អាកុង(Ar) គ្រីបតុង(Kr) សេណុង(Xe) រ៉ាដុង(Rn)ជាដើម។

**ឧស្ម័នកាបូនិក Carbon dioxide ($CO_2$)**

